ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការចិញ្ចឹមមាន់



បំណិនជីវិតសម្រាប់មធ្យមសិក្សាបឋមភូមិ
គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ : [illegible] អយក.ប្រក

# ប្រកាស
## ស្តីពី
## ការអនុញ្ញាតឱ្យបោះពុម្ពផ្សាយ
## សៀវភៅ " ការចិញ្ចឹមមាន់ "

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- យោងគោលនយោបាយសម្រាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំណេះទូទៅ២០០៥-២០០៩
- យោងសេចក្តីណែនាំលេខ០៣ អយក. សណន.ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ របស់ក្រសួងអប់រំ យុវជន និង កីឡា ស្តីពីប្រព័ន្ធអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស
- យោងសំណើរបស់អង្គការអប់រំពិភពលោក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២
- យោងកំណត់ហេតុប្រជុំរបស់លេខាធិការដ្ឋានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេសនាថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៣
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាអនុម័តសៀវភៅសិក្សា និងសម្ភារឧបទេស

## សម្រេច

ប្រការ១- អនុញ្ញាតឱ្យបោះពុម្ពផ្សាយសៀវភៅ " ការចិញ្ចឹមមាន់ " ដែលជាស្នាដៃនិពន្ធ និងរៀបរៀងរបស់អង្គការអប់រំពិភពលោក សហការជាមួយក្រសួងអប់រំ យុវជននិងកីឡា ដើម្បីប្រើប្រាស់ជាឯកសារជំនួយក្នុងការបង្រៀន និងរៀនកម្មវិធីបំណិនជីវិតនៅតាមអនុវិទ្យាល័យ ។

ប្រការ២- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ និងអង្គការអប់រំពិភពលោក មានភារកិច្ចអនុវត្តប្រកាសនេះ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

អ៊ឹម_សិទ្ធី

កន្លែងទទួល :
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន"
- ដូចប្រការ២
- កាលប្បវត្តិ- ឯកសារ.អ.គ.ស.

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: [illegible] ទូរសារ: [illegible]
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

**គណៈកម្មការអភិវឌ្ឍសៀវភៅ**
**"ការចិញ្ចឹមមាន់"**

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោក ស៊ី ប៉េងគ្រុយ
២. លោក អេង សុខ
៣. លោក វីលៀម វ៉ាន់ឌឺវ៉ាល់

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណឆន
២. លោក ប៊ុត សុភាន់
៣. លោក ផុក ចាន់ថុល

**គណៈកម្មការពិនិត្យ**

១. លោកស្រី យឹម យីហ៊ុប
២. លោក ព្រៃ សំបូរ

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ(USAID)

សហការរៀបចំដោយ
អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា


អារម្ភកថា.............................................................................................. ក

វត្ថុបំណងរួម.............................................................................................. ខ

ការត្រៀមលក្ខណៈមុនពេលបង្រៀន............................................................. ខ

ខ្លឹមសារសង្ខេប........................................................................................ គ

មេរៀនទី ១: ការជ្រើសរើសទីកន្លែងចិញ្ចឹមមាន់........................................ ១

មេរៀនទី ២: របៀបសង់ទ្រុងមាន់.......................................................... ៤

មេរៀនទី ៣: របៀបចិញ្ចឹមមាន់.............................................................. ៨

មេរៀនទី ៤: របៀបផ្សំចំណីមាន់........................................................... ១៣

មេរៀនទី ៥: របៀបធ្វើកំប៉ុស្តមាន់.......................................................... ១៨

មេរៀនទី ៦: អនាម័យទ្រុងមាន់............................................................ ២១

មេរៀនទី ៧: ជ្រើសរើសមាន់ទុកចិញ្ចឹមបន្ត............................................ ២៥

មេរៀនទី ៨: ការទម្លាក់ព្រូនមាន់.......................................................... ៣០

មេរៀនទី ៩: ជំងឺមាន់........................................................................ ៣៣

មេរៀនទី ១០: ចំណេះដឹងក្នុងការចិញ្ចឹមមាន់........................................... ៣៩




# អារម្ភកថា

វិស័យអប់រំជាវិស័យគន្លឹះមួយ ដែលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ពិសេសការ អភិវឌ្ឍធនធានមនុស្ស ។ ដោយសង្គមជាតិយើងមានការអភិវឌ្ឍលើគ្រប់វិស័យ ការអប់រំក៏ត្រូវបានយកចិត្តទុកដាក់យ៉ាងខ្លាំង ដើម្បីបណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយគុណភាពនិងមានជំនាញខ្ពស់ ដើម្បីបំពេញលើគ្រប់លក្ខខណ្ឌការងារ ។

ដើម្បីឆ្លើយតបនឹងតម្រូវការរីកចម្រើននៃទីផ្សារសេរីរបស់សង្គមជាតិ ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតគោលនយោបាយសម្រាប់អភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ និងគោលនយោបាយអប់រំបំណិនជីវិត សម្រាប់អនុវត្តនៅតាមសាលារៀនចំណេះទូទៅ។

កម្មវិធីអប់រំបំណិនជីវិតតាមមូលដ្ឋាន គឺជាស្នូលនៃការបង្កើនគុណភាព និងប្រសិទ្ធភាពក្នុងវិស័យអប់រំ ដែលនឹងផ្តល់ឱ្យសិស្សនូវចំណេះដឹងមូលដ្ឋានយ៉ាងជ្រៅជ្រះ និងបណ្តុះជំនាញផ្សេងៗ ដែលមានសារសំខាន់សម្រាប់ការស្រូបយកបទពិសោធន៍ល្អៗក្នុងការពង្រឹងចំណេះដឹង និងបំណិនចាំបាច់សម្រាប់បម្រើជីវភាពរស់នៅប្រចាំថ្ងៃ។

ការចិញ្ចឹមមាន់ មានតាំងពីយូរយារណាស់មកហើយ ប៉ុន្តែយើងម្នាក់ៗចិញ្ចឹមមាន់សម្រាប់តែបរិភោគប្រចាំគ្រួសារប៉ុណ្ណោះ។អ្នកចិញ្ចឹមមាន់ទាំងនោះ អាចលក់ដូរដោះស្រាយជីវភាពបានតិចតួចមិនអាចចាត់ទុកជាអាជីពសម្រាប់គ្រួសារបានឡើយ។

រាល់ការចិញ្ចឹមមាន់តាមគ្រួសារនីមួយៗ យើងពុំទាន់គិតពីលក្ខណៈបច្ចេកទេសដូចជា អនាម័យទីកន្លែងចិញ្ចឹមការជ្រើសរើសពូជ ការចាក់វ៉ាក់សាំងការពារ និងថ្នាំព្យាបាល។ ដោយយល់ឃើញដូច្នេះ គណៈកម្មការអភិវឌ្ឍន៍វិស័យផលិតកម្មនិងបសុព្យាបាល បានរៀបចំឯកសារស្តីពីការចិញ្ចឹមមាន់នេះឡើង ក្នុងគោលបំណងលើកស្ទួយការចិញ្ចឹមមាន់នេះឱ្យទទួលបានជោគជ័យ និងក្លាយជាលក្ខណៈអាជីព។

ឯកសារស្តីអំពី "ការចិញ្ចឹមមាន់" មានបំណងជួយសិស្ស ឱ្យទទួលបាននូវចំណេះដឹង បំណិន និងបទពិសោធន៍ក្នុងផ្នែក បំណិនជីវិតងាយៗ ដែលទាក់ទងនឹងការចិញ្ចឹមមាន់ ។ ការចិញ្ចឹមមាន់មានតួនាទីសំខាន់ក្នុងផលិតកម្មសម្រាប់គ្រួសារ។ការរៀនពីរបៀបចិញ្ចឹមមាន់តាំងពីនៅវ័យក្មេងបានផ្សារភ្ជាប់ទៅនឹងតម្រូវការទៅតាមអាទិភាពនិងគោលបំណង ដើម្បីជួយមនុស្សពេញវ័យឱ្យជៀសផុតពីការប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីខ្វះការយល់ដឹងក្នុងការធ្វើផលិតកម្មកសិកម្ម។ យើងសង្ឃឹមថា យុវជនបច្ចុប្បន្ននឹងមានគំនិតក្នុងការធ្វើផែនការ ការរៀបចំថវិកា សម្ភារៈ និងអនុវត្តការចិញ្ចឹមមាន់ទៅតាមដំណាក់កាលសំខាន់ៗ ដើម្បីឱ្យមុខរបរនេះក្លាយជាការអភិវឌ្ឍជីវភាពក្នុងគ្រួសារ។

## ១. វត្ថុបំណងរួម

បំណិនជីវិត គឺជាបំណិនបញ្ញា បុគ្គលិកលក្ខណៈ អន្តរបុគ្គល និងវិជ្ជាជីវៈ ដែលអាចជួយដល់ការ ធ្វើការ សម្រេចចិត្ត ការធ្វើទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព និងអាចដោះស្រាយ និងគ្រប់គ្រងខ្លួនឯងបាន។ គឺជាបំណិនដែលរួមចំណែកក្នុងការលើកស្ទួយសុខុមាលភាព និងជីវិតប្រកបដោយផលិតភាព។*(ដកស្រង់គោលនយោបាយបំណិនជីវិត ២០០៦)*។

ការបង្រៀនបំណិនជីវិតនេះ ចង់ឱ្យសិស្សមើលឃើញសារប្រយោជន៍ និងផ្តល់សមត្ថភាពដល់ពួកគេក្នុងការៈ

- ជ្រើសរើសពូជមាន់ឱ្យបានសមស្រប
- រៀបចំទីកន្លែងចិញ្ចឹមមាន់ដោយសង់រោង និងរៀបចំទីធ្លាសម្រាប់មាន់ដើរលេង
- រៀបចំរណ្តៅធ្វើកំប៉ុស្តមាន់ សម្រាប់ឱ្យវាកាយរកចំណីបន្ថែម
- ផ្តល់វ៉ាក់សាំងឱ្យមាន់
- ចងក្រងជាមេរៀនអំពីការចិញ្ចឹមមាន់ដែលធ្លាប់បានអនុវត្តកន្លងមក។

## ២. ការត្រៀមលក្ខណៈមុនពេលបង្រៀន

ម៉ូឌុលនេះចែកចេញជាច្រើនផ្នែកផ្សេងៗគ្នា ដែលមានគោលបំណងខុសៗគ្នា។ ការត្រៀមលក្ខណៈមុនពេលបង្រៀនសិស្ស ជាដំណាក់កាលត្រៀមរបស់គ្រូ។ ព័ត៌មានទាក់ទងទៅនឹងការបង្រៀននិងរៀន ពិសេសមេរៀនត្រូវបានគ្រូត្រៀម ទុកជាមុន។

### ● សម្ភារឧបទេស

សម្ភារឧបទេសភាគច្រើនជាសម្ភារៈមូលដ្ឋានដូចជា ប៊ិក ឬក្រដាស និងសម្ភារៈផ្សេងៗទៀត ដែលត្រូវផ្តល់ឱ្យសិស្សសម្រាប់អនុវត្តផ្ទាល់ ដោយជូនភ្ជាប់នៅតាមមេរៀននីមួយៗ។ លើសពីនេះទៀត ក្នុងសៀវភៅនេះមានបន្ថែមឯកសារអ៊ុតសម្រាប់សិស្ស ក្នុងការពិភាក្សាក្រុមតូច ក្នុងមួយឈុត ២០ សន្លឹក។

### ● លទ្ធផលរំពឹងទុក

ផ្តល់ឃ្លាបញ្ជាក់នូវអ្វីនឹងសម្រេចបាន និងវាយតម្លៃនៅខាងចុងមេរៀន។ ឃ្លាទាំងនេះ ទាក់ទងនឹងគោលដៅរួមរបស់បំណិនជីវិត ដែលបានកំណត់នៅក្នុងគោលការណ៍ណែនាំបំណិនជីវិត នៅមធ្យមសិក្សាបឋមភូមិ ព្រមទាំងកំណត់នៅក្នុងបំណិនទាក់ទងសង្គម បំណិនសេដ្ឋកិច្ច និងបំណិនអាជីពងាយ។

### ● សញ្ញាសម្គាល់សម្រាប់សកម្មភាពនីមួយៗ

ខាងក្រោមនេះជាសញ្ញាសម្គាល់សកម្មភាពងាយៗ សម្រាប់គ្រូអនុវត្តបានជោគជ័យក្នុងការបង្រៀន និងរៀន។

ធ្វើសកម្មភាព ៖ គ្រូចាំបាច់ត្រូវដឹកនាំសិស្សធ្វើសកម្មភាព

សរសេរ ៖ ពេលខ្លះត្រូវការឱ្យលោកគ្រូ/អ្នកគ្រូសរសេរនៅលើក្តារខៀន

សួរ ៖ គ្រូរៀបចំសំណួរ

ពន្យល់ ៖ ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

### ● លំនាំបង្រៀន

មេរៀននីមួយៗចែកជា ៣ផ្នែក។ ផ្នែកទី១ គឺជាសេចក្តីផ្តើមដែលយើងព្យាយាមផ្សារភ្ជាប់ទៅនឹងចំណេះដឹង ដែលសិស្សមានស្រាប់ ឬរំឭកមេរៀនចាស់ ។ ផ្នែកទី២ យើងនឹងបង្រៀនសកម្មភាពសំខាន់ៗ ដោយផ្អែកលើវិធីសាស្ត្រ

បង្រៀនបែបការងារគម្រោង(ចុះស្រាវជ្រាវ ប្រមូលព័ត៌មាន សម្ភាស ចងក្រងឯកសារ និងបទបង្ហាញ...។) និងយុទ្ធវិធីបង្រៀនផ្សេងៗទៀត។ ផ្នែកទី៣ជាផ្នែកបញ្ចប់យើងអាចធានាបានថារាល់លទ្ធផលនៃការសិក្សារបស់យើង គឺបានឆ្លងកាត់នូវយុទ្ធវិធីខុសៗគ្នាជាច្រើន។ នៅចុងបញ្ចប់មេរៀន មានកិច្ចការសម្រាប់សិស្សយកទៅធ្វើនៅផ្ទះ ដើម្បីផ្សារភ្ជាប់ជាមួយមេរៀនថ្មី។

## ៣. ខ្លឹមសារសង្ខេប

ខ្លឹមសារសង្ខេបត្រូវបានផ្តល់ជូនឱ្យគ្រូក្នុងផ្នែកនេះ ដើម្បីជាទុនខ្លះក្នុងការបង្រៀន ហើយក៏ជាសញ្ញាណមួយជាក់លាក់បញ្ជាក់ពីទំនាក់ទំនង និងសារសំខាន់រវាងមេរៀននីមួយៗ ។

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបរួមទាំង ១០ មេរៀនដែលមាននៅក្នុងម៉ូឌុលបំណិនជីវិតៈ

| ចំណងជើងមេរៀន | ពេលវេលា | វត្ថុបំណង | ទំព័រ |
|---|---|---|---|
| ១: ការជ្រើសរើសទីកន្លែងចិញ្ចឹមមាន់ | ២ ម៉ោង | ស្វែងយល់អំពីកន្លែងចិញ្ចឹមមាន់ | ១ |
| ២: របៀបសង់ទ្រុងមាន់ | ២ ម៉ោង | កំណត់បានអំពីការសង់ទ្រុងមាន់ | ៤ |
| ៣: របៀបចិញ្ចឹមមាន់ | ២ ម៉ោង | អនុវត្តការចិញ្ចឹមមាន់នៅតាមផ្ទះ | ៨ |
| ៤: របៀបផ្សំចំណីមាន់ | ២ ម៉ោង | អាចផ្សំចំណីមាន់ | ១៣ |
| ៥: របៀបធ្វើកំប៉ុស្តមាន់ | ២ ម៉ោង | អនុវត្តការធ្វើកំប៉ុស្តមាន់បានដោយខ្លួនឯង | ១៨ |
| ៦: អនាម័យទ្រុងមាន់ | ២ ម៉ោង | យល់ដឹងពីការធ្វើអនាម័យឱ្យមាន់ | ២១ |
| ៧: ជ្រើសរើសមាន់ទុកចិញ្ចឹមបន្ត | ២ ម៉ោង | អាចកត់សំគាល់មាន់សម្រាប់ចិញ្ចឹមបន្ត | ២៥ |
| ៨: ការទម្លាក់ពូនមាន់ | ២ ម៉ោង | ស្វែងយល់ពីការទម្លាក់ពូនមាន់ | ៣០ |
| ៩: ជំងឺមាន់ | ២ ម៉ោង | អាចកត់សំគាល់មាន់មានជំងឺ | ៣៣ |
| ១០:ចំណេះដឹងក្នុងការចិញ្ចឹមមាន់ | ២ ម៉ោង | កំណត់បានពីលក្ខណៈទូទៅរបស់មាន់ | ៣៩ |

## ៤. ការវាយតម្លៃ

ការវាយតម្លៃមាន២ផ្នែកសំខាន់ៗ។ មួយផ្នែកជាការវាយតម្លៃនៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ និងជាវិញ្ញាសាសរសេរដែលយើងត្រូវបញ្ចូលនៅផ្នែកខាងចុង ម៉ូឌុល ។ ផ្នែកមួយទៀតជាការវាយតម្លៃទៅលើឥរិយាបថសិស្សដោយគ្រូជាអ្នកសង្កេតផ្ទាល់រៀងរាល់ថ្ងៃហើយដាក់ពិន្ទុ។ វិធីវាយតម្លៃទាំងពីរចំណុចនេះមានសារៈសំខាន់ក្នុងការវាស់ចំណេះដឹង និងឥរិយាបថរបស់សិស្សម្នាក់ៗ ។ ចំពោះការវាយតម្លៃសិស្សនេះយើងគិតពិន្ទុ ៥០ ស្មើទៅនឹងមុខវិជ្ជា មួយចំនួនផងដែរ គឺយើងឱ្យពិន្ទុ ៣៥ ទៅលើឥរិយាបថ និងពិន្ទុ ១៥ ទៅលើវិញ្ញាសាសរសេរ។

នៅតាមមេរៀននីមួយៗ គ្រូទុកពេលឱ្យសិស្សពិភាក្សាក្រុមតូចឱ្យបានច្រើន នៃចំណុចសំខាន់ៗនៅពាក់កណ្តាលមេរៀននីមួយៗ។ កំឡុងពេលសិស្សពិភាក្សាក្រុមតូច ជាពេលវេលាដែលគ្រូអាចសង្កេតឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។ ជាការល្អគ្រូគួរដាក់ពិន្ទុឥរិយាបថសិស្សចាប់ពីមេរៀនទី ៦ តទៅ។

## ៥. ឯកសារបន្ថែម

ផ្នែកនេះផ្តល់នូវព័ត៌មានរួមសម្រាប់គ្រូប្រើប្រាស់ រួមទាំងផ្ទាំងរូបភាពសម្រាប់គ្រូប្រើប្រាស់នៅក្នុងមេរៀននេះ។

# មេរៀនទី ១: ការជ្រើសរើសទីកន្លែងចិញ្ចឹមមាន់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធាន ដែលត្រូវការ

- ដីស ហ្វឺតសរសេរក្ដារខៀន
- ខ្សែ ម៉ែត្រ ចបកាប់ រនាស់ កាំបិត។ល។

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

១.សិស្សអាចយល់ដឹង អំពីកន្លែងចិញ្ចឹមមាន់

២.សិស្សនឹងអាចជ្រើសរើសទីកន្លែងបានសមស្រប។

**ចំណងជើងមេរៀនទី ១ៈការជ្រើសរើសទីកន្លែងៈ** 🕑 ៣០ នាទី

**សេចក្ដីផ្ដើមៈ**

សរសេរចំណងជើងមេរៀននៅលើក្ដារខៀន រួចគូសរង្វង់ជុំវិញចំណងជើងមេរៀន។ បន្ទាប់មកគ្រូសួរសិស្សហើយឱ្យសិស្សឡើងមកក្ដារខៀនម្នាក់ម្ដងៗ ដើម្បីសរសេរយោបល់របស់គេនៅជុំវិញចំណងជើងមេរៀន អំពីខ្លឹមសារសំខាន់ៗដែលមានទំនាក់ទំនងទៅនឹងមេរៀន។ ធ្វើរបៀបនេះ ដើម្បីឱ្យថ្នាក់រៀនមានសកម្មភាព និងឱ្យសិស្សមានភាពក្លាហានក្នុងការបញ្ចេញយោបល់ ។

ដើម្បីឱ្យការងារសម្រេចបានជោគជ័យ តើមានអ្នកណាខ្លះចូលរួមក្នុងការជ្រើសរើសកន្លែងចិញ្ចឹមមាន់ ?

គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន




ពន្យល់សិស្សថា យើងមានកម្មវិធីចញ្ចឹមមាន់នៅក្នុងសាលារៀន ដូច្នេះយើងត្រូវជ្រើសរើសទីកន្លែងចញ្ចឹមមាន់។
ទីកន្លែងសម្រាប់ចិញ្ចឹមមាន់គឺៈ ដីទួលស្រឡះមានធាតុអាកាសល្អ មានដើមឈើខ្លះៗ (មិនរាលពេកមិនស្រឡះពេក) ទីកន្លែងដែលត្រូវជ្រើសរើស ស្ថិតនៅមិនឆ្ងាយពីផ្លូវដើរ ជាកន្លែងមានសុវត្ថិភាព។

លោកគ្រូ/អ្នកគ្រូឱ្យក្រុមសិស្ស ពិនិត្យមើលទីធ្លាក្នុងសាលារៀន ដើម្បីកំណត់ទីតាំងចញ្ចឹមមាន់ តើជ្រើសរើសនៅកន្លែងណា?
ដូច្នេះ ដើម្បីឱ្យកាន់តែច្បាស់ យើងទៅមើលទីកន្លែងផ្ទាល់ទាំងអស់គ្នាឱ្យបាន ២ ឬ ៣ កន្លែងរួចយើងធ្វើការវាយតម្លៃប្រៀបធៀបមើល តើកន្លែងណាមួយវាសមស្របជាងគេ? ហើយយកម៉ែត្រ ខ្សែ កាំបិត និងពូថៅទៅជាមួយផង។

## សកម្មភាពសំខាន់។

🕑 ៤០ នាទី

គ្រូដឹកនាំសិស្សចុះទៅពិនិត្យជាក់ស្ដែងចំនួន ២ ឬ ៣ កន្លែង ហើយពិភាក្សាផ្ទាល់នៅទីនោះតែម្ដង។ កន្លែងដែលសម្រេចយកគឺៈ កត់ត្រាទុកក្នុងសៀវភៅ ឬក្រដាស់រ៉ាម
- កន្លែងមានសុវត្ថិភាព(ងាយស្រួលការពារ)
- ជិតប្រភពទឹក
- ជាដីមិនលិចទឹកនៅរដូវវស្សា
- ដីនៅមិនឆ្ងាយពីផ្លូវដើរ
- មានដើមឈើខ្លះៗ(ដើម្បីឱ្យមាន់ជ្រកម្លប់នៅពេលថ្ងៃ)

យកម៉ែត្រវាស់ទៅតាមទំហំដែលបានពិភាក្សា រួចបោះបង្គោលនិងចងខ្សែចំណាំទុក។ ហើយនាំសិស្សត្រឡប់ចូលថ្នាក់វិញ។ កំឡុងពេលសិស្សចុះពិនិត្យមើលកន្លែងចិញ្ចឹមមាន់គ្រូត្រូវសង្កេត ឥរិយាបថសិស្សក្នុងការដាក់ពិន្ទុ។

## បញ្ចប់មេរៀន ៖

🕑 ២០ នាទី

ឱ្យសិស្សយកសៀវភៅកត់ត្រាចម្លើយខាងលើ និងសំណួរនៅលើក្ដារខៀន ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ត្រូវសាកសួរពីឪពុកម្ដាយ ឬជាមួយអ្នកជិតខាង។

សរសេរសំណួរនៅលើក្ដារខៀន(ឱ្យសិស្សយកទៅធ្វើនៅផ្ទះ)

តើកន្លែងចិញ្ចឹមមាន់ត្រូវមានសភាពដូចម្ដេច ដើម្បីឱ្យការចិញ្ចឹមមានលក្ខណៈសមស្រប?

តើត្រូវជ្រើសរើសទីកន្លែងដូចម្ដេចដើម្បីឱ្យការចិញ្ចឹមមាន់មានសុវត្ថិភាព?

បណ្តាំផ្ញើ
- ទីកន្លែងចិញ្ចឹមមាន់ រកដីទួល
- មានពន្លឺថ្ងៃចាំងចូលដល់ក្នុងទ្រុង
- ជាការល្អត្រូវមានសំណាញ់ព័ទ្ធជុំវិញដើម្បីកុំឱ្យមាន់ដើរសេរី ពិបាកក្នុងការតាមដានពេលមាន់មានជំងឺការព្យាបាលនិងផ្តល់វ៉ាក់សាំង។
- ងាយស្រួលក្នុងការសម្អាតទ្រុង
- សម្អាតដោយបាចកំបោរ ក្នុងរវាង ៣ ខែម្តង
- ផ្ទៃក្រឡាទ្រុង គិតមាន់ ៣ ក្បាលក្នុង ១ ម២
- ប្រសិនបើមានព្រៃ ត្រូវកាប់ឆ្ការឱ្យវាល ដើម្បីជៀសវាងសត្វពីព្រៃមកស៊ីមាន់។

## ល្បែងសិក្សា ៖ ទូកយើងលិចហើយ

🕑 10 នាទី

ឱ្យសិស្សទាំងអស់ឈរនៅកណ្តាលថ្នាក់ ដោយរុញតុទៅកៀនជញ្ជាំងទាំងអស់ ឬឈរនៅកណ្តាលវាលក៏បាន។ មានសិស្សម្នាក់ឈរនៅកណ្តាលក្នុងចំណោមសិស្សទាំងអស់នោះ ជាអ្នកបញ្ជា ។ បន្ទាប់មកសិស្សជាអ្នកបញ្ជានោះ ក៏ស្រែកឡើងថា "**ទូកយើងលិចហើយជិះបានតែ ៤នាក់ទេ**" ក្រោយមកសិស្សទាំងអស់ត្រូវរត់ទៅផ្តុំគ្នាត្រឹមតែ ៤ នាក់/១ក្រុម ហើយអ្នកបញ្ជាដើរត្រួតពិនិត្យមើល បើក្រុមណាមួយលើសឬខ្វះពីចំនួនខាងលើ ត្រូវដកចេញពីក្រុមធំមិនឱ្យលេងតទៅទៀតទេ រង់ចាំពិន័យនៅទីបញ្ចប់ ។ បន្ទាប់មកអ្នកបញ្ជាក៏ស្រែកម្តងទៀតថា "**ទូកយើងលិច ហើយជិះបានតែ ៥នាក់ទេ**" អ្នកដែលឈរជាក្រុមពីមុន ត្រូវរំសាយហើយរត់ទៅផ្តុំជាក្រុម៥នាក់/ក្រុម ហើយអ្នកបញ្ជា ដើរមើលបើក្រុមណាលើសឬខ្វះចំនួននោះ ត្រូវដកចេញឈប់ឱ្យលេងរង់ចាំពិន័យ។ បន្ទាប់មកទៀតអ្នកបញ្ជាក៏ស្រែកឡើងដូចមុនដែរ តែដូរចំនួនសិស្សក្នុង ១ ក្រុម ហើយអ្នកផ្សេងក៏ធ្វើដូចមុនដែរ គឺឈរទៅតាមចំនួនរបស់អ្នកបញ្ជា។ ការធ្វើរបៀបនេះ ឱ្យបានពី ៤ ទៅ ៥ ដងទើបឈប់។

នៅទីបញ្ចប់អ្នកបញ្ជាត្រូវសួរទៅក្រុមធំថា តើត្រូវពិន័យអ្វីទៅលើអ្នកដែលចាញ់ បន្ទាប់មកអ្នកទាំងនោះក៏ឆ្លើយឡើងថា: សុំឱ្យច្រៀង សុំឱ្យរាំ ឬធ្វើសកម្មភាពផ្សេងៗ... ហើយអ្នកដែលចាញ់ទាំងនោះត្រូវធ្វើទៅតាមសំណូមពររបស់ក្រុមដែលទទួលជោគជ័យ។

លុះដល់ពិន័យចប់ហើយ ទើបឱ្យសិស្សទាំអស់ចូលអង្គុយតាមកន្លែងរៀងខ្លួនវិញ។ សូមបញ្ជាក់ថាល្បែងនេះគេយកមកលេង ភាគច្រើននៅពេលដែលចាប់ផ្តើមថ្ងៃបើកវគ្គដំបូង ដើម្បីបង្កើនភាពស្និទ្ធស្នាល ពីព្រោះថ្ងៃបើកវគ្គដំបូងនេះសិក្ខាកាមមិនទាន់ស្គាល់គ្នាជិតស្និទ្ធទេ។

# មេរៀនទី ២: របៀបសង់ទ្រុងមាន់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន ( តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធាន ដែលត្រូវការ

- ដីស ហ្វឺតសរសេរក្តារខៀន
- កាំបិត ពូថៅ ដែកគោល ឬស្សី ម៉ែត្រ ។ល។
- សន្លឹកអ៊ុតទី ១ ( ការចិញ្ចឹមមាន់ )

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- កំណត់ពីទំហំទ្រុងមាន់ដែលត្រូវសាងសង់គឺ ៣ក្បាល/ម២
- ស្វែងយល់ពីអត្ថប្រយោជន៍របស់ទ្រុងមាន់ និងសង់ទ្រុងមាន់បានដោយខ្លួនឯង

## រំឭកមេរៀនទី ១

🕑 ១០ នាទី

✋ ពិនិត្យមើលវត្តមានរួច ប្រមូលកិច្ចការសិស្សមកកែ

លោកគ្រូ អ្នកគ្រូពិភាក្សាសំណួរជាមួយសិស្សដូចខាងក្រោម៖

❓ តើកន្លែងចិញ្ចឹមមាន់ត្រូវមានសភាពដូចម្តេច ដើម្បីឱ្យការចិញ្ចឹមមានលក្ខណៈសមស្រប ?

សិស្សនាំគ្នាឆ្លើយ:

ទីកន្លែងសម្រាប់ចិញ្ចឹមមាន់គឺ: ដីទួល ស្រឡះ ជាតុអាកាសល្អ មានដើមឈើខ្លះៗ(មិនវាលពេកមិនស្រឡះពេក)

ទីកន្លែងដែលត្រូវជ្រើសរើស ស្ថិតនៅមិនឆ្ងាយពីផ្លូវដើរ ជាកន្លែងមានសុវត្ថិភាព។

តើត្រូវជ្រើសរើសទីកន្លែងដូចម្តេចដើម្បីឱ្យការចិញ្ចឹមមាន់មានសុវត្ថិភាព ? សិស្សឆ្លើយ:

- កន្លែងមានសុវត្ថិភាពគឺ:
- ជិតប្រភពទឹក
- ជាដីមិនលិចទឹកនៅរដូវវស្សា
- ដីនៅមិនឆ្ងាយពីផ្លូវដើរ
- មានដើមឈើខ្លះៗ( ដើម្បីឱ្យមាន់ជ្រកម្លប់នៅពេលថ្ងៃ )

**ចំណាងជើងមេរៀនទី ២: របៀបសង់ទ្រុងមាន់** ⌚ ៤០ នាទី

ថ្ងៃនេះរៀនពីរបៀបសង់ទ្រុងមាន់: គ្រូឱ្យសិស្សគូររូបតាមការនឹកឃើញអំពីទ្រុងមាន់



✋ ចែកសន្លឹកអុិតទី ១ ដល់សិស្សទាំងអស់ពិនិត្យមើលលំនាំសាងសង់ទ្រុងមាន់

◈ តើការសង់ទ្រុងមាន់ត្រូវធ្វើនៅលើទីតាំងមានលក្ខណៈដូចម្តេច?

គួរសង់ទ្រុងនៅលើដីទួលដែលមានខ្យល់ចេញចូលបានល្អ មិនសើម មិនលិចទឹក និងមិនឆ្ងាយពីផ្ទះ តែមិនឱ្យជាប់និងផ្ទះទេ។ ទ្រុងមាន់ត្រូវតែមានដំបូល និងជញ្ជាំងការពារកំដៅ និងភ្លៀងឱ្យបានល្អព្រមទាំងរៀបចំឱ្យមានធ្នើរសម្រាប់ ដាក់សំបុកឱ្យមាន់ពង និងទ្រនំសម្រាប់ឱ្យមាន់ដេក ផ្សេងពីកន្លែងពង។

តើការសាងសង់ទ្រុងមាន់មានអត្ថប្រយោជន៍អ្វីខ្លះ?

ការសាងសង់ទ្រុងមាន់មានអត្ថប្រយោជន៍ដូចជាៈ

- មាន់ក្រាបពង និងភ្ញាស់កូនទទួលផលបានល្អ
- ងាយស្រួលក្នុងការសម្អាត និងធ្វើអនាម័យ
- កាត់បន្ថយនៅពេលដែលមាន់ឡើងទ្រនំវាប៉ះទង្គិចគ្នា
- កាត់បន្ថយនូវជំងឺផ្សេងៗ
- ងាយស្រួលក្នុងការប្រមូលលាមកសម្រាប់យកមកធ្វើជី
- កាត់បន្ថយការបាត់បង់ដោយចោរលួច ឬសត្វស៊ី (ឆ្កែ ស្កា សំពោច...)
- ងាយស្រួលក្នុងការចាប់មាន់យកមកចាក់វ៉ាក់សាំង
- ងាយស្រួលក្នុងការតាមដានជំងឺ និងព្យាបាល(ទម្លាក់ព្រូន)
- ងាយស្រួលក្នុងការចាប់យកទៅលក់ ដូច្នេះបើចង់ចិញ្ចឹមមាន់ ចាំបាច់ត្រូវធ្វើទ្រុងឱ្យវា។

◈ តើរបៀបសង់ទ្រុងមាន់ត្រូវមានសភាពដូចម្តេច?

របៀបសង់ទ្រុងមាន់ត្រូវមានសភាពដូចខាងក្រោមៈ

- ទ្រុងមាន់សង់បណ្តោយថ្ងៃ ពីកើតទៅលិច(បើអាចធ្វើបាន)
- ទ្រុងគួរមានកំពស់ ១២០ស.ម និងត្រូវមានជញ្ជាំង និងដំបូលសម្រាប់ការពារកំដៅថ្ងៃ ភ្លៀង

- គួរមានកន្លែងដេក នៅផ្សេងពីកន្លែងពង និងកន្លែងរស់នៅ
- កម្រាលរនាបធ្នើរឱ្យមាន់ដេកឃ្លាតពីគ្នា ២-៣ សម ស្ថិតនៅខ្ពស់ពីដី ហើយមិនត្រូវដាក់សំបុកពីក្រោមឡើយ
- នៅជុំវិញទ្រុង គួរតែដាំល្ហុងប្រេងដើម្បីធ្វើជាម្លប់ និងផ្លែជ្រុះមកដីបានមាន់កាយស៊ី។

តើត្រូវរៀបចំទ្រុងមាន់មានលក្ខណៈដូចម្ដេចខ្លះ?
ទ្រុងមាន់ត្រូវរៀបចំឱ្យស្អាត(ស្ងួត មានដំបូល មានជញ្ជាំង)មានធ្នើរ ឬបង្គងសម្រាប់ឱ្យវាទុំដេក ហើយជៀសវាង មិនឱ្យវាដេកពីលើ ឬពីក្រោមគ្នាឡើយ ដែលជាហេតុបណ្ដាលនាំឱ្យឆ្លងជំងឺ។

តើការរៀបចំសំបុកឱ្យមាន់ពងត្រូវធ្វើដូចម្ដេច?
មេមាន់ក្នុងស្រុក ត្រូវការរៀបចំសំបុកឱ្យវាពង៖
- សំបុកអាចរៀបជាថ្នាក់ៗ តែត្រូវមានជញ្ជាំងខ័ណ្ឌ ដើម្បីកុំឱ្យវាចឹកគ្នា ។
- មេមាន់ក្រាបនៅពេលដែលវាពងបានចំនួន ៨-១២ ពងរយៈ ២១ថ្ងៃទើបញាស់។
- សំបុកត្រូវធ្វើមុននៅពេលមាន់រកពង ។
- សំបុកត្រូវធ្វើពីរបស់ដែលស្ងួតដូចជា ស្លឹកចេក ចំបើង រុំជារង្វេលដាក់ក្នុងធុង បង្គី ឬឡាំង
- សំបុកដែលសមស្របតាមបច្ចេកទេសត្រូវមានទទឹង ៣០ សម បណ្ដោយ ៤០ សម និងកំពស់ ៤០ សម ដាក់ភ្ជាប់ទៅនឹងជញ្ជាំង។

គ្រូពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់ថា៖
ការសាងសង់ទ្រុងមាន់មានច្រើនរបៀប អាស្រ័យទៅតាមគោលបំណង និងធនធានរបស់អ្នកចិញ្ចឹម។ គេអាចសង់ទ្រុងមាន់អំពីសម្ភារៈ ដែលមានស្រាប់នៅក្នុងមូលដ្ឋានដូចជា កូនឈើ ឬស្សី ស្លឹកត្នោត វល្លិ/រំពាក់ ស្បូវ ។ល។ សម្ភារៈទាំងនេះងាយស្រួលរក ហើយចំណាយប្រាក់អស់តិចតួចទៀតផង ។

## សកម្មភាពសំខាន់។ ៣០ នាទី

យកម៉ែត្រវាស់ និងបោះបង្គោលដែលយើងបានកំណត់រួចជាស្រេច។
បណ្ដោយ ៦ ម៉ ទទឹង ៤ ម និងកំពស់ ១.២០ ម
ចូលរួមសាងសង់ទ្រុងមាន់ជាមួយសិស្ស ដើម្បីអនុវត្តឱ្យបានត្រឹមត្រូវ។

## បញ្ចប់មេរៀន ១០ នាទី

សិស្សទាំងអស់យកសៀវភៅកត់ត្រាខ្លឹមសារមេរៀននិងសំណួរនៅលើក្ដារខៀន។ បន្តសាងសង់នៅថ្ងៃបន្ទាប់ រៀបចំឱ្យហើយស្រេច ទើបយកមាន់មកដាក់។

១. តើរបៀបសង់ទ្រុងមាន់ត្រូវមានសភាពដូចម្ដេច?
២. តើត្រូវរៀបចំទ្រុងមាន់មានលក្ខណៈដូចម្ដេចខ្លះ?

បណ្ដាំផ្ញើៈ
- បើចិញ្ចឹមមាន់ ចាំបាច់ត្រូវធ្វើទ្រុង ព្រោះងាយស្រួលតាមដាន អាចដាក់បាន ៥ក្បាលក្នុង១ម៉ែត្រការ៉េ
- កន្លែងចិញ្ចឹមត្រូវមានម្លប់ សម្រាប់ឱ្យមាន់ជ្រកនៅពេលថ្ងៃ នឹងដាំល្ហុងប្រេងនៅក្បែរនោះ ជាការល្អ ប្រសើរ។

ការវាយតម្លៃ:

- តើការសង់ទ្រុងមាន់ មានសភាពដូចម្តេច?
- ហេតុអ្វីបានជាយើងរៀបចំកន្លែងឱ្យមាន់ដេក នៅផ្សេងពីកន្លែងមាន់ពង?
- តើក្នុង ១ ម៉ែត្រការ៉េ អាចដាក់មាន់ចិញ្ចឹម(មាន់ស្រុក)បានប៉ុន្មានក្បាល?
- តើការសង់ទ្រុងមាន់មានសារប្រយោជន៍អ្វីខ្លះ?

**ល្បែងសិក្សា: ល្បែងរារបង្គង** ១០ នាទី

ឱ្យសិស្សទាំងអស់ឈរជារង្វង់មូល នៅក្នុងថ្នាក់ ឬនៅក្រៅថ្នាក់ក៏បាន ហើយជ្រើសរើសអ្នកស្ម័គ្រចិត្តចំនួន១នាក់ មកឈរនៅកណ្តាល ក្នុងចំណោមសិស្សទាំងអស់។ បន្ទាប់មកយកក្រមាចងមុខ ១ នាក់នោះឱ្យជិត(មិនឱ្យមើលឃើញទេ) រួចហើយឱ្យសិស្សម្នាក់ដែលចងមុខនោះ ដើររាវរកអ្នកដែលឈរនៅជុំវិញ បើចាប់បានអ្នកណាមួយត្រូវយកក្រមាពីអ្នកមុនមកចងមុខអ្នកថ្មីវិញម្តង ហើយដើររាវរកចាប់អ្នកដែលឈរជុំវិញដូចមុនដដែល។ ផ្ទុយទៅវិញបើអ្នកចងមុខនោះចាប់គេមិនបានទេ នៅធ្វើសកម្មភាពរហូតដល់ឈប់លេង។



រូបទ្រុងមាន់





រូបសំបុកមាន់

# មេរៀនទី ៣: របៀបចិញ្ចឹមមាន់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើល ព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារណែនាំសម្រាប់គ្រូ កិច្ចតែងការ កាលវិភាគប្រចាំថ្ងៃ
- សៀវភៅសិស្ស ជាជម្រើសដែលគ្រូត្រូវការប្រើបើចាំបាច់។
- ដីស ហ្វឺតសរសេរក្តារខៀន

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- អនុវត្តការចិញ្ចឹមមាន់ដោយខ្លួនឯង
- ស្វែងយល់ពីរបៀបថែរក្សាមាន់បានល្អ

**រំឭកមេរៀនទី ២: របៀបសង់ទ្រុងមាន់** 🕑 ១០ នាទី

លោកគ្រូ/អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោម៖

◈ តើរបៀបសង់ទ្រុងមាន់ មានសភាពដូចម្តេច? សិស្សនាំគ្នាឆ្លើយ:

របៀបសង់ទ្រុងមាន់មានសភាពដូចខាងក្រោម:

- ទ្រុងមាន់សង់បណ្តោយថ្ងៃ ពីកើតទៅលិច(បើអាចធ្វើបាន)
- ទ្រុងគួរមានកំពស់ ១២០ស.ម និងត្រូវមានជញ្ជាំង និងដំបូលសម្រាប់ការពារកំដៅថ្ងៃ ភ្លៀង
- កម្រាលរនាបធ្មើរឱ្យមាន់ដេកឃ្លាតពីគ្នា ២-៣ សម ស្ថិតនៅខ្ពស់ពីដី ហើយមិនត្រូវដាក់សំបុកពីក្រោមឡើយ។
- នៅជុំវិញទ្រុងគួរតែដាំល្ហុងប្រេង ដើម្បីធ្វើជាម្លប់ និងពេលផ្លែជ្រុះមកដីអាចបានជាចំណីមាន់។

តើត្រូវរៀបចំទ្រុងមាន់ឱ្យមានលក្ខណៈដូចម្តេចខ្លះ? សិស្សនាំគ្នាឆ្លើយ:

ទ្រុងមាន់ត្រូវរៀបចំឱ្យស្អាត(ស្ងួត មានដំបូល មានជញ្ជាំង) មានធ្មើរឬបង្គងសម្រាប់ឱ្យវាទុំដេក ហើយជៀសវាងមិនឱ្យដេកលើឬក្រោមគ្នាឡើយ។ គួររៀបចំកន្លែងដេក នៅផ្សេងពីកន្លែងពង។

## ចំណងជើងមេរៀនទី៣: របៀបចិញ្ចឹមមាន់

⏲ ៤០ នាទី

### សេចក្តីផ្តើម

សរសេរចំណងជើងមេរៀនលើក្តារខៀន រួចគូសរង្វង់ជុំវិញចំណងជើងមេរៀន ។ បន្ទាប់មកគ្រូសួរសិស្សហើយឱ្យសិស្សឡើងមកក្តារខៀនម្នាក់ម្តងៗ ដើម្បីសរសេរយោបល់របស់គេនៅជុំវិញចំណងជើងមេរៀន អំពីខ្លឹមសារសំខាន់ៗដែលមានទាក់ទងនឹងមេរៀន ។ ធ្វើរបៀបនេះដើម្បីឱ្យថ្នាក់រៀនមានសកម្មភាព និងឱ្យសិស្សមានភាពក្លាហាន ក្នុងការបញ្ចេញយោបល់ ។

◈ តើការចិញ្ចឹមមាន់ ត្រូវការសម្ភារៈអ្វីខ្លះ?

គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន




តើរបៀបផ្តល់ចំណីឱ្យមាន់មានប៉ុន្មានយ៉ាង?

ការផ្តល់ចំណី

ចំណីគ្រប់គ្រាន់មានន័យថាមាន់ស៊ីឆ្អែត ហើយមានគុណភាពស្របទៅតាមតម្រូវការសម្រាប់លូតលាស់ និងការរស់នៅ។ជាទូទៅមាន់ជំទង់ ១ ក្បាល ត្រូវការបរិមាណចំណីសរុបប្រហែល ១០០ក្រ ក្នុង១ ថ្ងៃ ។នៅពេលមាន់មានអាយុពី ១-១៥ ថ្ងៃដំបូង គួរផ្តល់ចំណី ៤-៥ ដងក្នុង១ថ្ងៃ លុះដល់ក្រោយមក អាចបន្ថយមកនៅត្រឹម ២-៣ដងវិញក្នុង១ថ្ងៃ។

ចំពោះកូនមាន់ដែលទើបនឹងញាស់ភ្លាមត្រូវបង្អត់អាហារវារយៈពេលយ៉ាងតិចបំផុត១២ម៉ោងព្រោះក្នុងខ្លួនរបស់វានៅមានសារជាតុនៃ ស៊ុតពណ៌លឿងដែលជាចំណីបម្រុងសម្រាប់ចិញ្ចឹមជីវិតនៅឡើយ។ ប្រសិនបើយើងរហ័សផ្តល់ចំណីឱ្យវាស៊ីពេកនោះបណ្តាលឱ្យវាអួលចំណីស្លាប់។ ចំណីសម្រាប់កូនមាន់ជាចំណីដែលងាយស្រួលលាយម៉ដ្ឋគ្រាប់ល្អិតៗ ដូចជា: កន្ទក់ ចុងអង្ករ ពោតកិន ជាដើម ។

ចំណីសម្រាប់មាន់គួរដាក់នៅក្នុងស្នូក៍ហើយលាយចូលគ្នានូវប្រភេទចំណីជាតិអង្ករជាតិសាច់ជាតិបន្លែបៃតងនិងអំបិលបន្តិចផង " ។ អ្នកចិញ្ចឹមគួរផ្លាស់ប្តូរទម្លាប់ ពីការឱ្យស្រូវ អង្ករដោយបាចឱ្យស៊ីចំណី ទៅជាអាហារលាយផ្សំរួចស្រេចដូចជា ចុងអង្ករ បន្លែពណ៌បៃតង គ្រក្ងន/ចកបាយទាវិញ ព្រោះវាអាចជួយសន្សំ ក៏ដូចជាកាត់បន្ថយនូវការចំណាយរបស់អ្នកទៅលើចំណី ហើយវាក៏អាចជួយឱ្យមាន់របស់អ្នកមានការលូតលាស់ឆាប់រហ័ស និងមានសុខភាពល្អ។ យើង អាចប្រើប្រាស់បរិមាណ អង្ករ/ចុងអង្ករ ស្រូវឬកន្ទក់ស្មើនឹងបរិមាណបន្លែសម្រាប់ផ្តល់ឱ្យមាន់ធំ។

- ការចិញ្ចឹមមាន់មាន ២ របៀប

១. ចំពោះកូនមាន់: មាន ២របៀបគឺ ដោយមេបណ្តើរកូន និងតាមរបៀបធ្វើអាជីវកម្ម ។

- ចិញ្ចឹមដោយមេបណ្ដើរៈមេមាន់ក្នុងស្រុកជួយកូនវាក្នុងការរកចំណីការពារមានភ្លៀងខ្យល់ការពារសត្វដទៃទៀតមកយាយីកូនរបស់វា ពេលកូនមានអាយុពី ៣-៤ ខែ មេមាន់ឈប់បណ្ដើរកូនរួចចាប់ផ្ដើមពងសាជាថ្មី ។

- នៅពេលដែលកូនលើកក្រោយមានអាយុ១ឬ២ថ្ងៃយើងប្រមូលផ្ដុំតាមរបៀបធ្វើអាជីវកម្មវិញប្រសើរជាងចំពោះកូនមាន់ត្រូវមានភ្លើងជួយជាកំដៅឱ្យវាផង។ ធ្វើរបៀបនេះមេមាន់ឆាប់រកឈ្មោល និងពងបន្តទៀត។

២.ចំពោះមាន់ជំទង់: ចាប់ពីកូនមាន់អាយុបាន២ខែឡើងទៅមិនត្រូវការកំដៅទៀតឡើយ។ លក្ខណៈញីឈ្មោលក៏បង្ហាញឱ្យឃើញច្បាស់ថា មាន់ឈ្មោលភាគច្រើនឆាប់ធំជាងមាន់ញី។ ពេលនេះត្រូវបំបែកការចិញ្ចឹមមាន់ញីចេញពីមាន់ឈ្មោល (ចំពោះការចិញ្ចឹមពូជមាន់បរទេស ឬចិញ្ចឹមទុកពូជ)។ ប៉ុន្ដែបើចិញ្ចឹមមាន់យកសាច់វិញអាចចិញ្ចឹមរហូត ដល់ ១០-១២ សប្ដាហ៍ ដែលធំល្មមអាចលក់បាន។

- ការចិញ្ចឹមរបៀបធ្វើអាជីវកម្មៈ ត្រូវមានអនាម័យ មានរាំងសាំងការពារ និងចំណីផ្សំទៅតាមបច្ចេកទេសទីកន្លែងស្រឡះមានខ្យល់ចេញចូលសមស្រប ។

-តើរៀបចំកន្លែងក្រៅទ្រុងដូចម្ដេច? នៅក្នុងទ្រុងមាន់ត្រូវបោសសម្អាត ឱ្យបានញឹកញាប់ ជៀសវាងកើតស្រមើលនិងជំងឺផ្សេងៗ។ ចំណែកឯនៅខាង ក្រៅទ្រុងវិញ ត្រូវជីករណ្ដៅនិងដាក់សំរាមធ្វើជាកំប៉ុស្ដមាន់ ពីព្រោះមាន់ចូលចិត្តកកាយរកចំណីបន្ថែមតាមទីកន្លែងផ្សេងៗ។ ប្រសិនបើនៅជិតៗផ្ទះគ្មានកន្លែងឱ្យវាកាយទេ វានឹងដើរទៅឆ្ងាយពីផ្ទះដែលនាំឱ្យបាត់បង់ដោយ កត្តាផ្សេងៗ។ ដូច្នេះអ្នកគួររៀបចំកន្លែងឱ្យមាន់សម្រាប់កាយដែលហៅថា កំប៉ុស្ដមាន់។

- ស្នូកទឹក និងស្នូកចំណីៈ

នៅក្នុងទ្រុងឬក្បែរទ្រុង ត្រូវមានស្នូកទឹកនិងស្នូកចំណីសម្រាប់ដាក់ទឹក និងចំណីឱ្យបានស្អាតល្អ។ ពីព្រោះការឱ្យចំណីនៅលើដីវាងាយនឹងទទួលជំងឺផ្សេងៗជាពិសេសពពួកព្រូន។ស្នូកទឹកនិងស្នូកចំណីធ្វើពីបំពង់ឬស្សីកាត់ជាកង់ៗត្រូវឱ្យមានថ្នាំងនៅចុងសងខាង រួចយើងពុះនៅត្រង់សាច់កណ្ដាល ១ចំហៀងតែមិនឱ្យដាច់ថ្នាំងសងខាងឡើយដើម្បីជួយទប់ចំណីកុំឱ្យកំពប់។ នៅពេលដាក់ចំណីក្នុងស្នូក កុំឱ្យលើសពីពាក់កណ្ដាលស្នូក ជៀសវាងចំណីកំពប់ ។សម្រាប់មាន់ធំស្នូកទឹក និងស្នូកចំណី ត្រូវព្យួរនៅជញ្ជាំងទ្រុង ឱ្យផុតពីដីកំពស់ ១០ សម ។ មាន់ធំ ៤ក្បាលត្រូវការទឹកស្អាត ១លីត្រ ក្នុង ១ថ្ងៃ ។ ស្នូកទឹកនិងស្នូកចំណី សម្រាប់មាន់ធំនួន ១០ក្បាល គួរមានប្រវែង ១.៥០ម ត្រូវសម្អាតរាល់ថ្ងៃហើយ ឧស្សាហ៍ដាក់ទឹក បើកន្លែងនោះសើមពេកគួរតែប្ដូរទៅកន្លែងផ្សេង តែកុំប្ដូរឱ្យឆ្ងាយលើសពី ៣-៥ម ពីកន្លែងដើម ។ នៅរដូវប្រាំង ចំពោះទឹកត្រូវត្រាំសំបកគរ ស្ដៅ វល្លិពេជ្រ ។ល។ ដើម្បីការពារជំងឺដែលនឹងអាចកើតមានដូចជាៈ អាសន្នរោគ ទល់លាមក ជាដើម។

👄 ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់:

បច្ចេកទេសចិញ្ចឹមមាន់តាមធម្មជាតិ ជាការអនុវត្តដោយបានប្រមូលផ្ដុំ នូវទម្លាប់ចិញ្ចឹមតាមយថាផលនិងបច្ចេកទេសសាមញ្ញៗ ដើម្បីឱ្យមាន់មានសុខភាពល្អ លូតលាស់បានលឿន និងមិនសូវមានការបាត់បង់។ តាមរយៈការចិញ្ចឹមនេះ យើងបានចំណាយថវិកាតិចតួចបំផុត លើការប្រើប្រាស់នូវធនធាន ពូជមាន់ ចំណី និងថ្នាំការពារ។

នៅពេលមាន់រកពងយើងរៀបចំសំបុកឱ្យមេមាន់គ្រប់ៗក្បាល ដោយដាក់ថ្នាំជក់ឬស្លឹកស្ដៅនៅបាតសំបុកដើម្បីការពារស្រមើល ។

- ពេលមាន់ក្រាប ឧស្សាហ៍បង្វិលពង ដើម្បីឱ្យវាទទួលកំដៅស្មើគ្នា ពងទាំងនោះនឹងញាស់ស្មើគ្នាដែរ។
- នៅរដូវប្រាំងធ្វើសំបុកឱ្យស្តើង រដូវវស្សាត្រូវធ្វើសំបុកឱ្យក្រាស់ និងជ្រៅ
- ធ្វើអនាម័យសម្អាតទ្រុង ១ ថ្ងៃម្ដង ដើម្បីការពារកុំឱ្យមានជំងឺឆ្លង
- ទម្លាក់ព្រូនដោយប្រើស្លាខ្ចី ពុះជា ៨ ចម្រៀកបញ្ចុក ១ក្បាល ១ ចម្រៀកធ្វើរៀងរាល់ខែ។

- ពេលមាន់ចូលដេកអស់ ត្រូវសម្អាតស្នូកទឹក និងស្នូកចំណីរួចដាក់សាថ្មី ។
- ពិនិត្យតាមដានមើលមាន់ណាសង្ស័យថាឈឺ ត្រូវចាប់វាចេញ។
- ត្រាំទឹកសំបកគរ បណ្តូលពេជ្រ សំបកស្ពៅ គល់ស្លឹកគ្រៃ ស្លុវត្នោត និងមេថ្នាំទុកឱ្យមាន់ផឹក។

**សកម្មភាពសំខាន់។** ⌚ ៣០ នាទី

នៅសប្តាហ៍ក្រោយយើងរៀនអំពីផ្សំចំណីឱ្យមាន់ តែយើងដឹងថា តើត្រូវមានអ្វីខ្លះ? សូមតាមដានទាំងអស់គ្នា លោកគ្រូ អ្នកគ្រូបានសរសេរនៅលើក្រដាសមានពាក្យៈ ចុងអង្ករ អំបិល សំបកខ្យង/ខ្ចៅ ផ្លែស្លែង អំពិលទុំ បន្លែ ផ្លាស្ទីកកន្ទក់ ដុំថ្ម ... សរសេរឱ្យបានច្រើន ហើយឱ្យសិស្សរើសយកម្នាក់មួយៗ។ ក្រោយពីសិស្សរើសយកបានម្នាក់មួយរួចហើយបន្ទាប់មកគ្រូក៏ស្រែកថាផ្សំចំណីមាន់សិស្សកាន់ផ្ទាំងអក្សរ(ដែលអាចផ្សំចំណីឱ្យមាន់បាន) រត់ទៅផ្តុំគ្នាទាំងអស់គ្នាពិនិត្យមើល តើត្រឹមត្រូវឬទេ? ពិនិត្យរួចហើយមកកន្លែងដើមវិញ។ បន្ទាប់មក គ្រូស្រែកថា "មិនត្រូវការចំណីមាន់ទេ"

សិស្សកាន់ផ្ទាំងអក្សរ ដែលមាន់មិនអាចស៊ីបាននោះ រត់ទៅផ្តុំគ្នា រួចពិនិត្យមើល តើត្រឹមត្រូវដែរឬទេ?

ល្បែងនេះអាចលេងបានច្រើនសារ ដើម្បីឱ្យសិស្សមានការចងចាំ។

គ្រូដឹកនាំសិស្ស អនុវត្តជាក់ស្តែងដូចជាការផ្តល់ចំណី ទឹក រៀបចំសម្អាតកន្លែងកូនមាន់ កន្លែងមាន់ធំដេក កន្លែងមាន់ពង និងសម្អាតស្នូកទឹក ស្នូកចំណី។

**បញ្ចប់មេរៀន** ⌚ ១០ នាទី

ឱ្យសិស្សយកសៀវភៅកត់ខ្លឹមសារមេរៀន និងសំណួរនៅលើក្តារខៀនយកទៅមើល និងឆ្លើយនៅផ្ទះ ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ ត្រូវចេះសាកសួរឪពុកម្តាយ បងប្អូន ឬអ្នកជិតខាង។

សំណួរៈ ១. តើរៀបចំកន្លែងខាងក្រៅទ្រុងមាន់ដូចម្តេច?

២. តើការចិញ្ចឹមមាន់មានប៉ុន្មានរបៀប?

យកល្អគ្រូចាត់ចែងសិស្ស ជាពិសេសក្រុមប្រឹក្សាកុមារ រៀបចំពិនិត្យតាមដានថែទាំមាន់។ ជាពិសេសត្រូវពន្យល់សិស្សថា យើងត្រូវពិនិត្យមើលរៀងរាល់ថ្ងៃ។ ប្រសិនបើឃើញអ្វីមួយមិនល្អ ត្រូវតែបំពេញបន្ថែមភ្លាម បើមិនធ្វើដូច្នេះ មាន់នឹងអាចបាត់អស់។

ត្រូវរៀបចំសិស្សថែទាំ នៅថ្ងៃឈប់សម្រាកផងដែរ បើមិនធ្វើដច្នេះទេ កង្កែបនឹងបាត់អស់។

តារាងតាមដានការចិញ្ចឹមមាន់ៈ

| ថ្ងៃ | ច័ន្ទ | អង្គារ | ពុធ | ព្រហស្បត៍ | សុក្រ | សៅរ៍ | អាទិត្យ |
|---|---|---|---|---|---|---|---|
| ចំណី សល់ប៉ុន្មាន? | | | | | | | |
| សម្អាតស្នូកទឹក/ចំណី | | | | | | | |
| ដាក់ទឹក/ចំណី | | | | | | | |
| សម្អាតទ្រុងមាន់ | | | | | | | |
| ពិនិត្យជញ្ជាំង/ទ្វារ | | | | | | | |
| ពិនិត្យកំប៉ុស្តមាន់ | | | | | | | |
| ... | | | | | | | |

## ការណែនាំរបស់គ្រូៈ មេរៀនទី ៣

ការធំធាត់របស់មាន់ៈ

ក. ការធំធាត់ក្នុងស៊ុត

បន្ទាប់ពីពងចេញពីមេវា ត្រូវការរយៈពេល ២១ថ្ងៃសម្រាប់ធំធាត់(ច្រើនជាង ឬតិចជាង ៣ថ្ងៃ)។ កំដៅនឹងជួយ

ឱ្យមាន់ធំធាត់ក្នុងស៊ុតជាបន្តបន្ទាប់ៈ

ថ្ងៃទី ៤ : កកើតចំណុចខ្មៅ តែមិនអាចមើលឃើញ ប្រសិនបើស៊ុតបែក

ថ្ងៃទី ៧ : មើលឃើញសសៃឈាមជាច្រើននៅក្នុងដុំខ្មៅ

ថ្ងៃទី ៩ : សសៃឈាមជាច្រើនកើនឡើង និងដុំខ្មៅរីកធំ

ថ្ងៃទី ១២ៈ កកើតកូនទំហំប៉ុនកាក់ និងឃើញសសៃឈាមច្បាស់ជុំវិញ

ថ្ងៃទី ១៧ៈ មួយភាគបីនៅក្នុងស៊ុត កដុំខ្មៅជារូបរាងមាន់ច្បាស់លាស់

ថ្ងៃទី ២០ៈ ធំធាត់ពេញក្នុងស៊ុត

ថ្ងៃទី ២១ៈ ញាស់ចេញពីស៊ុត

ខ. ការធំធាត់របស់មាន់

ការរីកលូតលាស់របស់មាន់មាន ៥ដំណាក់កាលដូចជាស៊ុត ញាស់ មាន់ជំទង់ មាន់មេឬឈ្មោល និងមាន់ចាស។



### ល្បែងសិក្សា : ទេវតាថា

🕑 ១០ នាទី

ឱ្យសិស្សទាំងអស់ ឈរជារង្វង់មូល ហើយមានម្នាក់ឈរនៅកណ្តាលរង្វង់ ធ្វើជាទេវតា ហើយនិយាយថាៈ លើកជើងឆ្វេង អ្នកដែលឈរនៅជុំវិញត្រូវតែលើកជើងឆ្វេងតាមទេវតាថា ឱ្យលើកដៃស្តាំ ត្រូវតែលើកដៃស្តាំតាមទេវតាថា ឱ្យបែរមុខទៅឆ្វេង ត្រូវតែធ្វើតាមឱ្យដូចទេវតាថាទាំងអស់។ ចំពោះសកម្មភាព ដែលទេវតានិយាយឱ្យញាប់ គឺចង់ឱ្យធ្វើសកម្មភាពអ្វីក៏បានដែរ ដើម្បីឱ្យមានអ្នកខុស។

ផ្ទុយទៅវិញ បើមានអ្នកណាមួយធ្វើខុសពីទេវតានិយាយ គឺអ្នកនោះមានកំហុស ចាប់យកមកឱ្យឈរនៅក្នុងរង្វង់ ដើម្បីឱ្យជួយត្រួតពិនិត្យមើលអ្នកធ្វើខុសថែមទៀត។

លុះទេវតា ឱ្យធ្វើសកម្មភាពបាន ៦ ទៅ ៧ ដង អ្នកមានកំហុសត្រូវតែពិន័យ ឱ្យរាំ ឱ្យច្រៀង ឱ្យ...ទៅតាមសំណូមពរអ្នកឈរជុំវិញ ។ដើម្បីញ៉ាំងពិធីនេះឱ្យកាន់តែសប្បាយ អ្នកឈរជុំវិញច្រៀង អ្នកនៅកណ្តាលរាំ ឬអ្នកនៅកណ្តាលច្រៀងផងរាំផងក៏មានដែរ។

# មេរៀនទី ៤: របៀបផ្សំចំណីមាន់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ:

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធាន ដែលត្រូវការ

- ឯកសារណែនាំសម្រាប់គ្រូ កិច្ចតែងការ កាលវិភាគប្រចាំថ្ងៃ
- សៀវភៅសិស្សជាជម្រើសដែលគ្រូត្រូវការប្រើបើចាំបាច់
- ដីស ហ្វឺតសរសេរក្ដារខៀន
- កន្ទក់ម៉ដ្ឋ ចុងអង្ករ ពោតក្រហម សំបកខ្យងខ្ចៅបុក អំបិល។ល។
- ផូស្ទ័រវដ្តជីវិតនៃស៊ុតមាន់

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ផ្សំចំណីមាន់ដោយខ្លួនឯង
- ផ្ដល់ចំណី ទៅតាមប្រភេទមាន់។

**រំឭកមេរៀនទី ៣: របៀបចិញ្ចឹមមាន់** 🕑 ១០ នាទី

លោកគ្រូ/អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោម៖

◈ តើត្រូវរៀបចំកន្លែងខាងក្រៅទ្រុងមាន់ដូចម្ដេច? សិស្សនាំគ្នាឆ្លើយ:

ទីកន្លែងខាងក្រៅទ្រុងមាន់បានរៀបចំ:

នៅក្នុងទ្រុងមាន់ត្រូវបោសសម្អាតឱ្យបានញឹកញាប់ជៀសវាងកើតស្រមើលនិងជំងឺផ្សេងៗ។ ចំណែកឯនៅខាងក្រៅទ្រុងវិញ ត្រូវជីករណ្ដៅនិងដាក់សំរាមធ្វើជាកំប៉ុស្តមាន់ ពីព្រោះមាន់ចូលចិត្តកកាយរកចំណីបន្ថែមតាមទីកន្លែងផ្សេងៗ។ប្រសិនបើនៅជិតៗផ្ទះគ្មានកន្លែងឱ្យវាកាយទេវានឹងដើរទៅឆ្ងាយពីផ្ទះដែលនាំឱ្យបាត់បង់ដោយកត្តាផ្សេងៗ ។ ដូច្នេះអ្នកគួររៀបចំកន្លែងឱ្យមាន់សម្រាប់កាយ ដែលហៅថាកំប៉ុស្តមាន់។

◈ តើការចិញ្ចឹមមាន់មានប៉ុន្មានរបៀប? សិស្សនាំគ្នាឆ្លើយ:

ការចិញ្ចឹមមាន់មាន ២ របៀប:

១. ចំពោះកូនមាន់: មាន ២របៀប ដោយមេបណ្ដើរកូន និងតាមរបៀបធ្វើអាជីវកម្ម ។

- ចិញ្ចឹមដោយមេបណ្តើរៈ មេមាន់ក្នុងស្រុកជួយកូនវាក្នុងការរកចំណី ការពារមានភ្លៀងខ្យល់ ការពារសត្វដទៃទៀតមកយាយីកូនរបស់វា។ ពេលកូនមានអាយុពី ៣-៤ខែ មេមាន់ឈប់បណ្តើរកូនរួចចាប់ផ្តើមពងសាជាថ្មី។
- នៅពេលដែលកូនលើកក្រោយមានអាយុ ១ ឬ២ ថ្ងៃ យើងប្រមូលផ្តុំតាមរបៀបធ្វើអាជីវកម្មវិញប្រសើរជាង។ ចំពោះកូនមាន់ត្រូវមានភ្លើងជួយជាកំដៅឱ្យវាផង។ ធ្វើរបៀបនេះមេមាន់ឆាប់រកឈ្មោលនិងពងបន្តទៅទៀត ។

២. ចំពោះមាន់ជំទង់ៈ ចាប់ពីកូនមាន់អាយុបាន ២ ខែឡើងទៅ មិនត្រូវការកំដៅទៀតឡើយ ។ លក្ខណៈញីនិងឈ្មោល ក៏បង្ហាញឱ្យឃើញច្បាស់ថា មាន់ឈ្មោលភាគច្រើនឆាប់ធំជាងមាន់ញី។ ពេលនេះត្រូវបំបែកការចិញ្ចឹមមាន់ញីចេញពីមាន់ឈ្មោល (ចំពោះការចិញ្ចឹមពូជមាន់បរទេស ឬការចិញ្ចឹមទុកពូជ)។
ប៉ុន្តែបើចិញ្ចឹមមាន់យកសាច់វិញ អាចចិញ្ចឹមរហូតដល់ ១០-១២ សប្តាហ៍ ដែលធំល្មមអាចលក់បាន។

**ចំណងជើងមេរៀនទី ៤: របៀបផ្សំចំណីមាន់** ⏲ ៤០ នាទី

បិទផ្ទាំងផូស្ទ័រ វដ្តជីវិតរបស់ស៊ុតមាន់នៅលើក្តារខៀន រួចសួរសំណួរទៅសិស្សដូចខាងក្រោម

- លោកគ្រូ/អ្នកគ្រូ សួរសំណួរទៅសិស្ស
  តើវដ្តជីវិតរបស់ស៊ុតមាន់មានប៉ុន្មានថ្ងៃ?
- គ្រូសួរសំណួរទៅឱ្យសិស្ស ដែលទាក់ទង វដ្តជីវិតមាន់ បន្ទាប់មកឱ្យសិស្សឡើងពន្យល់នៅលើផ្ទាំងរូបភាព។
- តើអ្នកពិនិត្យមានប៉ុន្មានដំណាក់កាល?
  មាន ៨ ដំណាក់កាលនៅក្នុងរូបភាព






**របៀបផ្សំចំណីមាន់៖**

តើការធ្វើមេចំណីបំប៉ន និងមេថ្នាំបង្ការជំងឺ រៀបចំដូចម្តេច?

ការធ្វើមេចំណីបំប៉ន និងមេថ្នាំបង្ការៈ

ដើម្បីបង្កើនប្រសិទ្ធភាពនៃការលូតលាស់ និងធន់ទ្រាំទៅនឹងជំងឺឆ្លងផ្សេងៗ យើងអាចធ្វើមេចំណីនិងមេថ្នាំដើម្បី

បំប៉នមាន់របស់អ្នក។ ប្រភេទចំណី និងមេថ្នាំនេះ មានលក្ខណៈងាយស្រួលក្នុងការធ្វើ ដោយសារធាតុផ្សំងាយស្រួលរក ដូចជា បន្លែ ផ្លែឈើគ្រប់ប្រភេទ... ។ វិធីសាស្ត្រទូទៅសម្រាប់ផលិតមេនេះមានដូចតទៅៈ

- វត្ថុធាតុដើម
  - សារធាតុស្រស់មានៈ បន្លែស្រស់ មើមរុក្ខជាតិ ផ្លែឈើ។ល។ ចម្រុះគ្នាយក ៣ភាគ
  - ស្ករត្នោត ១ ភាគ
- វិធីសាស្ត្រអនុវត្ត
  - យកវត្ថុធាតុដើមទាំងអស់មកច្របល់ចូលគ្នាឱ្យសព្វ
  - ច្រកចូលក្នុងកែវ ឬធុងដែលមានគ្របបិទឱ្យជិត កុំឱ្យខ្យល់ចេញចូលបាន
  - រក្សាទុកក្នុងកន្លែងម្លប់រយៈពេលយ៉ាងតិច១៥ថ្ងៃ និងឧស្សាហ៍បើកបញ្ចេញខ្យល់១ថ្ងៃម្តងដើម្បីការពារកុំឱ្យផ្ទុះ ។
- វិធីប្រើ
  - នៅពេលធាតុផ្សំទាំងនោះកាច់បានល្អ វានឹងចេញជាតិហើយមានក្លិនឈ្ងុយ និងរសជាតិជូរប្រហែលក្រូចឆ្មារ។
  - យកមេដែលជាទឹកកកើតឡើងនៅក្នុងដបនោះមកលាយជាមួយនឹងទឹកឱ្យមាន់ផឹកឬលាយជាមួយចំណីឱ្យមាន់ស៊ីជារៀងរាល់ថ្ងៃ ដោយប្រើកម្រិត ១%។ ឧទាហរណ៍ៈ ក្នុងចំណី ១០០គក្រ ឬទឹក ១០០ លីត្រ យើងលាយជាមួយនឹងមេនោះ ១ លីត្រ។ បើចំណី ១ គក្រ ឬទឹក១ លីត្រ យើងលាយជាមួយនឹងមេនោះចំនួនតែ ១ សេសេទេ។

ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

តើរបៀបផ្សំចំណីឱ្យមាន់ មានរូបមន្តដូចម្តេច?

ការចិញ្ចឹមរបៀបធ្វើអាជីវកម្មៈ ចំពោះការផ្សំចំណីតាមរបៀបធ្វើអាជីវកម្មតាមរូបមន្តដូចខាងក្រោមៈ

| ប្រភេទចំណី | សម្រាប់កូនមាន់ % | សម្រាប់មាន់ពង % | សម្រាប់មាន់សាច់ % |
|---|---|---|---|
| កន្ទក់ម៉ដ្ឋ | ១០ | ២៩.៥ | ៣០.១៥ |
| ចុងអង្ករ | ១០.៨ | ៥ | ១០ |
| ពោតក្រហម | ៤២ | ៣០ | ៣០ |
| កាកសណ្តែកសៀង | ១២ | ១០ | ១០ |
| ត្រីបុក | ២០ | ២០ | ១៥ |
| សំបកខ្យង/ខ្ចៅ/លៀសបុក | ៤ | ៥ | ៤ |
| អំបិល | ០.២ | ០.៥ | ០.៥ |

ប្រសិនបើអ្នកចិញ្ចឹមពុំមានលទ្ធភាពទិញចំណីផ្សំស្រេចបាន ឬនៅតំបន់ដាច់ស្រយាល យើងអាចរកចំណីតាមធម្មជាតិដូចជាៈ

- ដើមដំឡូងជ្វា មើមត្រាវ ដើមដំឡូងមី ចិញ្ច្រាំឱ្យល្អិតហាលឱ្យស្ងួត ដើម្បីទុកបានយូរ
- បន្លែស្លឹកបៃតង ស្លឹកក្ដម្ពទេស ត្រកួន

- គ្រាប់សណ្ដែកបាយ គ្រាប់សណ្ដែកសៀង ចុងអង្ករ ពោត
- សត្វល្អិតតូចៗ ដូចជាៈ ដង្កូវ កណ្ដៀរ កណ្ដូប ស្រមោច ជន្លេន ។ល។
- ទឹកជាវត្ថុសំខាន់ណាស់ក្នុងការចិញ្ចឹមមាន់ ស្នូកចំណីនិងទឹកត្រូវឱ្យមានអនាម័យ។

រូបមន្តផ្សំចំណីឱ្យមាន់ដែលងាយបំផុតៈ

- គ្រាប់ពោតក្រហមកិន ឬចុងអង្ករ ៤ កំប៉ុង
- កន្ទក់ ១កំប៉ុង កន្លះ
- ម្សៅត្រី ១ កំប៉ុង
- កាកសាច់ដូងស្ងួត ១ កំប៉ុង កន្លះ
- ស្លឹកក្តម្ពទេស ១ កំប៉ុង
- អំបិល ១ ស្លាបព្រាបាយ
- សំបកគ្រំ លៀស បុកឱ្យម៉ដ្ឋ ១ ទូកដៃ (ច្របល់លាយចូលគ្នាឱ្យសព្វ រួចដាក់ឱ្យស៊ី)

**សកម្មភាពសំខាន់។** ៣០ នាទី

ទាំងអស់គ្នារៀបចំអនុវត្ត ផ្សំចំណីមាន់ទៅតាមរូបមន្តដែលបានពិភាក្សារួចហើយ។

គ្រូដឹកនាំសិស្ស អនុវត្តជាក់ស្តែងក្នុងការផ្សំចំណីមាន់ និងធ្វើមេថ្នាំសម្រាប់លាយជាមួយចំណី ដើម្បីឱ្យសិស្សងាយយល់និងងាយចងចាំ។

**បញ្ចប់មេរៀន** ១០ នាទី

ទាំងអស់គ្នាយកសៀវភៅកត់ខ្លឹមសារមេរៀន និងសំណួរនៅលើក្តារខៀនយកទៅមើល និងឆ្លើយនៅផ្ទះ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ ត្រូវចេះសាកសួរឪពុកម្តាយ បងប្អូន ឬអ្នកជិតខាង។

សំណួរៈ ១. តើការធ្វើមេចំណីបំប៉ន និងមេថ្នាំបង្ការជំងឺមានអ្វីខ្លះ?
២.តើរូបមន្តផ្សំចំណីឱ្យមាន់ដែលងាយបំផុតមានអ្វីខ្លះ?

បណ្តាំផ្ញើៈ ត្រូវចេះផ្សំចំណីណា ដែលងាយរកនៅក្នុងមូលដ្ឋាន។
ស្លឹកបន្លែពណ៌បៃតងមានសាសំខាន់ណាស់។ វាមានឥទ្ធិពលច្របាច់ពោះវៀន និងជួយរុញលាមកមកក្រៅ(ការពារជំងឺទល់លាមក) ម្យ៉ាងទៀតជាតិបន្លែ ការពារកុំឱ្យមាន់ចឹកស៊ីរោមគ្នាវា។

**ការណែនាំគ្រូៈ**

ដើម្បីរស់នៅ និងលូតលាស់បានល្អ មាន់ត្រូវការចំណីអាហារ សារធាតុចិញ្ចឹមនិងទឹកសម្រាប់ការលូតលាស់ដូចមនុស្សយើងដែរ។ ប្រភេទចំណីអាហារដែលមាន់ត្រូវការ មានទាំងអស់ ៤ក្រុមសំខាន់ៗៈ

**ក. ក្រុមអាហារជាតិសាច់ ឬប្រូតេអ៊ីន(អាហារសាងសង់)**

ជាតិសាច់មានតួនាទី ចាំបាច់សម្រាប់បង្កើត និងជួសជុលកោសិកាឱ្យរក្សាសកម្មភាពនៅធម្មតានិងដើម្បីបង្កើតពងពោមហើយវាជួយឱ្យមាន់មានការធំធាត់លឿន និងពងបានធំល្អ។ ប្រសិនបើគ្មានអាហារជាតិសាច់ទេ មាន់មិនអាចលូតលាស់ធំធាត់បានលឿន និងធន់ទ្រាំនឹងជំងឺបានល្អទេ។អាហារជាតិសាច់ ដែលមាននៅជុំវិញខ្លួនកសិករមានដូចជាៈជន្លេន ត្រី ម្សៅត្រី កំពឹស សាច់ខ្យង ពពួកសត្វល្អិតដូចជាៈ កណ្ដូប ចង្រិត មេភ្លៀង កណ្ដៀរ ដង្កូវ...។ ក្រៅពីអាហារទាំងនេះ ជាតិសាច់ក៏មាននៅក្នុងរុក្ខជាតិដែរ ដូចជាពពួកគ្រាប់ធុញ្ញជាតិ សណ្ដែកសៀង សណ្ដែកបាយ សណ្ដែកអង្គុយ សណ្ដែកអង្រែ។ល។

**ខ. ក្រុមអាហារផ្ដល់កំដៅ ឬឋាមពលៈ**

តួនាទីសំខាន់របស់ក្រុមអាហារកំដៅ គឺជួយបង្កើតកំដៅ ចូលរួមក្នុងចលនា ការរំលាយសំយោគអាហារនិងសម្របសម្រួលសកម្មភាព និងចលនាផ្សេងៗរបស់មាន់។ អាហារប្រភេទនេះមានដូចជាៈ ជាតិខ្លាញ់ ម្សៅ ស្ករ កាកដូង សណ្ដែកដី កន្ទក់ ពោត ស្រូវ ដំឡូងឈើ ដំឡូងជ្វា។ល។

**គ. ក្រុមអាហារជាតិរ៉ែៈ**

ជាតិរ៉ែសំខាន់ចាំបាច់ ក្នុងការជួយបង្កើតឆ្អឹង ឈាម ពោម និងសំបកពង។ អាហារប្រភេទនេះ បានមកពីសំបកខ្យង ខ្ចៅ គ្រំ លៀសបុក និងអំបិល...។ កាលណាមាន់ខ្វះជាតិរ៉ែ ជាពិសេសកាល់ស្យូមនឹងបណ្ដាលឱ្យឆ្អឹងទន់ស្ដោកងាយបាក់ ក្រិនមិនងាយធំ សំបកពងស្ដើងងាយបែក ឬរាកពង ហើយចឹកពងខ្លួនឯងស៊ី។

## ល្បែងសិក្សា : ខ្លែងចាប់កូនមាន់

🕑 ១០ នាទី

ចែកសិស្សជា ២ ក្រុម ឈរជាជួរ ដោយមេក្រុមនិងមេក្រុមឈរទល់មុខគ្នា ចម្ងាយពីគ្នាប្រហែល ៣ ម៉ែត្រ។ ក្រុមនីមួយៗ ឈរឱបចង្កេះគ្នាឱ្យជាប់ តាំងពីមេក្រុមរហូតដល់អ្នកនៅចុងក្រោយបង្អស់ អ្នកដែលឈរមុខគេគឺជាមេខ្លែងផងជាមេមាន់ផង ហើយអ្នកដែលនៅក្រោយគេបង្អស់គឺជាកូនមាន់ ។ មេក្រុមនេះ បើនៅក្នុងក្រុមខ្លួនឯងធ្វើជាមេមាន់ ប៉ុន្តែបើប្រឆាំងជាមួយក្រុមគេ គឺធ្វើជាមេខ្លែង។

ក្រោយពីបានរៀបចំរួចអ្នកទាំងអស់គ្នាស្រែកឡើងថា "ខ្លែងចាប់កូនមាន់" បន្ទាប់មកមេខ្លែងតាមក្រុមនីមួយៗ រិះរកទៅចាប់កូនមាន់នៅក្រុមគេឱ្យបានប៉ុន្តែមេក្រុមរបស់គេនោះក៏បានដើរតួជាមេមាន់ផងដើម្បីការពារកូនមាន់របស់គេនៅខាងក្រោយដែរ ដូច្នេះមេក្រុមនេះដើរចាប់កូនមាន់គេ និងការពារកូនមាន់ខ្លួនឯង។

សូមបញ្ជាក់ថានៅពេលធ្វើសកម្មភាព សមាជិកក្នុងក្រុមនីមួយៗ ឱបចង្កេះបន្តគ្នាឱ្យជាប់មិនឱ្យដាច់គ្នាទេប្រសិនបើក្រុមណាដាច់គ្នា មានន័យថាក្រុមនោះចាញ់គេហើយ។



# មេរៀនទី ៥: របៀបធ្វើកំប៉ុស្តមាន់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពត្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារណែនាំសម្រាប់គ្រូ កិច្ចតែងការ កាលវិភាគប្រចាំថ្ងៃ
- សៀវភៅសិស្សជាជម្រើសដែលគ្រូត្រូវការប្រើ បើចាំបាច់
- ដីស ហ្វឺតសរសេរក្តារខៀន
- ចបកាប់ បង្គី កាំបិត សម្រាម/កំទេចចំបើង/អង្កាម។ល។
- ជូស្ទ័រចិញ្ចឹមមាន់

☼ វត្ថុបំណង:

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- ស្វែងយល់ពីសារប្រយោជន៍នៃការធ្វើកំប៉ុស្តមាន់
- ចេះធ្វើកំប៉ុស្តមាន់ដោយខ្លួនឯង។

**រំឭកមេរៀនទី ៤: របៀបផ្សំចំណីមាន់** 🕑 ១០ នាទី

លោកគ្រូ/អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោម៖

⟐ តើការធ្វើមេចំណីបំប៉ន និងមេថ្នាំបង្ការជំងឺមានអ្វីខ្លះ? សិស្សនាំគ្នាឆ្លើយ:

វត្ថុធាតុដើមសម្រាប់ធ្វើមេចំណីបំប៉ន និងមេថ្នាំបង្ការជំងឺមាន:

- សារធាតុស្រស់មានៈ បន្លែស្រស់ មើមរុក្ខជាតិ ផ្លែឈើ។ល។ ចម្រុះគ្នាយក ៣ភាគ
- ស្ករត្នោត ១ ភាគ

តើរូបមន្តផ្សំចំណីមាន់ដែលងាយបំផុតមានអ្វីខ្លះ? សិស្សនាំគ្នាឆ្លើយ: រូបមន្តផ្សំចំណីមាន់ដែលងាយបំផុតមាន

- គ្រាប់ពោតក្រហមកិន ឬចុងអង្ករ ៤ កំប៉ុង
- កន្ទក់ ១ កំប៉ុង កន្លះ
- ម្សៅត្រី ១ កំប៉ុង
- កាកដូងស្ងួត ១ កំប៉ុង កន្លះ
- ស្លឹកក្ដម្ពទេស ១ កំប៉ុង អំបិល ១ ស្លាបព្រាបាយ
- សំបកគ្រំ លៀស បុកឱ្យម៉ដ្ឋ ១ ទូកដៃ (ច្របល់លាយចូលគ្នាឱ្យសព្វ រួចដាក់ឱ្យស៊ី)

## ចំណងជើងមេរៀនទី៥: របៀបធ្វើកំប៉ុស្តមាន់ ៤០ នាទី

### សេចក្តីផ្តើម

សរសេរចំណងជើងមេរៀននៅលើក្តារខៀនរួចគូសរង្វង់ជុំវិញចំណងជើងមេរៀន។ បន្ទាប់មកគ្រូសួរសិស្សហើយឱ្យសិស្សឡើងមកក្តារខៀនម្នាក់ម្តងៗដើម្បីសរសេរយោបល់របស់ គេនៅជុំវិញចំណងជើងមេរៀនអំពីខ្លឹមសារខានៗដែលទាក់ទងនឹងមេរៀន។ធ្វើរបៀបនេះដើម្បីឱ្យថ្នាក់រៀនមានសកម្មភាពនិងឱ្យសិស្សមានភាពក្លាហានក្នុងការបញ្ចេញយោបល់ ។

◈ តើរបៀបធ្វើកំប៉ុស្តមាន់ត្រូវការសម្ភារៈអ្វីខ្លះ ?

គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន




តើរៀបចំកំប៉ុស្តមាន់ដូចម្តេច ?

នៅក្នុងទ្រុងមាន់ត្រូវបោសសម្អាត ឱ្យបានញឹកញាប់ជៀសវាងកើតស្រមើលនិងជំងឺផ្សេងៗ។ ចំណែកឯងនៅក្រៅទ្រុងវិញ ត្រូវជីករណ្តៅ និងដាក់សំរាមធ្វើជាកំប៉ុស្តមាន់ ពីព្រោះមាន់ចូលចិត្តកកាយរកចំណីបន្ថែមតាមទីកន្លែងផ្សេងៗ។ ប្រសិនបើនៅជិតៗផ្ទះគ្មានកន្លែងឱ្យវាកាយទេវានឹងដើរទៅឆ្ងាយពីផ្ទះដែលនាំឱ្យបាត់បង់ដោយកត្តាផ្សេង។ ដូច្នេះអ្នកគួររៀបចំកន្លែងឱ្យមាន់សម្រាប់កាយ( កំប៉ុស្តមាន់ )ដូចតទៅ:

- ជ្រើសរើសកន្លែងមានម្លប់ឈើ ដើម្បីរៀបចំជាកន្លែងឱ្យមាន់កាយ។
- ជីករណ្តៅជម្រៅ ៣ សម ទំហំ ២ x ២ ម ជីកឱ្យបានច្រើនកន្លែង។
- ប្រមូលស្លឹកឈើ អង្កាមឬសារធាតុផ្សេងៗ ដាក់ក្នុងរណ្តៅ( ហាមដាក់លាមកសត្វ )បើនៅរដូវប្រាំងត្រូវស្រោចទឹកឱ្យសើមៗ ដើម្បីឱ្យសត្វល្អិតចូលនៅ នឹងក្លាយជាចំណីមាន់។
- ធ្វើរបងព័ទ្ធជុំវិញរណ្តៅ ឬយកបន្លាស្រះ ដើម្បីកុំឱ្យមាន់កាយសំរាមចេញពីរណ្តៅ។

បន្ទាប់ពីយើងដឹងថាមានសត្វល្អិតចូលនៅ យើងបើកបន្លាឱ្យមាន់វាកាយ។ រយៈ ២ឬ ៣ថ្ងៃក្រោយមករៀបចំរណ្តៅចាស់ឱ្យស្អាតដូចដើមវិញនិងស្រះបន្លាដដែលរួចទៅបើករណ្តៅថ្មីមួយទៀតឱ្យវាកាយធ្វើរបៀបនេះឱ្យបានជាបន្តបន្ទាប់

◈ តើការធ្វើកំប៉ុស្តមាន់មានសារប្រយោជន៍អ្វីខ្លះ ?

ការធ្វើកំប៉ុស្តអាចជួយឱ្យមាន់របស់អ្នកលូតលាស់លឿនតាមរយៈការស៊ីសត្វល្អិតដែលសម្បូរណ៍ទៅដោយជាតិសាច់និងជៀសវាងការបាត់ដោយប្រការផ្សេងៗពីព្រោះវាមិនដើរឆ្ងាយ។ ម៉្យាងទៀតនៅពេលដែលស្លឹកឈើឬសម្រាមនោះរលួយវានឹងក្លាយទៅជាជីកំប៉ុស្តដ៏ល្អអាចយកទៅប្រើប្រាស់បាន ហើយមានគុណភាពដូចជាជីលាមកគោដែរ។

**សកម្មភាពសំខាន់។** ៣០ នាទី

យើងនាំគ្នាទៅកន្លែងចិញ្ចឹមមាន់ ដោយយកសម្ភារៈទៅជាមួយផង។
អនុវត្តរបៀបធ្វើកំប៉ុស្តមាន់ ទៅតាមការពិភាក្សានៅក្នុងថ្នាក់ ចែកគ្នាជីក ១០ នាក់ធ្វើឱ្យបាន ១រណ្តៅ។
ធ្វើរួចហើយត្រឡប់ទៅថ្នាក់វិញ។

**បញ្ចប់មេរៀន** ១០ នាទី

ឱ្យសិស្សយកសៀវភៅ កត់ខ្លឹមសារមេរៀន និងសំណួរនៅលើក្តារខៀនយកទៅមើល និងឆ្លើយនៅផ្ទះ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ ត្រូវចេះសាកសួរឪពុកម្តាយ បងប្អូន ឬអ្នកជិតខាង។

សំណួរៈ ១. តើការរៀបចំកំប៉ុស្តមាន់ធ្វើដូចម្តេច?
២. តើការធ្វើកំប៉ុស្តមាន់មានសារប្រយោជន៍អ្វីខ្លះ?

បណ្តាំផ្ញើៈ- តាមដានរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច
- ការធ្វើកំប៉ុស្តមាន់មានសារៈសំខាន់ណាស់ អាចជួយឱ្យមាន់ឆាប់ធំធាត់ អាចកាត់បន្ថយក្នុងការទិញចំណីនិងកាត់បន្ថយក្នុងការបាត់បង់។

**ការស្តាប់នាក្រុម : ទាយសកម្មភាព** ១០ នាទី

ការរៀបចំលេងល្បែងមានដូចតទៅៈ
- សិស្សទាំងអស់ឈរជា ២ ជួរ បន្តពីក្រោយគ្នារហូត
- ក្រុមនីមួយៗ រើសតំណាងក្រុមម្នាក់ឱ្យឈរពីមុខជួរ តែបែរមុខទល់គ្នាជាមួយអ្នកដែលឈរក្នុងជួរ
- បន្ទាប់មក មានម្នាក់ទៀតឈរនៅពីក្រោយខ្នងអ្នកទាំង ២ លើកៅអីខ្ពស់ដើម្បីងាយស្រួលបង្ហាញសកម្មភាព
- ម្នាក់ដែលជាអ្នកលើកសកម្មភាពបង្ហាញទៅអ្នកដែលឈរក្នុងជួរ ហើយឱ្យធ្វើកាយវិការសកម្មភាពនោះដើម្បីឱ្យអ្នកដែលតំណាងក្រុមនីមួយៗ ទាយ តើសកម្មភាពនោះមានឈ្មោះអ្វី? ប៉ុន្តែហាមអ្នកទាំង ២ នេះមិនឱ្យងាទៅមើលក្រដាសសកម្មភាពដែលគេកំពុងបង្ហាញនោះទេ។
- បើក្រុមណាទាយឈ្មោះសកម្មភាពនោះត្រូវ ចាត់ទុកថាជាឈ្នះ។
- បន្ទាប់មកអ្នកដែលបង្ហាញសកម្មភាព រៀបចំបង្ហាញសាជាថ្មីទៀត ហើយការអនុវត្ត គឺដូចនៅជំហានទី ១ដែរ។ ប្រសិនបើក្រុមទាំង ២ ទាយមិនចំឈ្មោះសកម្មភាពនោះទេ អ្នកដែលបង្ហាញមានសិទ្ធិប្តូរបង្ហាញទៅសកម្មភាពមួយទៀត។

បញ្ជាក់ៈ អ្នកដែលបង្ហាញសកម្មភាព ត្រូវរៀបចំក្រដាសសកម្មភាព ជាមុនឱ្យហើយស្រេច។ សកម្មភាពទាំងនោះអាចសរសេរអ្វីក៏បានដែរដូចជាៈ ភ្ជួរស្រែ ដកសំណាប បោកស្រូវ ជិះកង់ ទាត់បាល់ កាត់សក់...។

ការសរសេរសកម្មភាពនេះ ច្រើនឬតិច អាស្រ័យទៅលើពេលវេលា។

- នៅទីបញ្ចប់ អ្នកដែលបង្ហាញសកម្មភាព ត្រួតពិនិត្យមើល តើក្រុមណាមួយដែលទាយត្រូវសកម្មភាពច្រើនជាងគេ ជាក្រុមឈ្នះ ហើយក្រុមដែលទាយត្រូវបានតិច ជាក្រុមចាញ់។
- ក្រុមដែលចាញ់ត្រូវតែពិន័យ ឱ្យច្រៀង ឱ្យរាំ ច្រៀងផងរាំផង ហើយក្រុមដែល ឈ្នះជួយទះដៃ។

# មេរៀនទី ៦: អនាម័យទ្រុងមាន់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ
មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ
- អាននិងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូ នឹងការបង្រៀនដែរឬទេ ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ
- ឯកសារណែនាំសម្រាប់គ្រូ កិច្ចតែងការ កាលវិភាគប្រចាំថ្ងៃ
- សៀវភៅសិស្សជាជម្រើសដែលគ្រូត្រូវការប្រើបើចាំបាច់
- ដីស ហ្វឺតសរសេរក្តារខៀន
- កំបោរ អំបោស បង្គី ចបកាប់/ប៉ែល។ល។

☼ វត្ថុបំណងៈ
នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖
- ធ្វើអនាម័យទ្រុងមាន់ និងស្នូកទឹក ស្នូកចំណី
- យល់ពីពីសារសំខាន់ការធ្វើអនាម័យទ្រុងមាន់។

**រំឭកមេរៀនទី ៥: របៀបធ្វើកំប៉ុស្តមាន់** 🕑 ១០ នាទី

លោកគ្រូ/អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោម៖

◈ តើការរៀបចំកំប៉ុស្តមាន់ធ្វើដូចម្តេច ? សិស្សនាំគ្នាឆ្លើយៈ
ការធ្វើកំប៉ុស្តមាន់រៀបចំដូចតទៅៈ
- ជ្រើសរើសកន្លែងមានម្លប់ឈើ ដើម្បីរៀបចំជាកន្លែងឱ្យមាន់កាយ។
- ជីករណ្តៅជម្រៅ ៣០ សម ទំហំ ២ x ២ម ជីកឱ្យបានច្រើនកន្លែង។
- ប្រមូលស្លឹកឈើ អង្កាមឬសារធាតុផ្សេងៗ ដាក់ក្នុងរណ្តៅ(ហាមដាក់លាមកសត្វ)បើនៅរដូវប្រាំងត្រូវស្រោចទឹកឱ្យសើមៗ ដើម្បីឱ្យសត្វល្អិតចូលនៅ នឹងក្លាយជាចំណីមាន់។
- ធ្វើរបងព័ទ្ធជុំវិញរណ្តៅ ឬយកបន្លាស្រះ ដើម្បីកុំឱ្យមាន់កាយសំរាមចេញពីរណ្តៅ។

បន្ទាប់ពីយើងដឹងថា មានសត្វល្អិតចូលនៅ យើងបើកបន្លាឱ្យមាន់កាយ។ រយៈ ២ ឬ ៣ ថ្ងៃក្រោយមករៀបចំរណ្តៅចាស់ឱ្យស្អាតដូចដើមវិញនិងស្រះបន្លាដដែល រួចទៅបើករណ្តៅថ្មីមួយទៀតឱ្យវាកាយ ធ្វើរបៀបនេះឱ្យបានជាបន្តបន្ទាប់។

តើការធ្វើកំប៉ុស្តមាន់មានសារប្រយោជន៍អ្វីខ្លះ?សិស្សនាំគ្នាឆ្លើយៈ

ការធ្វើកំប៉ុស្តមាន់ អាចជួយឱ្យមាន់របស់អ្នកលូតលាស់លឿន តាមរយៈការស៊ីសត្វល្អិតដែលសម្បូរណ៍ទៅដោយជាតិសាច់និងជៀសវាងការបាត់ដោយប្រការផ្សេងៗពីព្រោះវាមិនដើរឆ្ងាយ។ម្យ៉ាងទៀតនៅពេលដែលស្លឹកឈើឬ សម្រាមនោះរលួយ វានឹងក្លាយទៅជាជីកំប៉ុស្តដ៏ល្អអាចយកទៅប្រើប្រាស់បាន ហើយមានគុណភាពដូចជាជីលាមកគោដែរ។

**ចំណុចដើងមេរៀនទី៦: របៀបធ្វើអនាម័យទ្រុងមាន់** ៣០ នាទី

**សេចក្ដីផ្ដើម**

សរសេរចំណងជើងមេរៀន នៅលើក្ដារខៀន រួចគូសវង់ជុំវិញចំណងជើងមេរៀន។ បន្ទាប់មកគ្រូសួរសិស្សហើយឱ្យសិស្សឡើងមកក្ដារខៀនម្នាក់ម្ដងៗដើម្បីសរសេរយោបល់របស់គនៅជុំវិញចំណងជីងមរៀនអំពីខ្លឹមសារខាន់ៗដែលទាក់ទងនឹងមេរៀន។ ធ្វើរបៀបនេះដើម្បីឱ្យថ្នាក់រៀនមានសកម្មភាព និងឱ្យសិស្សមាភាពក្លាហានក្នុងការបញ្ចេញយោបល់ ។

តើរបៀបធ្វើអនាម័យទ្រុងមាន់ ត្រូវការសម្ភារៈអ្វីខ្លះ?

គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន




តើការធ្វើអនាម័យ និងវិធានការបង្ការជំងឺផ្សេងៗដូចម្ដេច?

ការធ្វើអនាម័យ និងវិធានការបង្ការជំងឺផ្សេងៗៈ

ដើម្បីឱ្យការចិញ្ចឹមមាន់ទទួលបានជោគជ័យ ទាមទារឱ្យអ្នកចញ្ចឹមធ្វើការថែទាំ និងធ្វើអនាម័យឱ្យបានល្អ។ វិធានការសំខាន់ៗដូចជាៈ

- ត្រូវបំបាត់ទឹកកខ្វក់ ដែលមាននៅជុំវិញផ្ទះ និងទីធ្លាជិតខាងក្បែរទ្រុងមាន់
- ត្រូវបោសសម្អាតទ្រុង និងលាងសម្អាតស្នូកចំណី និងស្នូកទឹកជារៀងរាល់ថ្ងៃ
- ចំណីនិងទឹកសម្រាប់មាន់ ត្រូវមានគុណភាពល្អ ចំណីដែលមាន់ស៊ីមិនអស់ត្រូវយកចេញ មិនត្រូវទុកឱ្យផ្អូមខូច គុណភាពនៅក្នុងស្នូកនោះទេ។
- ត្រូវលាងរំងាប់មេរោគនៅក្នុងទ្រុង ស្នូកទឹក ស្នូកចំណីនិងបរិវេណជុំវិញទ្រុងនៅពេលដែលមានផ្ទុះជំងឺ ដោយប្រើទឹកកំបោរស។ គួរទុកទ្រុងឱ្យនៅទំនេររយៈពេលពី ២-៤សប្ដាហ៍ទើបអាចដាក់មាន់ថ្មីចូលវិញបាន។
- មិនត្រូវទិញមាន់ដែលសង្ស័យថាឈឺពីផ្សារ ឬពីភូមិដែលកំពុងកើតជំងឺឆ្លងមកបរិភោគឡើយ

ព្រោះវាអាចនាំមេ រោគមកជាមួយផងក៏ថាបាន។

● ពូជមាន់ថ្មី ដែលយកមកពីប្រភពផ្សេងៗត្រូវធ្វើការបំបែក តាមដានដោយឡែកយ៉ាងតិច ៧ ថ្ងៃដើម្បីឱ្យច្បាស់ថាមាន់នោះពុំមានផ្ទុកជំងឺទេ។

● ប្រសិនបើមានមាន់ឈឺ ឬសង្ស័យថាកើតជំងឺឆ្លង យើងត្រូវបំបែកវាទៅដាក់នៅទ្រុងផ្សេងមួយទៀតឆ្ងាយពីគេ ដើម្បីកុំឱ្យវាចម្លងជំងឺទៅមាន់ដទៃទៀត ដែលនៅមានសុខភាពល្អ ។

● ហាមបរិភោគមាន់ឈឺ ឬមាន់ងាប់ដោយសារជំងឺ។ មិនត្រូវយកវាទៅលក់ ឬបោះចោលផ្ដេសផ្ដាសទេត្រូវកប់ ឬ ដុតចោល។

● ហាមអ្នកទិញមាន់ ឬយកមាន់ពីអ្នកដទៃ ចូលក្នុងទីធ្លា និងទ្រុងមាន់របស់យើងឡើយ។

## សកម្មភាពសំខាន់។

៤០ នាទី

យើងនាំគ្នាទៅកន្លែងចិញ្ចឹមមាន់ ដោយយកសម្ភារៈទៅជាមួយផង។

អនុវត្តរបៀបធ្វើអនាម័យទ្រុងមាន់ ទៅតាមការពិភាក្សានៅក្នុងថ្នាក់។

នៅពេលបោសសម្អាតទ្រុងបានស្អាត ហើយត្រូវឧស្សាហ៍បាញ់ថ្នាំការពារក្នុងបរិវេណចិញ្ចឹមមាន់។ ចំពោះថ្នាំផ្សំតាមរបៀបដូចខាងក្រោម:

- ទឹកខ្មេះ ១ ភាគ
- ស្រាស ១ ភាគ
- ស្ករត្នោត ១ ភាគ
- មេថ្នាំ ១ ភាគ
- ទឹក ៥ ភាគ

ធ្វើរួចហើយត្រឡប់ទៅថ្នាក់វិញ។

## បញ្ចប់មេរៀន

១០ នាទី

ឱ្យសិស្សយកសៀវភៅ កត់ខ្លឹមសារមេរៀន និងសំណួរនៅលើក្ដារខៀនយកទៅមើល និងឆ្លើយនៅផ្ទះ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ ត្រូវចេះសាកសួរឪពុកម្ដាយ បងប្អូន ឬអ្នកជិតខាង។

សំណួរ: ១. តើមានវិធានការអ្វីខ្លះដើម្បីចិញ្ចឹមមាន់ឱ្យឆាប់ធំ?

២. តើថ្នាំសម្អាតទ្រុងមាន់ផ្សំឡើងដោយអ្វីខ្លះ?

តាមដានរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច

- ក្នុងការចិញ្ចឹមមាន់ ត្រូវរៀបចំទ្រុងឱ្យហើយជាមុនសិន
- ត្រូវចេះប៉ាន់ស្មានពីបរិមាណមាន់ទៅនឹងទំហំទ្រុងដែលបានរៀបចំហើយ ៣-៥ក្បាលក្នុង ១ម៉ែត្រការេ។
- កូនមាន់ដែលបានបំបែកចេញពីមេត្រូវចាក់វ៉ាក់សាំង និងផ្ដល់កំដៅឱ្យវា។
- អនាម័យ: ទ្រុងស្ងួត ចំណីមានគុណភាពល្អនិងលាយថ្នាំទម្លាក់ព្រូន ទឹកស្អាត។
- បើយកមាន់ថ្មីមកចិញ្ចឹមបន្ថែម ត្រូវទុកវាដោយឡែក ៣-៤ ថ្ងៃដើម្បីពិនិត្យតាមដានមើលវាសិន។
- ត្រូវយកមាន់ឈឺដាក់ដោយឡែក ដើម្បីការពារកុំឱ្យឆ្លងជំងឺទៅដល់មាន់នៅក្នុងទ្រុង។

## ល្បែងកំសាន្ត : ដំឡូងក្តៅ

🕑 ១០ នាទី

ល្បែងនេះមានម្នាក់ ជាអ្នករៀបចំពីមុនឱ្យរួចជាស្រេចដូចជាៈ ការសរសេរសកម្មភាពនៅលើក្រដាសឱ្យបាន៥ ទៅ ៦សកម្មភាព គឺមួយសកម្មភាពសរសេរនៅលើក្រដាសមួយសន្លឹក ហើយយកក្រដាសដែលសរសេរសកម្មភាពមក ច្របាច់រុំពីលើគ្នាម្តងមួយៗឱ្យទៅជារាងមូលរហូតដល់អស់ ប៉ុន្តែគេអាចយកក្រដាសស្អាតមករុំឆ្លាស់គ្នានឹងក្រដាស សរសេរសកម្មភាពក៏បានដែរ។

នៅពេលចាប់ផ្តើមលេងល្បែងនេះ ឱ្យសិស្សឈរជារង្វង់មូល ហើយអ្នកដែលរៀបចំ យកដុំក្រ ដាសដែលរុំរួចហើយនោះ ទៅឱ្យអ្នកឈរម្នាក់កាន់សិន គេសន្មត់ថាជាដំឡូងក្តៅ ពីព្រោះអ្នកដែលទទួលមិនបានកាន់យូរទេប្រញាប់ហុច បន្តទៅអ្នកបន្ទាប់ទៀតព្រោះខ្លាចធ្វើសកម្មភាព ប៉ុន្តែគាប់ជួនអ្នក ខ្លះក៏ប៉ះចំក្រដាសគ្មានសកម្មភាពដែរ។

ចំណែកអ្នកដែលរៀបចំ មិនឈរនៅក្នុងរង្វង់ទេ ទៅពួនឬបែរមុខចេញពីអ្នកដែលលេងល្បែង ហើយបានឱ្យបញ្ជាថា ប្រុងប្រៀបចាប់ផ្តើម។ ក្រោយពីបានឮហើយអ្នកកាន់ដុំក្រដាសបានហុចឱ្យអ្នកបន្តបន្ទាប់យ៉ាងប្រញាប់។ រយៈ ប្រហែល ៥-៦ វិនាទីមក អ្នកបញ្ជាថាឈប់ អ្នកកំពុងលេងក៏ផ្អាកដែរ ហើយដុំក្រដាសនៅលើដៃអ្នកណាមួយ អ្នកនោះ ផែកមើល មានសរសេរសកម្មភាពអ្វីត្រូវធ្វើតាមតែម្តង។ ក្រោយពីអ្នកធ្វើសកម្មភាពនេះចប់ ល្បែងក៏ចាប់ផ្តើមបន្តទៀត គឺបានហុច ឱ្យអ្នកបន្តបន្ទាប់រហូតដល់អ្នកបញ្ជាថា ឱ្យឈប់ទើបឈប់ហើយអ្នកដែលកាន់ក្រដាសក៏ផែកមើលដូចអ្នក មុនដែរ បើឃើញសរសេរធ្វើសកម្មភាពអ្វីត្រូវតែធ្វើតាម។ ជាបន្តបន្ទាប់មកទៀត លំនាត្រូវធ្វើដូចអ្នកមុនៗ រហូតដល់ អស់ក្រដាសសកម្មភាព។ រីឯសកម្មភាពរបស់គេម្នាក់ៗគឺអាស្រ័យទៅតាមសកម្មភាពដែលបានសរសេរនៅលើក្រដាស ដែលគេចាប់បាន។

ចំណាំៈ និយាយរួម បើអ្នកណាបើកចំក្រដាសសកម្មភាពអ្វី ត្រូវតែធ្វើតាមសកម្មភាពនោះ ផ្ទុយទៅវិញបើអ្នកណា បើកចំក្រដាសសសុទ្ធ(គ្មានសរសេរសកម្មភាព)គ្មានធ្វើអ្វីទាំងអស់ ហើយហុចក្រដាសនោះជាបន្តបន្ទាប់ទៀតបាន ន័យថាអ្នកនោះសំណាងល្អ មិនបានធ្វើសកម្មភាពទេ ហើយហុចបន្តទៅទៀត។

ល្បែងនេះភាគច្រើននៅក្រដាសចុងក្រោយបង្អស់ អ្នករៀបចំច្រើនសរសេរសកម្មភាពថា" ច្រៀងនិងរាំទាំងអស់គ្នា" ដូច្នេះក៏ត្រូវច្រៀងនិងរាំទាំងអស់គ្នាតែម្តងទៅ។ធ្វើរបៀបនេះដើម្បីញ៉ាំងឱ្យការលេងល្បែងនេះកាន់តែសប្បាយរីករាយ និងស្និទ្ធស្នាលមួយកម្រិតថែមទៀត។



# មេរៀនទី ៧: ការជ្រើសរើសមាន់ចិញ្ចឹមបន្ត

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធាន ដែលត្រូវការ

- ឯកសារណែនាំសម្រាប់គ្រូ កិច្ចតែងការ កាលវិភាគប្រចាំថ្ងៃ
- សៀវភៅសិស្សជាជម្រើសដែលគ្រូត្រូវការប្រើបើចាំបាច់
- ដីស ហ្វឺតសរសេរក្តារខៀន
- សន្លឹកអ៊ុតចែកសិស្ស "សង្ខេបពីការចិញ្ចឹមមាន់"
- ផូស្ទ័រការចិញ្ចឹមមាន់

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- កត់សំគាល់អំពីមាន់មានសុខភាពល្អ និងមាន់មានជំងឺ
- ជ្រើសរើសមាន់ ទុកចិញ្ចឹមបន្ត។

**រំឭកមេរៀនទី ៦: អនាម័យទ្រុងមាន់** 🕑 ១០ នាទី

លោកគ្រូ/អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោម៖

◈ តើមានវិធានការអ្វីខ្លះដើម្បីចិញ្ចឹមមាន់ឱ្យឆាប់ធំ?

ដើម្បីឱ្យមាន់ឆាប់ធំ ត្រូវមានវិធានការសំខាន់ៗដូចជាៈ

- ត្រូវបំបាត់ទឹកក្រខ្វក់ ដែលមាននៅជុំវិញផ្ទះ និងទីធ្លាជិតខាងក្បែរទ្រុងមាន់
- ត្រូវបោសសម្អាតទ្រុង និងលាងសម្អាតស្នូកចំណី និងស្នូកទឹកជារៀងរាល់ថ្ងៃ
- ចំណីនិងទឹកសម្រាប់មាន់ ត្រូវមានគុណភាពល្អ ចំណីដែលមាន់ស៊ីមិនអស់ត្រូវយកចេញមិនត្រូវទុកឱ្យផ្អូមខូចគុណភាពនៅក្នុងស្នូកនោះទេ
- មាន់ណាដែលឈឺត្រូវប្រញាប់យកចេញ
- ទម្លាក់ព្រូនឱ្យបានញឹកញាប់។

❓ តើថ្នាំសម្អាតទ្រុងមាន់ផ្សំឡើងដោយអ្វីខ្លះ?
សិស្សនាំគ្នាឆ្លើយៈ
✏ ថ្នាំសម្អាតទ្រុងមាន់ផ្សំឡើងដោយៈ
- ទឹកខ្មេះ ១ ភាគ
- ស្រាស ១ ភាគ
- ស្ករត្នោត ១ ភាគ
- មេថ្នាំ ១ ភាគ
- ទឹក ៥ ភាគ

**ចំណងជើងមេរៀនទី ៧ៈ ការជ្រើសរើសមាន់ចិញ្ចឹមបន្ត** 🕑 ៣០ នាទី

លោកគ្រូ/អ្នកគ្រូបង្ហាញផូស្ទ័រពីការចិញ្ចឹមមាន់ ហើយឱ្យសិស្សពន្យល់ពីរបៀបធ្វើកំប៉ុស្តមាន់ ហេតុអ្វីបានជាកំប៉ុស្តមាន់មានសារសំខាន់?



តើរបៀបជ្រើសរើសមាន់ទុកពូជត្រូវធ្វើដូចម្តេចខ្លះ?

របៀបជ្រើសរើសមាន់ទុកធ្វើពូជបន្ត មានដូចតទៅៈ

ក.ការជ្រើសរើសពូជមាន់ៈ

ដើម្បីចិញ្ចឹម យើងគប្បីជ្រើសរើសយកមាន់ទាំងឡាយណា ដែលមានសុខភាពល្អ រហ័សរហួន ភ្នែកភ្លឺក្បាលងើបឡើងលើ ស្បែកភ្លឺរលោង គ្មានរបួសឬពិការ។ ការជ្រើសរើសមាន់ទុកធ្វើពូជបានល្អ ត្រូវសង្កេតមើលដូចតទៅៈ

១- ការសង្កេតនិងជ្រើសរើសកូនមាន់អាយុបាន ១ថ្ងៃៈ

កូនមាន់អាយុបាន១ថ្ងៃយើងមានការងាយស្រួលក្នុងការពិនិត្យមើលជើងចំពុះនិងពោះ។ មាន់ដែលមានសុខភាពល្អមានរោមគ្រសុះៗ ពោះមានពណ៌សហើយទន់ ផ្ចិតស្ងួត។ ចំពោះកូនមាន់ដែលសុខភាពមិនល្អមានរោមស្អិតជាប់គ្នាពោះធ្លាក់មានពណ៌ខៀវក្រម៉ៅ ផ្ចិតប្រហោង។ កូនមាន់ប្រភេទនេះមិនត្រូវរើសយកមកចិញ្ចឹមធ្វើពូជទេ។

២- ការជ្រើសរើសកូនមាន់អាយុពី ២-៤ សប្តាហ៍:

ការជ្រើសរើសមាន់ក្នុងអាយុនេះ គឺការជ្រើសរើសមាន់មកចិញ្ចឹមយកសាច់សំខាន់គឺយកមាន់ចូលចិត្តស៊ីចំណី (មើលតែ) ត្រូវមានជើងរឹងមាំ រោមរលោង ស្លាបក្តោបជាប់ខ្លួនទាំងសងខាង កន្ទុយសមនិងរូបរាង។ ចំពោះមាន់ដែលមានរោមពព្រុសៗស្លេកស្លាំងគឺមាន់ខ្វះជីវជាតិ។ ក្នុងអាយុនេះ មាន់ញីនិងមាន់ឈ្មោលចាប់ផ្តើមខុសគ្នាហើយ គឺមាន់ឈ្មោលមាឌធំជាងញី និងសិរក្រហមជាងមាន់ញី។ បើចិញ្ចឹមជាទ្រង់ទ្រាយធំ គួរចិញ្ចឹមឈ្មោលដោយឡែក និងញីដោយ ឡែក ធ្វើរបៀបនេះយើងនឹងចំណេញជាង ពីព្រោះយើងអាចចាប់មាន់ឈ្មោលលក់បានមុនមាន់ញី។

៣- ការជ្រើសរើសមាន់អាយុ ៣៦ - ៤២ ថ្ងៃ:

ការជ្រើសរើសមាន់នៅពេលនេះ គឺជាការសំខាន់ និងចាំបាច់ចំពោះមាន់យកសាច់ផង និងយកស៊ុតផង។ អាយុបាន ៣៦ ថ្ងៃចំពោះមាន់យកស៊ុត និង ៤២ ថ្ងៃចំពោះមាន់យកសាច់ ។

៤- ការជ្រើសរើសមេមាន់:

ក្រោយពេលពងវាញាស់ និងបណ្តើរកូនបានម្តងហើយមិនត្រូវយកទេ យើងត្រូវជ្រើសរើសយកកូនលើកទី២វិញ។ ក្នុងការចិញ្ចឹមគួរគប្បីកត់ត្រាចំនួនពងចំនួនកូនដែលទើបនឹងញាស់និងចំនួនកូនដែលមេលែងបណ្តើរធ្វើយ៉ាងនេះអាចទទួលបានលទ្ធផលពិតប្រាកដក្នុងការដកចេញនូវមេមាន់ដែលមិនសូវឱ្យពងនិងមិនចេះរក្សាកូន ដើម្បីបន្ថយចំណីផលិតពង។ ចំពោះមាន់ដែលផ្តល់ពងហើយ យើងអាចដឹងដោយចន្លោះឆ្អឹងគូថ និងឆ្អឹងទ្រូងធំទូលាយ។

ខ.របៀបជ្រើសរើសមាន់ធំទុកធ្វើបា មានលក្ខណៈដូចខាងក្រោម:

- មាន់បាត្រូវមានរូបរាងល្អធំជាត់ រឹងមាំ មិនដែលកើតជំងឺឆ្លង
- គួរមានទម្ងន់ ២ គក្រ ឡើងទៅ
- មានសភាពរហ័សរហួន ពូកែជាន់មេ
- មានអាយុចន្លោះពី ៩ខែ ទៅ ៣ ឆ្នាំ
- គួរជម្រុះចោលនូវមាន់បាចាស់ដែលមានអាយុលើសពី ៣ ឆ្នាំ។

គ.របៀបជ្រើសរើសមាន់ធំទុកធ្វើមេតាមលក្ខណៈដូចខាងក្រោម:

- មេមាន់ត្រូវមានរូបរាងធំជាត់ រឹងមាំ មិនដែលកើតជំងឺឆ្លង
- គួរមានទម្ងន់ ១.៥ គក្រ ឡើងទៅ
- មានអាយុចាប់ពី ៧ខែ ទៅ ៣ ឆ្នាំ
- ផ្តល់ពងយ៉ាងតិចពី ៤ ទៅ ៥ ដងក្នុង ១ ឆ្នាំ
- ផ្តល់ពងមួយដងបានពី ៨ ទៅ ១២ ពង
- ក្រាបពងម្តងៗ កូនញាស់បានយ៉ាងតិច ៨ ក្បាល
- ពូកែចិញ្ចឹមកូន នៅសល់ពីងាប់យ៉ាងតិចពី ៨ ក្បាល
- មិនកាច មិនចឹកកូនខ្លួនឯង ឬកូនរបស់មេដទៃទៀត
- គួរជម្រុះចោលនូវមេចាស់ ឬមេដែលគ្មានលក្ខណៈល្អដូចរៀបរាប់ខាងលើនេះចោល។

តើមាន់ទុកធ្វើពូជបន្តត្រូវជៀសវាងអ្វីខ្លះ?

ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់:

ក្នុងការទុកពូជបន្ត ត្រូវជៀសវាងក្នុងការបង្កាត់ជាន់ឈាម វាងកូននិងមេខ្លួនឯង ឬវាងបានិងកូនខ្លួនឯង និងវាង បងប្អូនបង្កើតរបស់វា។ ការបង្កាត់ដែលមានលក្ខណៈជាន់ឈាម បណ្តាលឱ្យលេចចេញនូវលក្ខណៈអន់ដូច

ជាមាឌកាន់តែតូចទៅៗ ពងតិចមិនសូវញាស់ឬកើតមកខ្សោយ ងាយទទួលជំងឺឆ្លងជាដើម។

ដូច្នេះជាការល្អប្រសើរ យើងគួរជ្រើសរើសបាដែលមិនមែនជាកូនមេពូជរបស់យើងតាមរយៈការដោះដូរបាជាមួយអ្នកជិតខាង ជាអ្នកធ្លាប់អនុវត្តតាមបច្ចេកទេសនេះបានល្អ។ ម្យ៉ាងទៀត ជៀសវាងការទុកពូជបាឬមេចេញពីកូនមេដែលទើបពងញាស់លើកទី ១ និងមេដែលមានអាយុចាស់លើសពី ៣ ឆ្នាំ។

## សកម្មភាពសំខាន់។

⌚ ៣០ នាទី

យើងនាំគ្នាទៅកន្លែងចិញ្ចឹមមាន់ ដើម្បីសង្កេតមើលឱ្យដឹងពីលក្ខណៈមាន់ញី និងមាន់ឈ្មោល។

អនុវត្តចាប់មាន់មានអាយុប្រហែល ៤ សប្តាហ៍ក្នុងសំបុកតែមួយ ដោយបង្ហាញពីទ្រង់ទ្រាយជាលក្ខណៈមាន់ញី និងមាន់ឈ្មោល។

បង្ហាញពីលក្ខណៈរូបរាងមាន់ដែលត្រូវទុកធ្វើពូជបន្ត និងមាន់ដែលមិនអាចយកធ្វើពូជបាន។

ធ្វើរួចហើយត្រឡប់ទៅថ្នាក់វិញ។

## បញ្ចប់មេរៀន

⌚ ១០ នាទី

ទាំងអស់គ្នាយកសៀវភៅ កត់ខ្លឹមសារមេរៀន និងសំណួរនៅលើក្តារខៀនយកទៅមើល និងឆ្លើយនៅផ្ទះ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ ត្រូវចេះសាកសួរឪពុកម្តាយ បងប្អូន ឬអ្នកជិតខាង។

សំណួរៈ ១. តើការជ្រើសរើសកូនមាន់អាយុបាន ១ថ្ងៃទុកធ្វើពូជត្រូវមានលក្ខណៈដូចម្តេចខ្លះ?

២. តើការជ្រើសរើសមាន់ទុកធ្វើបានិងមេត្រូវមានលក្ខណៈដូចម្តេច?

៣. តើមាន់ទុកធ្វើពូជបន្តត្រូវជៀសវាងអ្វីខ្លះ?

តាមដានរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច

បណ្តាំផ្ញើៈ- ជៀសវាងទម្លាប់ទុកមាន់ឈឺធ្វើពូជបន្ត។

- ជៀសវាងយកមាន់ក្មេងពេក ឬចាស់ពេកមកធ្វើពូជបន្ត។
- ជ្រើសរើសមាន់ទុកធ្វើពូជ ត្រូវតាមដានតាំងពីញាស់រហូតដល់ធំ។
- កូនមាន់ ដែលបានបំបែកចេញពីមេត្រូវចាក់វ៉ាក់សាំង និងផ្តល់កំដៅឱ្យវា។

**ល្បែងកំសាន្ត : ស្តេចចង់** ⏲ ១០ នាទី

ល្បែងស្តេចចង់ មានម្នាក់តាំងខ្លួនធ្វើជាស្តេចចំណែកឯអ្នកផ្សេងទៀតចែកជា២ក្រុមស្មើគ្នាហើយអ្នកឈរ និងអ្នកធ្វើស្តេចត្រូវនៅចម្ងាយពីគ្នាប្រហែល ១០ម៉ែត្រ។

អ្នកដែលឈរតាមក្រុមទី១ ឱ្យទៅខ្សឹបឈ្មោះអ្នកនៅក្រុមទី ២ ដាក់ស្តេច បន្ទាប់មកក្រុមទី២ទៅខ្សឹបឈ្មោះអ្នកនៅក្រុមទី ១ ដាក់ស្តេចវិញម្តង។ ការធ្វើរបៀបនេះគឺផ្លាស់ប្តូរក្រុមរហូត ហើយមិនប្រកាន់ទេ អ្នកណាឡើងទៅ ខ្សឹបដាក់ស្តេចក៏បានដែរ។

ចំពោះអ្នកនៅតាមក្រុមនីមួយៗ ដែលឡើងទៅរកស្តេចនោះត្រូវចំឈ្មោះដែលក្រុមគេប្រាប់ ស្តេចនោះឯងតម្រូវឱ្យទៅនៅក្រុមគេហើយចំណែកឯក្រុមមួយទៀតក៏ធ្វើដូច្នោះដែរ។ សកម្មភាពល្បែងនេះអាចលេងបានយូរឬឆាប់គឺអាស្រ័យទៅតាមពេលវេលាដែលយើងគ្រោងទុក។

នៅទីបញ្ចប់អ្នកដែលធ្វើស្តេចត្រូវពិនិត្យមើលក្រុមណាដែលមានចំនួនច្រើនជាងគឺឈ្នះ ក្រុមណា ចំនួនតិចគឺចាញ់ ហើយក្រុមដែលចាញ់ ត្រូវពិន័យ ស្រេចតែយើងនាំគ្នាកំណត់ចុះអាចរាំ ច្រៀងឬធ្វើសកម្ម ភាពផ្សេងៗក៏បាន។



# មេរៀនទី ៨: ការទម្លាក់ព្រូនមាន់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្ដារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្ដារខៀន...)

📖 សម្ភារឧបទេស ធនធាន ដែលត្រូវការ

- ឯកសារណែនាំសម្រាប់គ្រូ កិច្ចតែងការ កាលវិភាគប្រចាំថ្ងៃ
- សៀវភៅសិស្សជាជម្រើសដែលគ្រូត្រូវការប្រើប្រើចាំបាច់
- ដីស ហ្វឺតសរសេរក្ដារខៀន
- ថ្នាំព្រូន ស្លឹកឬផ្លែក្តម្ពទេស ផ្លែស្លាខ្ចី ចំណី។ល។

☼ វត្ថុបំណងៈ

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

១. ផ្សំថ្នាំទម្លាក់ព្រូនមាន់ដោយខ្លួនឯង

២. អនុវត្តតាមរបៀបនការទម្លាក់ព្រូនមាន់ ។

**រំឭកមេរៀនទី ៧: ការជ្រើសរើសមាន់ចិញ្ចឹមបន្ត** 🕑 ១០ នាទី

លោកគ្រូ អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោម៖

◈ តើការជ្រើសរើសកូនមាន់អាយុបាន ១ថ្ងៃទុកធ្វើពូជមានលក្ខណៈដូចម្ដេចខ្លះ? សិស្សនាំគ្នាឆ្លើយៈ

ការជ្រើសរើសកូនមាន់អាយុបាន ១ថ្ងៃទុកធ្វើពូជត្រូវសង្កេតមើលលក្ខណៈដូចជាៈ

កូនមាន់អាយុបាន ១ថ្ងៃ យើងមានការងាយស្រួលក្នុងការពិនិត្យមើល ជើង ចំពុះ និងពោះ។ មាន់មានសុខភាពល្អមានរោមគ្រសុះៗពោះមានពណ៌សហើយទន់ផ្ចិតស្ងួត។ ចំពោះកូនមាន់ដែលសុខភាពមិនល្អ មានរោមស្អិតជាប់គ្នាពោះធ្លាក់មានពណ៌ខៀវក្រមៅ ផ្ចិតប្រហោង។ កូនមាន់ប្រភេទនេះ មិនត្រូវរើសយកមកចិញ្ចឹមធ្វើពូជឡើយ។

តើការជ្រើសរើសមាន់ទុកធ្វើបានិងមេត្រូវមានលក្ខណៈដូចម្ដេច?សិស្សនាំគ្នាឆ្លើយៈ

ការជ្រើសរើសមាន់ទុកធ្វើបាមានលក្ខណៈដូចតទៅៈ

- មាន់បាត្រូវមានរូបរាងល្អ ធំធាត់ រឹងមាំ មិនដែលកើតជំងឺឆ្លង
- គួរមានទម្ងន់ ២ គ.ក្រ ឡើងទៅ
- មានសភាពរហ័សរហួន ពូកែជាន់មេ

● មានអាយុចន្លោះពី ៩ខែ ទៅ ៣ ឆ្នាំ

● គួរជម្រុះចោលនូវមាន់បាចាស់ដែលមានអាយុលើសពី ៣ ឆ្នាំ។

- ការជ្រើសរើសមាន់ទុកធ្វើមេមានលក្ខណៈដូចតទៅៈ

● មេមាន់ត្រូវមានរូបរាងធំធាត់ រឹងមាំ មិនដែលកើតជំងឺឆ្លង

● គួរមានទម្ងន់ ១.៥ គក្រ ឡើងទៅ

● មានអាយុចាប់ពី ៧ខែ ទៅ ៣ ឆ្នាំ

● ផ្តល់ពងយ៉ាងតិចពី ៤ ទៅ ៥ ដងក្នុង ១ ឆ្នាំ

● ផ្តល់ពងមួយដងបានពី ៨ ទៅ ១២ ពង

● ក្រាបពងម្តងៗកូនញាស់បានយ៉ាងតិច ៨ ក្បាល

● ពូកែចិញ្ចឹមកូន នៅសល់ពីងាប់យ៉ាងតិចពី ៨ ក្បាល

● មិនកាច មិនចឹកកូនខ្លួនឯង ឬកូនរបស់មេដទៃទៀត

● គួរជម្រុះចោលនូវមេចាស់ ឬមេដែលគ្មានលក្ខណៈល្អដូចរៀបរាប់ខាងលើនេះចោល

តើមាន់ទុកធ្វើពូជបន្តត្រូវជៀសវាងអ្វីខ្លះ?

ការជ្រើសរើសមាន់ទុកធ្វើពូជបន្ត ត្រូវជៀសវាងក្នុងការបង្កាត់ជាន់ឈាម រវាងកូននិងមេខ្លួនឯង ឬរវាងបា និងកូនខ្លួនឯង និងរវាងបងប្អូនបង្កើតរបស់វា។ ការបង្កាត់ដែលមានលក្ខណៈជាន់ឈាម បណ្តាលឱ្យលេចចេញនូវលក្ខណៈអន់ដូចជាមាឌកាន់តែតូចទៅៗ ពងតិចមិនសូវញាស់ ឬកើតមកខ្សោយងាយទទួលជំងឺឆ្លងជាដើម។

ដូច្នេះជាការល្អប្រសើរ យើងគួរជ្រើសរើសបាដែលមិនមែនជាកូនមេពូជរបស់យើង តាមរយៈការដោះដូរបា ឬមេជាមួយអ្នកជិតខាង ជាអ្នកធ្លាប់អនុវត្តតាមបច្ចេកទេសនេះបានល្អ។ ម្យ៉ាងទៀតជៀសវាងការទុកពូជបាឬមេចេញពីកូនមេដែលទើបពងញាស់លើកទី ១ និងមេដែលមានអាយុចាស់លើសពី ៣ ឆ្នាំ។

**ចំណងជើងមេរៀនទី ៨ៈ ការទម្លាក់ព្រូនមាន់** ⌚ ៤០ នាទី

លោកគ្រូ/អ្នកគ្រូពន្យល់ ពីរបៀបទម្លាក់ព្រូនមាន់

? តើការទម្លាក់ព្រូនមាន់ត្រូវមានអ្វីខ្លះ?

គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀនៈ

គ្រាប់សង្កែ គ្រាប់ក្ទម្ពទេស ផ្លែស្លាថ្មី ស្លឹកក្ទម្ពទេស ដូងទំកោសរួច...

តើរបៀបទម្លាក់ព្រូនមាន់ធ្វើដូចម្តេចខ្លះ?

ពន្យល់ចំណុចសំខាន់ៗ ឬ ប្រាប់សិស្សនៅក្នុងថ្នាក់

● ការទម្លាក់ព្រូនៈ

នៅពេលកូនមាន់មានអាយុ ៣ សប្តាហ៍វាចាប់ផ្តើមចេះដើរកកាយរកចំណីស៊ីដោយខ្លួនវាហើយឆ្លងនូវជំងឺព្រូន។ *ដូច្នេះត្រូវទម្លាក់ព្រូនជារៀងរាល់ខែ* ដោយប្រើប្រាស់នូវចំណី ដូចជា ស្លឹកឬគ្រាប់ក្ទម្ពទេស គ្រាប់សង្កែនិងផ្លែស្លាខ្ចីជាដើម។ល។

តើរុក្ខជាតិអ្វីខ្លះ ដែលអាចយកមកប្រើក្នុងការទម្លាក់ព្រូនឱ្យមាន់បាន?

រុក្ខជាតិដែលអាចយកមកប្រើក្នុងការទម្លាក់ព្រូនឱ្យមាន់បាន ងាយរកនៅក្នុងមូលដ្ឋានដូចជាៈ ស្លឹកឬគ្រាប់ក្ទម្ពទេស និងគ្រាប់សង្កែ យើងអាចលាយជាមួយចំណីរយៈពេល ៣ថ្ងៃម្តង ឬចាប់បញ្ច្រកក្នុងកម្រិត ៣

គ្រាប់សម្រាប់មាន់ទម្ងន់ ១ គ.ក្រ។ ចំពោះផ្លែស្លាយើងអាចយកមកបញ្ចូក ឬបុកលាយជាមួយចំណីឬលាយនឹងទឹកក៏បានក្នុងកម្រិត ១/៤ នៃផ្លែស្លា សម្រាប់ទម្ងន់មាន់ ១ គ.ក្រ ។

ម្យ៉ាងទៀតយើងអាចធ្វើការទម្លាក់ព្រូន ដោយប្រើកន្ទក់លាយជាមួយនឹងដូងទុំកោសរួចច្របល់ចូលគ្នា( ដូងទុំ ១ ជាមួយនឹងកន្ទក់ ៣ គ.ក្រ) ដោយដាក់ឱ្យស៊ីជារៀងរាល់ខែ។ ការទម្លាក់ព្រូនមាន់អាចជួយឱ្យមាន់មានសុខភាពរឹងមាំ ឆាប់ធំធាត់ ហើយមិនងាយកើតជំងឺផ្សេងៗទៀតផង។

**សកម្មភាពសំខាន់។** ⌚ ៣០ នាទី

យើងនាំគ្នាទៅកន្លែងចិញ្ចឹមមាន់ ដើម្បីរៀបចំដាក់ថ្នាំព្រូនឱ្យមាន់។

គ្រូអនុវត្តជាមួយសិស្ស ចាប់មាន់បញ្ចុកថ្នាំព្រូន ដូចដែលយើងបានពិភាក្សានៅក្នុងថ្នាក់ ហើយ អនុញ្ញាតឱ្យសិស្សអនុវត្តជាបន្តបន្ទាប់។

ធ្វើរួចហើយត្រឡប់ទៅថ្នាក់វិញ។

**បញ្ចប់មេរៀន** ⌚ ១០ នាទី

ទាំងអស់គ្នាយកសៀវភៅ កត់ខ្លឹមសារមេរៀន និងសំណួរនៅលើក្ដារខៀនយកទៅមើល និងឆ្លើយនៅផ្ទះ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ ត្រូវចេះសាកសួរឪពុកម្ដាយ បងប្អូន ឬអ្នកជិតខាង។

សំណួរៈ ១. តើរុក្ខជាតិអ្វីខ្លះ ដែលអាចយកមកប្រើក្នុងការទម្លាក់ព្រូនឱ្យមាន់បាន?

២. តើរបៀបទម្លាក់ព្រូនមាន់ធ្វើដូចម្ដេចខ្លះ?

បណ្ដាំផ្ញើៈ- ត្រូវរកវត្ថុធាតុដើមដែលមាននៅក្នុងមូលដ្ឋាន ដើម្បីទម្លាក់ព្រូនឱ្យមាន់
- ការទម្លាក់ព្រូន ដើម្បីឱ្យមាន់មានសុខភាពល្អ និងឆាប់ធំធាត់
- ចំណី ទឹក និងស្នូកត្រូវមានអនាម័យ
- តាមដានរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច។

**ល្បែងកំសាន្ត : កណ្ដៀរចូលរន្ធ** ⌚ ១០ នាទី

ឱ្យសិស្សទាំងអស់ឈរជារង្វង់មូល កាន់ដៃបន្តគ្នា តែឱ្យដាច់នៅចន្លោះមួយៗ ម្នាក់ធ្វើជាដើមទីនិងម្នាក់ទៀតធ្វើចុងទី។ បន្ទាប់មកអ្នកនៅចុងទី ដើរកាន់ដៃបន្តគ្នាចូលទៅតាមចន្លោះអ្នកទី១ និងទី២ ហើយអ្នកទាំងអស់កាន់ដៃគ្នាហូតដើម្បីឱ្យអ្នកដែលដើរចូលមុជក្រោមដៃ ហាក់បីដូចជាកណ្ដៀរចូលរន្ធ រហូតដល់អ្នកទី ២ក៏ចូលដែរតែត្រូវបង្វិលដៃក្រឡាស់ខ្លួនមកឱ្យដូចនឹងគេដែរ។ ក្រោយមកទៀតអ្នកនៅចុងទីដដែល ដើរចូលចន្លោះអ្នកទី ២ និង ទី ៣ ទៀត រហូតដល់អ្នកទី ៣ ក៏ចូលដែរ តែត្រូវបង្វិលដៃក្រឡាស់ខ្លួនមកដូចអ្នកទី ២ ដែរ ។ ការធ្វើសកម្មភាពដដែលនេះ អ្នកនៅចុងទីដើរចូលចន្លោះអ្នកទី ៣ និង ទី ៤ ហើយក៏ដើរចូលចន្លោះជាបន្តបន្ទាប់រហូតដល់ចុងទី។ ចំពោះអ្នកចុងទីត្រូវចូលចន្លោះចុងបំផុតដែរ ដោយបង្វិលដៃក្រឡាស់ខ្លួនមកឱ្យដូចដើមវិញជាការស្រេច។

ក្រោយពីបានធ្វើសកម្មភាពជំហានទី១ ចប់ហើយត្រូវប្ដូរគ្នា គឺអ្នកនៅដើមពីមុនធ្វើចុងទី អ្នកនៅចុងពីមុនធ្វើដើមទីវិញម្ដង។ ចំណែកឯសកម្មភាព ធ្វើឱ្យដូចកាលពីធ្វើនៅជំហានទី ១ ដដែល។

បន្ទាប់ពីបានធ្វើសកម្មភាពជំហានទី ២ ទាំងអស់គ្នារួចមក ល្បែងនេះក៏សន្មត់ថាចប់។

# មេរៀនទី ៩: ជំងឺមាន់

🕑 រយៈពេលបង្រៀនៈ ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវនឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើលព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

📖 សម្ភារឧបទេស ធនធានដែលត្រូវការ

- ឯកសារណែនាំសម្រាប់គ្រូ កិច្ចតែងការ កាលវិភាគប្រចាំថ្ងៃ
- សៀវភៅសិស្សជាជម្រើសដែលគ្រូត្រូវការប្រើបើចាំបាច់
- ដីស ហ្វឺតសរសេរក្តារខៀន
- សំណាកមាន់មានជំងឺ ថ្នាំព្យាបាល វ៉ាក់សាំង។ល។
- ដូស្ស៊ីការចិញ្ចឹមមាន់

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាច ៖

- កំណត់បានរោគសញ្ញាមាន់ដែលកើតជំងឺ
- ផ្តល់ថ្នាំព្យាបាលឱ្យមាន់
- ចាក់វ៉ាក់សាំងឱ្យមាន់។

**រំឭកមេរៀនទី ៨: ការទម្លាក់ព្រូនមាន់** 🕑 ១០ នាទី

លោកគ្រូ/អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោម៖

◈ តើរុក្ខជាតិអ្វីខ្លះដែលអាច យកមកប្រើក្នុងការទម្លាក់ព្រូនឱ្យមាន់បាន? សិស្សនាំគ្នាឆ្លើយៈ

រុក្ខជាតិអ្វីខ្លះដែលអាចយកមកប្រើក្នុងការទម្លាក់ព្រូនឱ្យមាន់បាន ដូចជាៈ

- ស្លឹកឬគ្រាប់ក្តម្ពទេស
- គ្រាប់សង្កែ
- ផ្លែស្លាខ្ចី
- ដូងទុំ

តើរបៀបទម្លាក់ព្រូនមាន់ធ្វើដូចម្តេចខ្លះ? សិស្សនាំគ្នាឆ្លើយៈរបៀបទម្លាក់ព្រូនមាន់អនុវត្តដូចតទៅៈ ស្លឹកឬគ្រាប់ក្តម្ពទេស និងគ្រាប់សង្កែ យើងអាចលាយជាមួយចំណីរយៈពេល ៣ថ្ងៃម្តង ឬចាប់បញ្ចុកក្នុងកម្រិត៣គ្រាប់សម្រាប់មាន់ទម្ងន់ ១ គ.ក្រ។ ចំពោះផ្លែស្លាខ្ចី យើងអាចយកមកបញ្ចុក ឬបុកលាយជាមួយចំណី ឬលាយ

នឹងទឹកក៏បានក្នុងកម្រិត១/៤នៃផ្លែស្លាសម្រាប់ទម្ងន់មាន់១គ.ក្រ។ ម្យ៉ាងទៀតយើងអាចធ្វើការទម្លាក់ព្រូនដោយប្រើកន្ទក់លាយជាមួយនឹងដូងទុំកោសរួចច្របល់ចូលគ្នា( ដូងទុំ ១ ជាមួយនឹងកន្ទក់ ៣ គ.ក្រ ) ដោយដាក់ឱ្យស៊ីជារៀងរាល់ខែ។ ការទម្លាក់ព្រូនមាន់អាចជួយឱ្យមាន់មានសុខភាពរឹងមាំ ឆាប់ធំធាត់ ហើយមិនងាយកើតជំងឺផ្សេងៗទៀតផង។

## ចំណងជើងមេរៀនទី ៩: អំពីជំងឺមាន់

🕑 ៤០ នាទី

លោកគ្រូ អ្នកគ្រូ បង្ហាញផ្ទាំងរូបការចិញ្ចឹមមាន់ ពន្យល់ពីរបៀបចាក់វ៉ាក់សាំង ។បន្ទាប់មកគ្រូសួរទៅសិស្ស តើជំងឺមាន់មានអ្វីខ្លះ ?

គ្រូសរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន៖ ជំងឺរាកឈាម ជណងឺរាកស ជំងឺអាសន្នរោគ ជំងឺអុតមាន់ ជំងឺញូកាស។




◈ តើអ្នកកត់សំគាល់មាន់កើតជំងឺដូចម្ដេច ?តើអ្នកមានវិធានការដូចម្ដេចនៅពេលដែលមាន់មានជំងឺ ?

ការកត់សំគាល់មាន់មានជំងឺនិងវិធានការមានដូចតទៅ:

**១.អំពីជំងឺញូកាស: ( New Castle Diseases )**

ជំងឺញូកាស បង្កឡើងដោយវីរុស។ វាជាជំងឺមួយដែលឆ្លងរាលដាលយ៉ាងសាហាវបំផុត។

**ក.រោគសញ្ញា:**

យើងសង្កេតឃើញមាន់មួយចំនួនក្នុងហ្វូង ចុះខ្សោយ សំកុក ធ្លាក់ស្លាប ភ្នែកព្រឹមៗ ស៊ីតិច/អត់ស៊ី ប្រសិនបើយើងកំដៅឡើងខ្ពស់ ៤២-៤៣ អង្សាសេ។ មាន់ឈ្មោលឈប់រងាវ មេមាន់ថយពងឬអត់ពង លាមកធំក្លិនឆ្អេះឆ្អួល។

- ពិបាកដកដង្ហើម ហាមាត់ដូចស្វាប ហៀរទឹកសំបោរ
- ពេលរាកមក លាមកឡើងខៀវ ហើយប្រែបន្តិចម្តងៗ ទៅជាស
- លាមកមានលាយឈាម ក្លិនឆ្អាប មាត់ហៀរទឹករអិល ក្នុងគែរមានទឹកពេញ
- ញាក់ញ័រកន្ត្រាក់ខ្លួន កាច់ក។ កូនមាន់ និងមាន់ជំទង់ ធន់នឹងជំងឺនេះ ច្រើនជាងមាន់ធំ។

**ខ.ការព្យាបាល**

ជំងឺញូវកាសគ្មានថ្នាំព្យាបាលទេ។ ប៉ុន្តែគេឱ្យមាន់ផឹកស្រាត្រាំក្អែប៣-៤ ម.ល/ក្បាល ឬអាចឱ្យផឹកទឹកខ្ទឹលាយជាមួយនឹងខ្ទឹមសតែពុំសូវមានប្រសិទ្ធភាពទេ។

**គ.ការការពារ:**

- សម្អាតទ្រុង និងសម្ភារៈផ្សេងៗ ដែលមាននៅក្នុងទ្រុងមាន់
- ទ្រុងត្រូវស្ងួត ផ្តល់ចំណីឱ្យមាន់ មានសុខភាពល្អ និងឱ្យបានគ្រប់គ្រាន់
- ដុត ឬ កប់ចោលមាន់ដែលងាប់ដោយជំងឺនេះ។

**២.អំពីជំងឺអុតមាន់:** ( Variuola Ovium )

ជាជំងឺឆ្លងរាលដាលនៃសត្វមាន់ ហើយបង្កដោយវីរុស

**ក.រោគសញ្ញា: គេចែករោគសញ្ញាជំងឺអុតមាន់ជា ៣ សណ្ឋាន:**

- **សណ្ឋានអុតសើស្បែក:** ដុំពកតូចមានពណ៌កូលាប ឬលឿងហើយប្រែទៅជាក្រមរ នៅលើកន្លែងអត់រោម ដូចជាសិរនៅលើខ្ទង់ច្រមុះ គែមចំពុះ ជុំវិញភ្នែក ត្រចៀក ជើង បើកើតលើភ្នែកនឹងធ្វើឱ្យខ្វាក់ភ្នែកបើកើតលើចំពុះ ពិបាកស៊ី ផឹកទឹក កើតលើច្រមុះពិបាកដកដង្ហើម ។
- **សណ្ឋានអុតក្នុងមាត់ និងក្នុងបំពង់ក:** ក្នុងមាត់និងក្នុងបំពង់ក រលាក កកឈាម មានចំណុចពណ៌លឿង ។ ចំណុចនេះរាល ពកជាដុំ ឬជាបន្ទះ ច្បាមជាប់ក្នុងមាត់ ។ បន្ទះនោះបិទជាប់នឹងបំពង់ក ធ្វើឱ្យស្ទះដង្ហើមងាប់ ។
- **សណ្ឋានអុតនៅភ្នែក និងច្រមុះ:** មាន់ឈឺរលាកភ្នែក មានពពឹកភ្នែក ត្របកភ្នែកជាប់គ្នា ច្រមុះរលាកហៀរទឹកពេលចូលទឹកច្រមុះស្ងួតក្រៀមបិទរន្ធច្រមុះ នាំឱ្យពិបាកដកដង្ហើម។

**ខ.ការការពារ**

- អនាម័យ
- ការចាក់ថ្នាំការពារ
- សម្លាប់មូស រុយ ល្បោម ដែលជាភ្នាក់ងារចម្លងមេរោគ។

**គ.ការព្យាបាល:**

គ្មានថ្នាំព្យាបាលទេ តែតាមបទពិសោធន៍គេអាចយកក្រមរចេញ រួចលាបប្រ៊ីមេទីឡែន។ម៉្យាងទៀតអាចលាយជាម្សៅស្ត្រឹបតូមីស៊ីន និងម្សៅតាំងទេទីយ៉ូដ និងអាស៊ីដថៃ លាបលើមុខរបួស ។

**៣.ជំងឺអាសន្នរោគមាន់:** ( Fowl Cholera )

ជំងឺនេះបណ្តាលមកពីបាក់តេរី។ ជំងឺនេះច្រើនកើតចំពោះមាន់ដែលចិញ្ចឹមក្នុងលក្ខណៈកខ្វក់ ឬការចិញ្ចឹមដោយពុំបានប្រើថ្នាំការពារ។ ជំងឺនេះជាប្រភេទ ជំងឺឆ្លងយ៉ាងសាហាវ ។

**ក.រោគសញ្ញា:**
ជួនកាលមាន់ងាប់ភ្លាមៗជួនងាប់ពេលកំពង់ស៊ីជួនងាប់ក្នុងទ្រុងឬលើមែកឈើនៅពេលយប់ជួនកាលេចញរោគសញ្ញា ក្តៅខ្លាំង សំកុក អត់ស៊ី អត់ផឹក ជាំសិរ ច្រមុះ ចំពុះ មានទឹករំអិលពិបាកដកដង្ហើមចុះរាកលាមក មានពណ៌លឿង ព្រលៃត រោមជុំវិញគូថ ប្រឡាក់លាមក។ ត្រចៀករលាកចេញទឹកពណ៌លឿង មាន់កាច់ក រលាកសន្លាក់ឆ្អឹង។

**ខ.ការការពារ:** មានវិធានការអនាម័យ ប្រើវ៉ាក់សាំង (ទាក់ទងនឹងបសុពេទ្យ)

**គ.ការព្យាបាល:** គួរព្យាបាលសត្វដែលនៅជាមួយគ្នា ទាំងឈឺទាំងជា

- សត្វជា: ប្រើតេត្រាស៊ីគ្លីនគ្រាប់ ២៥០ម.ក្រ ៤គ្រាប់ ក្នុង១ ថ្ងៃសម្រាប់មាន់៥ក្បាលក្នុងរយៈពេល៣-៥ ថ្ងៃ ។
- សត្វឈឺ: ប្រើអុកស៊ីតេត្រាស៊ីគ្លីន ១០% ចាក់សាច់ដុំ ០.២-០.៥ មល ក្នុង ១ក្បាលព្យាបាលពី ៣-៥ ថ្ងៃ ។
- ទែរ៉ាមីស៊ីនលាយជាមួយចំណី ០.២២% ។
- ស្ត្រឹបតូមីស៊ីន ចាក់នឹងសាច់ដុំ ១៥០-២០០ មក្រ ទម្ងន់ ១ គក្រ ក្លរ៉ាំហ្វេនីកុល ២០-៤០ម.ក្រ ទម្ងន់ ១ គក្រ ឱ្យផឹក ឬលាយជាមួយចំណី ។

**៤.អំពីជំងឺរាកសះ:** (Salmonellosis)

ជំងឺរាកសជាប្រភេទជំងឺឆ្លងរាលដាលឆាប់រហ័ស ច្រើនកើតនៅលើមាន់ដែលមានអាយុពី ១-១៥ថ្ងៃ ។ ជំងឺនេះបង្កឡើងដោយបាក់តេរី។ លក្ខណៈពិសេសនៃជំងឺនេះគឺ រាកលាមកមានពណ៌ស ចុះទម្ងន់ អត្រាស្លាប់ពី ៤០-៥០%។

**ក.រោគសញ្ញា**
មាន់មានពោះធំ រោមបះ សំកុក ភ្នែកមមី ស៊ីតិច ឬអត់ស៊ី លាមកមានពណ៌ស ។ ចំពោះមេមាន់រាកពង រោមស្រអាប់សិរស្លេក ពងរាងវៀចមិនដូចជាពងធម្មតា។ ជំងឺនេះចម្លងពីមេឈឺ ទៅកូនតាមរយៈស៊ុត និងអាចឆ្លងតាមរយៈចំណី ទឹក បរិយាកាសផ្សេងៗ នៅជុំវិញដែលមិនស្អាត ។

**ខ.ការការពារ: ការចាក់វ៉ាក់សាំង**

- អនាម័យទ្រុង និងសម្ភារៈប្រើប្រាស់ក្នុងទ្រុង
- ដុតបំផ្លាញចោលសត្វងាប់ដោយជំងឺ
- កូនមាន់ទើបនឹងញាស់ត្រូវដាក់កន្លែងស្ងួតស្អាត ហើយត្រូវផ្តល់ចំណីដែលមានជីវជាតិ អា. ដេ.អឺ ឬអាចប្រើខ្លាញ់ថ្លើមត្រី១-២% ឬ ១-២ លីត្រ ក្នុងចំណី ១០០ គក្រ ឬ ១-២ មល ក្នុង ចំណី១ គក្រ ។

**គ.ការព្យាបាល**
ប្រើថ្នាំតេត្រាស៊ីគ្លីន(ចាក់) ៣០-៤០ មក្រ ក្នុងទម្ងន់មាន់ ១ គក្រ ។ ក្លរ៉ាមហ្វេនីកុល ១០% ចាក់សាច់ដុំ ៣០-៥០ មក្រ ក្នុងទម្ងន់មាន់ ១ គក្រ ឬអាចយក ៥ សេសេលាយទឹកស្អាត ១ លីត្រឱ្យមាន់ផឹក ៣-៥ ថ្ងៃ ។

**៥.ជំងឺរាកឈាម:** (Coccidiosis Avium)

ជាជំងឺសាហាវមួយក្នុងចំណោមជំងឺមាន់ ដែលបណ្តាលមកពីប៉ារ៉ាស៊ីតម្យ៉ាងរាងមូល តោងជាប់នៅក្នុងពោះវៀន។ សត្វកើតជំងឺនេះមានសភាពក្រិន ក្រធំ ចុះទម្ងន់។ ពូនមូលអាចឆ្លងតាមរយៈមនុស្ស កណ្តុរ សត្វចាប រុយ។ល។

**ក.រោគសញ្ញា:**
មាន់ដែលឈឺមានរោមបះ ខ្នងកោង ក្បាលសំយ៉ុង ភ្នែកបិទ ញាក់ញ័រ មានចេញឈាមតាមគូថតែអត់រាក ក្រោយមកមាន់ក៏ងាប់។ មាន់ខ្លះចេញរោគសញ្ញាច្បាស់លាស់ សំកុក ស៊ីតិចតួច ស្រេកទឹក លាមកពណ៌លឿង ឬក្រហមតិចៗ (លាយឈាម)ពិបាកដើរ រាកខ្លាំងក្លា គូថប្រឡាក់លាមកហើយមានរំអិលពណ៌ក្រហមមាន់ខ្លះងាប់ មាន់ខ្លះរស់ ។

**ខ.ការការពារៈ**

- អនាម័យ កុំចិញ្ចឹមកូនមាន់នៅក្នុងទ្រុងដែលធ្លាប់ចិញ្ចឹមមាន់ធំ
- មាន់ឈឺ ឬសង្ស័យថាឈឺ ត្រូវដកចេញ
- ចិញ្ចឹមធ្វើទ្រុងខ្ពស់ពីដី កុំឱ្យមាន់ស៊ីលាមកគ្នាវា
- ត្រូវធ្វើកម្មវិធីទម្លាក់ព្រូន

**គ.ការព្យាបាលៈ ប្រើថ្នាំ** Furazolidon

កម្រិតការពារ ១៥០ ក្រាម ក្នុងចំណី ១ តោន (០.០១៥%)ឱ្យមាន់ស៊ីក្នុងរយៈពេល ៧ថ្ងៃ។ កម្រិតព្យាបាលៈ ៤០០ ក្រាម ក្នុងចំណី ១ តោន (០.០៤០%)ឱ្យមាន់ស៊ីរយៈពេល ៧ថ្ងៃ បន្ទាប់មកប្រើតាមកម្រិតការពារវិញ ។

? តើមានវិធានការដូចម្តេច ដើម្បីកុំឱ្យកើតស្រមើលនៅនឹងសំបុកមាន់?

ការការពារស្រមើលនៅលើសំបុកមាន់ៈ ជាទូទៅស្រមើលច្រើនកើតនៅលើសំបុកមាន់ជាពិសេសនៅពេលដែលមាន់កំពុងក្រាប។ ដូច្នេះមុននឹងឱ្យ មេមាន់ក្រាបពងអ្នកគួរសម្លាប់និងការពារស្រមើលឬចៃលើខ្លួនមេមាន់និងសំបុកជាមុន សិនដោយប្រើ សារម៉ាវព្រៃ ស្លឹកស្តៅ ស្លឹកគ្រៃ ស្លឹកស្មាច់ ស្លឹកទៀប ស្លឹកម្រះព្រៅ ស្លឹកទន្រ្ទានខែត្រ។ល។ ដាក់នៅបាត សំបុក មុនឱ្យមេមាន់ពង។ គួររៀបចំសំបុក ឱ្យស្មើនឹងមេមាន់ ដើម្បីកុំឱ្យវាដណ្តើមសំបុកគ្នាពង។ នៅពេលដែលកូនវាញាស់អស់ គួរយកសំបុកនិងអ្វីដែលយើងដាក់បាតសំបុក សម្រាប់ឱ្យវាក្រាបពងនោះទៅដុតចោលទាំងអស់ ដើម្បីសម្លាប់ចៃនិងស្រមើល។

## សកម្មភាពសំខាន់។ ⌚ ៣០ នាទី

យើងនាំគ្នាទៅកន្លែងចិញ្ចឹមមាន់ ដើម្បីពិនិត្យនិងតាមដានមាន់មានជំងឺ។

គ្រូនិងសិស្សពិនិត្យតាមដានមាន់មានជំងឺ ហើយចាប់មករក្សាទុកខាងក្រៅទ្រុងដើម្បីព្យាបាល។ពិនិត្យរួចហើយត្រឡប់ទៅថ្នាក់វិញ។

ថ្ងៃក្រោយគ្រូវរក់វ៉ាក់សាំងផ្តល់ឱ្យមាន់។

## បញ្ចប់មេរៀន ⌚ ១០ នាទី

ឱ្យសិស្សយកសៀវភៅ កត់ខ្លឹមសារមេរៀន និងសំណួរនៅលើក្តារខៀនយកទៅមើល និងឆ្លើយនៅផ្ទះ។ ដើម្បីឱ្យចម្លើយកាន់តែច្បាស់ ត្រូវចេះសាកសួរឪពុកម្តាយ បងប្អូន ឬអ្នកជិតខាង។

សំណួរៈ ១.តើធ្វើដូចម្តេចដើម្បីបង្ការជំងឺមាន់?

២. តើមានវិធានការដូចម្តេច ដើម្បីកុំឱ្យកើតស្រមើលនៅនឹងសំបុកមាន់?

តាមដានរៀងរាល់ថ្ងៃ ទាំងព្រឹក ទាំងល្ងាច

បណ្តាំផ្ញើៈ

- មាន់ដែលងាប់ដោយសារជំងឺ ត្រូវដុតចោល
- មាន់មានជំងឺ ត្រូវចាប់ចេញពីក្នុងទ្រុង មករក្សាទុកខាងក្រៅដើម្បីតាមដាននិងព្យាបាល
- ដើម្បីឱ្យការចិញ្ចឹមកាន់តែមានប្រសិទ្ធភាព ត្រូវចាក់វ៉ាក់សាំងកូនមាន់ទើបនឹងញាស់

កំណត់សម្គាល់: *ខ្លឹមសារខាងលើនេះដកស្រង់ចេញពីសៀវភៅរបស់អង្គការស៊ីដសេ - កម្ពុជា CIDSE - CAMBODIA កម្មវិធីបណ្ដុះបណ្ដាលបច្ចេកទេសកសិកម្ម ឆ្នាំ១៩៩៦។*

## ល្បែងកំសាន្ត : ស្រឡាញ់កូនក្មេងកៅស៊ូ

១០ នាទី

ឱ្យសិស្សទាំងអស់ឈរជារង់ បែរមុខចូលក្នុងទាំងអស់គ្នា មានម្នាក់ឈរនៅកណ្ដាល ហើយពន្យល់ថា:

- នេះជាក្មេងកៅស៊ូ យើងទាំងអស់គ្នា ប្រឡែងលេងជាមួយនឹងកូនក្មេងកៅស៊ូនេះ ឱ្យដូចនឹងកូនក្មេងពិត។

- ការប្រឡែងលេងនេះ អ្នកណាចង់ធ្វើអ្វីក៏បានដែរដូចជា: សិតសក់ឱ្យវា ធ្វើជាពរវា ធ្វើជាងូតទឹក ធ្វើជាលាបម្សៅធ្វើជាថើបវា ហើយប្រឡែងលេងជាមួយកូនកៅស៊ូនេះ (រយៈពេលប្រហែលកន្លះវិនាទី/ម្នាក់) គឺធ្វើម្នាក់ម្ដងៗ រហូតដល់គ្រប់គ្នា ត្រូវចងចាំសកម្មភាពរបស់ខ្លួនផង។

- លុះធ្វើបានគ្រប់គ្នាហើយ អ្នកឈរកណ្ដាលទទួលយកកូនកៅស៊ូមកវិញ ហើយនិយាយបន្តថាយើងទាំអស់គ្នារាប់លេខ ម្នាក់រាប់លេខ ១ ខាងស្ដាំដៃបន្ទាប់រាប់លេខ ២ អ្នកស្ដាំដៃបន្តរាប់លេខ ១ លេខ ២ រហូតដល់គ្រប់គ្នា។

- ក្រោយពីរាប់លេខរួចហើយ អ្នកលេខ១ និងអ្នកលេខ ២ ឈរទល់មុខដៃគូទាំងអស់គ្នា បានន័យថាអ្នកលេខ ១ដៃគូជាមួយអ្នកលេខ ២។ អ្នកដែលប្រកាន់លេខ ១ ទាំងអស់គ្នា យកសកម្មភាពដែលខ្លួនបានធ្វើជាមួយនឹង កូនក្មេងកៅស៊ូ មកធ្វើជាមួយនឹងដៃគូរបស់ខ្លួន។ លុះដល់អ្នកទី ១ ធ្វើចប់ អ្នកទី ២ យកសកម្មភាពដែលខ្លួនបានធ្វើជាមួយនឹងកូនក្មេងកៅស៊ូ មកធ្វើជាមួយនឹងអ្នកទី ១ វិញម្ដង។

- លុះបានធ្វើសកម្មភាពដាក់គ្នាចប់ហើយ អ្នកឈរនៅកណ្ដាល ឱ្យអ្នកទាំងអស់ឈរបែរមុខចូលក្នុង ហើយលើកឡើងថា អ្នកដែលធ្វើសកម្មភាពបានល្អដូចដើមឈរនៅនឹងកន្លែង ដោយឡែកអ្នកដែលធ្វើមិនដូចសកម្មភាព ដែលខ្លួនបានធ្វើជាមួយនឹងកូនកៅស៊ូនោះ ចូលមកក្នុងរង់ដើម្បីពិន័យ។

- ពិន័យ មានច្រៀង មានរាំ ជួនកាលច្រៀងផងរាំផង ជួនកាលគ្រាន់តែរាំ ឯអ្នកឈរនៅខាងៗច្រៀង។



# មេរៀនទី ១០: ចំណេះដឹងក្នុងការចិញ្ចឹមមាន់

🕑 រយៈពេលបង្រៀន: ២ ម៉ោង

☑ ការត្រៀមលក្ខណៈ

មុនពេលបង្រៀនលោកគ្រូ អ្នកគ្រូត្រូវ

- អាន និងពិនិត្យមេរៀនដោយហ្មត់ចត់ និងធ្វើកិច្ចតែងការបង្រៀន
- ពិនិត្យមើលឯកសារសិស្ស ដើម្បីចង់ដឹងថាតើមានព័ត៌មាន និងសំណួរ សម្រាប់សកម្មភាពគ្រូវ នឹងការបង្រៀនដែរឬទេ?
- សរសេរសំណួរសិក្សាលើក្តារខៀន ឬនៅលើក្រដាសផ្ទាំងធំ។ ប្រសិនបើសិស្សមានសៀវភៅ គេអាចមើល ព័ត៌មាននេះនៅក្នុងសៀវភៅរបស់គេបាន
- មើលកាលវិភាគប្រចាំថ្ងៃ
- រៀបចំបន្ទប់រៀន (តុ កៅអី ក្តារខៀន...)

🕮 សម្ភារឧបទេស ធនធានដែលត្រូវការ

- សៀវភៅសិស្សជាជម្រើសដែលគ្រូត្រូវការប្រើបើចាំបាច់
- ដីស ហ្វឺតសរសេរក្តារខៀន
- សំណាកមាន់មានជំងឺ ថ្នាំព្យាបាលវ៉ាក់សាំង។ល។
- សំណួរសរសេរ សម្រាប់តេស្តចំណេះដឹង

☼ វត្ថុបំណង

នៅពេលរៀនមេរៀននេះចប់សិស្សទាំងអស់អាចៈ

- កំណត់ពីចំណី ដែលធ្វើឱ្យមាន់រហ័សឆាប់ធំធាត់
- បង្ហាញពីប្រព័ន្ធរំលាយអាហាររបស់មាន់។

**រំឭកមេរៀនទី ៩: ជំងឺមាន់** 🕑 ១០ នាទី

លោកគ្រូ/អ្នកគ្រូពិនិត្យវត្តមាន រួចប្រមូលកិច្ចការសិស្សមកកែ បន្ទាប់មកជាមួយសិស្សដូចមានសំណួរខាងក្រោមៈ

◈ តើធ្វើដូចម្តេចដើម្បីបង្ការជំងឺមាន់? សិស្សនាំគ្នាឆ្លើយៈ

ដើម្បីបង្ការជំងឺមាន់ ត្រូវអនុវត្តដូចតទៅៈ

- កូនមាន់ទើបញាស់ត្រូវផ្តល់វ៉ាក់សាំង និងត្រូវមានថ្នាំបង្ការសម្រាប់មានធំ
- អនាម័យទ្រុង កុំចិញ្ចឹមកូនមាន់នៅក្នុងទ្រុងដែលធ្លាប់ចិញ្ចឹមមាន់ធំ
- មាន់ឈឺ ឬសង្ស័យថាឈឺ ត្រូវដកចេញ បើងាប់ត្រូវដុតឬកប់ចោល
- ចិញ្ចឹមធ្វើទ្រុងឱ្យខ្ពស់ពីដី កុំឱ្យមាន់ស៊ីលាមកគ្នាវា
- ត្រូវធ្វើកម្មវិធីទម្លាក់ព្រូន

តើមានវិធានការដូចម្តេចដើម្បីកុំឱ្យកើតស្រមើលនៅនឹងសំបុកមាន់? សិស្សនាំគ្នាឆ្លើយៈ

ជាទូទៅ ស្រមើលច្រើនកើតនៅលើសំបុកមាន់ ជាពិសេសនៅពេលដែលមាន់កំពុងក្រាប។ ដូច្នេះមុននឹងឱ្យមេមាន់ក្រាបពង អ្នកគួរសម្លាប់និងការពារកុំឱ្យមានស្រមើល ឬចៃលើខ្លួនមេមាន់និងសំបុកជាមុនសិន ដោយប្រើសារម៉ារព្រៃ

ស្លឹកស្តៅ ស្លឹកគ្រៃ ស្លឹកស្វាច់ ស្លឹកទៀប ស្លឹកម្រះព្រៅ ស្លឹកទន្ទ្រានខែត្រ។ល។ ដាក់នៅបាតសំបុក មុននឹងឱ្យមេមាន់ពង។ គួររៀបចំសំបុកឱ្យស្មើនឹងមេមាន់ដើម្បីកុំឱ្យវាជណ្តើមសំបុកគ្នាពង។ នៅពេលដែលកូនវាញាស់អស់គួរយកសំបុក និងអ្វីដែលយើងដាក់បាតសំបុកសម្រាប់ឱ្យវាក្រាបពងនោះទៅដុតចោលទាំងអស់ដើម្បីសម្លាប់ចៃនិងស្រមើល។

**ចំណងជើងមេរៀនទី ១០: ចំណេះដឹងក្នុងការចិញ្ចឹមមាន់** ៤០ នាទី

តើពូជមាន់ដែលគេចិញ្ចឹមសព្វថ្ងៃមានប៉ុន្មានប្រភេទ?

ពូជមាន់ដែលចិញ្ចឹមនៅក្នុងប្រទេសកម្ពុជាយើងសព្វថ្ងៃនេះមាន ២ប្រភេទសំខាន់ៗ ដូចជា ពូជមាន់នៅក្នុងស្រុក និងពូជមាន់ដែលនាំចូលពីបរទេស។

**១. ពូជមាន់នៅក្នុងស្រុក**

ជាពូជមាន់ ដែលមាននៅក្នុងប្រទេសកម្ពុជាយើងជាយូរយារណាស់មកហើយ។ ពូជមាន់នៅក្នុងស្រុកសំខាន់ៗ ដូចជា ពូជមាន់សំពោ មាន់ស្ហួយ មាន់សំឡី មាន់ចៃ មាន់ក្រញាស់ មាន់គក មាន់នាល និងមាន់កណ្តូង។ល។ លក្ខណៈ របស់ពូជទាំងនេះគឺ មានខ្លួនតូច លូតលាស់យឺត ពងតិច តែមានការធន់នឹងជំងឺជាងពូជមាន់នាំចូល។ មាន់ក្នុងស្រុកមានលក្ខណៈពិសេសងាយស៊ាំនឹងធាតុអាកាស ស៊ីចំណីមិនរើស អាចលែងឱ្យដើររកស៊ីតាមភូមិ និងអាហាររបស់មនុស្ស ជ្រូក ចេះថែរក្សាកូន ហើយអាចក្រាបភ្ញាស់កូនបានដោយខ្លួនឯងទៀតផង។ ពូជមាន់ក្នុងស្រុកត្រូវបាន កសិករចិញ្ចឹមក្នុងចំនួនតិចតួច។

**២. ពូជមាន់នាំចូល**

ជាពូជថ្មីដែលត្រូវបានគេនាំចូលពីបរទេស ហើយភាគច្រើនត្រូវបាន ចិញ្ចឹមជាលក្ខណៈទ្រង់ទ្រាយធំ។ពូជទាំងនេះមាន ២ប្រភេទគឺពូជសម្រាប់ចិញ្ចឹមយកពង និងពូជសម្រាប់ចិញ្ចឹមយកសាច់។ លក្ខណៈនៃពូជមាន់ទាំងនេះគឺ មានការលូតលាស់លឿន ផ្តល់ស៊ុតបានច្រើន ធំៗ តែមិនសូវមានការធន់ទ្រាំនឹងធាតុអាកាស ជំងឺ និងស៊ីចំណីរើស។ ការចិញ្ចឹមពូជនេះ ទាមទារចំណាយថវិកា និងការថែទាំខ្ពស់។ ពូជមាន់នាំចូល ដែលគេសង្កេតឃើញនៅក្នុងប្រទេសកម្ពុជាមានដូចជា ពូជមាន់យកសាច់ ភ្លីមុត ពូជមាន់យកពង អ៊ីសាប្រោន និងពូជយូបាដជាដើម។

ពន្យល់ចំណុចសំខាន់ៗ ឬប្រាប់ សិស្សនៅក្នុងថ្នាក់ ។

**៣. ទម្លាប់ និងអត្តចរិតធម្មជាតិរបស់មាន់**

ជាលក្ខណៈធម្មជាតិមាន់ក្នុងស្រុកជាសត្វចូលចិត្តដើរកកាយរកចំណីជាហ្វូងនិងការរកញីឈ្មោលដោយខ្លួនឯង ។ កន្លែងសម្រាប់ចិញ្ចឹម ត្រូវរៀបចំ ឱ្យមាន់មានលទ្ធភាពបញ្ចេញនូវទម្លាប់របស់វាឱ្យបានល្អ។ **សកម្មភាពប្រចាំថ្ងៃដែលជាទម្លាប់របស់មាន់ជួយឱ្យមាន់លូតលាស់បានល្អតាមលក្ខណៈធម្មជាតិរបស់វាប្រកបដោយសុខភាពល្អ និងរស់នៅដោយសប្បាយចិត្ត**។ ជាទូទៅកាយវិការឬទម្លាប់ធម្មជាតិរបស់មាន់មានដូចជាពេលព្រលប់ចូលទ្រនំដេកលុះដល់ជិតភ្លឺរងាវ(មាន់ឈ្មោល)ពេលព្រឹកព្រលឹមស្រាងៗ ចុះពីទ្រនំដើររកចំណី។ លុះដល់ម៉ោង៩-១០ ព្រឹកមាន់ញីពងលុះដល់ពេលថ្ងៃត្រង់វាចុះមកត្រសុះលេងដីដើម្បីសម្អាតរោមនិងជម្រុះចៃឬស្រមើល។ នៅពេលថ្ងៃរសៀលបន្តិចវានាំគ្នាដេកលេងកំដៅថ្ងៃ ដើរកកាយរកចំណីស៊ីម្តងទៀតហើយដល់ពេលល្ងាចនាំគ្នាចូលទ្រនំវិញ។ ចំពោះសកម្មភាពបន្តពូជជាទូទៅ គឺមានគ្រប់ពេលវេលាទាំងអស់លើកលែងតែពេលដេក។

**៤. ការលូតលាស់របស់មាន់**

**ក.ការលូតលាស់របស់ស៊ុត**

ជាទូទៅ ស៊ុតមាន់ញាស់នៅថ្ងៃទី ២១(លើសឬខ្វះ ៣ ថ្ងៃ)គិតចាប់ពីមេមាន់ ចាប់ផ្តើមក្រាប។ ការលូតលាស់របស់កូនមាន់នៅក្នុងស៊ុត ប្រព្រឹត្តទៅដោយសារកំដៅដែលផ្តល់តាមរយៈមេក្រាប។តាមរយៈការឆ្លុះមើលស៊ុត គេអាចបែងចែកការអភិវឌ្ឍរបស់ស៊ុតដូចខាងក្រោមៈ

ថ្ងៃទី៤: មានគ្រាប់ខ្មៅមួយប៉ុនគ្រាប់សណ្តែក អាចមើលឃើញ បើមិនឃើញគឺស៊ុតនោះខូច។

ថ្ងៃទី៧: សរសៃឈាមត្រូវបានគេឃើញចេញពីចំណុចខ្មៅ ហើយថង់ខ្យល់ស្លេកជាងផ្នែកផ្សេងៗទៀត។ប្រសិនបើគ្រាប់ខ្មៅចេះចល័តគឺស៊ុតនោះខូច។

ថ្ងៃទី៩: ឃើញសរសៃឈាមច្រើន ថង់ខ្យល់ឃើញច្បាស់ ហើយចំណុចខ្មៅអាចចល័ត។

ថ្ងៃទី១២: កូនមាន់មានទំហំប៉ុនប្រាក់កាក់ ពេលមានចលនា គេអាចមើលឃើញសរសៃឈាមច្បាស់។

ថ្ងៃទី១៧: ១ភាគ ៣ នៃស៊ុតទទេ ជាផ្នែកនៅសល់ពេញដោយដុំខ្មៅ គេអាចមើលឃើញចំពុះកូនមាន់។

ថ្ងៃទី២០: កូនមាន់មានរូបរាងជិតពេញលេញ ហើយលែងត្រឡប់បាន។

ថ្ងៃទី២១: ញាស់

**ខ.ការលូតលាស់របស់មាន់**

ជាទូទៅការលូតលាស់របស់មាន់ត្រូវបានចែកចេញជា៥ដំណាក់កាលសំខាន់ៗដូចជាៈ ដំណាក់កាលស៊ុតដំណាក់កាលកូនមាន់ ដំណាក់កាលមាន់ជំទង់ ដំណាក់កាលមេ និងបា ដំណាក់កាលមាន់ចាស់។ ការគ្រប់គ្រងនិងថែរក្សាមាន់ ត្រូវប្រែប្រួលទៅតាមដំណាក់កាលនីមួយៗដែរ។

**សកម្មភាពសំខាន់។** ⌚ ៣០ នាទី

វាមានសារសំខាន់ ដែលសិស្សបំពេញសំណួរគ្រប់ៗគ្នា ។ សំណួរមាន ៣ ប្រភេទ (សំណួរចងចាំសំណួរផ្គូផ្គងនិងសំណួរត្រិៈវិៈ) ដែលសិស្សត្រូវឆ្លើយសំណួរទាំងអស់នោះ។ សិស្សត្រូវឆ្លើយឱ្យបាន រហ័សតាមដែលអាចធ្វើបាន។

✋លោកគ្រូ/អ្នកគ្រូចែកទម្រង់សំណួរដល់សិស្ស (មាននៅទំព័រទី ៤៨.៤៩ និងថតចម្លងត្រៀមទុកជាស្រេច)

👄លោកគ្រូ/អ្នកគ្រូណែនាំ ដើម្បីឱ្យសិស្សបានយល់ច្បាស់ក្នុងការបំពេញសំណួរ ជៀសវាងការលុប ឬកោសនិងថែមចម្លើយ បណ្តាលឱ្យលោកគ្រូ/អ្នកគ្រូ ពិបាកកែចម្លើយទាំងនោះ។

បន្ទាប់មកសិស្សចាប់ផ្តើមបំពេញសំណួរ ដែលមានរយៈពេល ១៥ នាទី

## បញ្ចប់មេរៀន

🕑 ១០ នាទី

### ក្រុមអាហារជាតិវីតាមីន(អាហារការពារ)

ជាតិវីតាមីនចាំបាច់ក្នុងការជួយបង្កើនភាពរឹងមាំ ប្រឆាំងនឹងមេរោគ ជួយក្នុងការរំលាយអាហារ ស្រូបយកសារធាតុចិញ្ចឹម ជួយដល់ការបន្តពូជ និងប្រព័ន្ធប្រសាទ។ វីតាមីនសំខាន់ៗសម្រាប់មាន់មានដូចជាៈ វីតាមីនអា ដេ កា អឺ និង បេ។ ជាតិវីតាមីនទាំងនេះសម្បូរណ៍ នៅក្នុងស្មៅស្រស់ ចក កន្ទុំថេត ត្រកួន ល្ពៅ ស្លឹកដំឡូងមី ស្ពៃ ស្លឹកល្ពៅ និងរុក្ខជាតិបៃតងជាច្រើនប្រភេទទៀត។ កង្វះវីតាមីន បណ្តាលឱ្យមានបញ្ហាលើមាន់ដូចតទៅៈ

- កង្វះវីតាមីនអា បណ្តាលឱ្យមាន់លូតលាស់យឺត អត្រាស្លាប់ខ្ពស់ ពងថយចុះ និងមានបញ្ហាលើដំណើរការបញ្ចេញទឹកមាត់ និងទឹកភ្នែក។
- កង្វះវីតាមីនដេ បណ្តាលឱ្យកូនមាន់កើតជំងឺទន់ឆ្អឹង មាន់ជំទង់ងាយបាក់ឆ្អឹង ពងថយចុះ និងអត្រាញាស់របស់វាថយចុះ។
- កង្វះវីតាមីនកា បណ្តាលឱ្យមានការហូរឈាមតាមជើង ទ្រូង ស្លាប និងឈាមមិនងាយកក។
- កង្វះវីតាមីនអឺ បណ្តាលឱ្យកូនមាន់មានជំងឺសរសៃប្រសាទ (ជំងឺឆ្កួតមាន់)និងធ្វើឱ្យអត្រាញាស់របស់វាថយចុះគ្រិនមិនធំ និងចឹកគ្នា ហើយស្លាប់ច្រើនចំពោះកូនមាន់។
- កង្វះវីតាមីនបេ បណ្តាលឱ្យការបំបែក ការស្រូបយកក្លយស៊ីត និងលីពីតពីចំណីថយចុះ ខ្វិនជើង រោមលូតលាស់ មិនល្អ រលាកស្បែក កោសិកាឈាមក្រហមលូតលាស់មិនល្អ ខ្លាញ់រុំថ្លើមនិងតម្រងនោម។

### ជាតិទឹក

ទឹកគឺជាផ្នែកមួយដ៏សំខាន់របស់មាន់ ដែលមានប្រហែលពី ៦៥-៧០% នៃទម្ងន់ខ្លួនទាំងមូល ។ ការផ្តល់ទឹកស្អាតគឺជាកត្តាចាំបាច់បំផុតព្រោះវាមានតួនាទីជួយក្នុងការរំលាយ និងស្រូបយកអាហារដឹកជញ្ជូនសារធាតុចិញ្ចឹមដែលបានរំលាយនោះទៅកាន់សរីរាង្គ និងជួយដឹកជញ្ជូនកាកសំណល់បញ្ចេញចោល។ ក្រៅពីនោះទឹកក៏មាន តួនាទីផងដែរក្នុងការសម្របសម្រួលសីតុណ្ហភាពនៅក្នុងខ្លួន នឹងជួយកំចាត់ឬលាងជាតិពុលចេញពីខ្លួនមាន់ ។ តម្រូវការទឹករបស់មាន់មានការកើនឡើងជានិច្ចដោយយោងទៅតាមអាយុរបស់មាន់។ កង្វះទឹកធ្វើឱ្យមាន់មាន ការលូតលាស់យឺត ថយទម្ងន់ ថយពង ហើយករណីធ្ងន់ធ្ងរ វាអាចធ្វើឱ្យមាន់ងាប់។

## ការណែនាំគ្រូ

ឱ្យសិស្សតាមដានការចិញ្ចឹមមាន់ចែកវេនតាមដានឱ្យបានទៀងទាត់ដោយប្រើប្រាស់តារាងតមដាននៅក្នុងមេរៀនទី ៣។

**ល្បែងកំសាន្ត : ជិះទូកបាញ់គ្នា** ១០ នាទី

ចែកសិស្សទាំងអស់ជា ៦ ក្រុម (១ ក្រុមមានគ្នា ៥ នាក់) និងមានឈ្មោះទូក សម្រាប់ក្រុមនីមួយៗ។
ក្រុមនីមួយៗ ត្រូវជ្រើសរើសឈ្មោះទូកប្រចាំក្រុមរៀងៗខ្លួន។
ក្រុមនីមួយៗឈរជាជួរ ពីក្រោយគ្នា ហើយក្រុមទាំងអស់ឈរទល់មុខគ្នា។

ឈ្មោះទូក:

១. ហនុមានវាយលុក
២. សុវណ្ណច័ន្ទគង្គាមានឫទ្ធិ
៣. ឫទ្ធីមុនីដៃកជះមានជ័យ
៤. សុវណ្ណបុប្ផាមហាលំពែង
៥. ស្រីកំណាចដៃឆៅ
៦. ពិជ័យសាគរជាយដែន

បញ្ជាក់: ការដាក់ឈ្មោះទូកនេះ គឺដើម្បីឱ្យក្រុមផ្សេងៗទៀតពិបាកចាំឈ្មោះទូករបស់យើង។
បន្ទាប់មក ក្រុមនីមួយៗ មានគ្នា ៥ នាក់ ដូច្នេះមានតួនាទីខុសៗគ្នា ដោយស្រែកថា:

ទី១. ស្រែកថា ប្រុងប្រៀប រត់ទៅក្រោយអ្នកទី ៥
ទី២. ឡើងមកមកខាងមុខ ស្រែកថា រៀបចំ រត់ទៅក្រោយបង្អស់
ទី៣. ឡើងមកមកខាងមុខ ស្រែកថា ច្រកគ្រាប់ រត់ទៅក្រោយបង្អស់
ទី៤. ឡើងមកមកខាងមុខ ស្រែកថា តម្រង់ ត្រូវចង្អុលទៅក្រុមទី ៥ ដែលយើងចង់បាញ់ រត់ទៅក្រោយ
ទី៥. ឡើងមកមកខាងមុខ ស្រែកថា "ស្រីកំណាចដៃឆៅ" បាញ់ទន្ទឹមគ្នានោះដៃចង្អុលទៅក្រុមទី៥ នោះផង។




បន្ទាប់ពីបានធ្វើសកម្មភាពហើយ សមាជិកក្នុងក្រុម ត្រូវបានប្ដូរតួនាទីគ្នា អ្នកទី៥ មកជាអ្នកទី១ អ្នកទី១ ទៅជាអ្នកទី២ អ្នកទី ២ ទៅជាអ្នកទី៣ ...។
ចំណែកឯក្រុមដែលគេចង្អុលថាបាញ់ ថាឈ្មោះក្រុមរបស់ខ្លួន ក្រុមនេះត្រូវធ្វើសកម្មភាព ឱ្យដូចក្រុមមុនដែរ។
ក្រុមបន្ទាប់ អនុវត្តតាមដូចគ្នាមុនៗ ដែរ។


កំណើតរបស់សត្វមាន់
21 ថ្ងៃ
2 ទៅ 3
សប្តាហ៍
2 ខែ
20 ថ្ងៃ
5 ខែ
10 ថ្ងៃ
4 ថ្ងៃ
ជាតិលឿង
ស្រទាប់ សំបក
សំបក
ស្រទាប់សំបក
ខាងក្នុង
ស្រទាប់សំបក
ខាងក្រៅ
USAID

# ការចិញ្ចឹមមាន់

## ផលប្រយោជន៍នៃការចិញ្ចឹមមាន់

*ការចិញ្ចឹមមាន់ផ្តល់ផលប្រយោជន៍ដូចជា:*

- ងាយស្រួលចិញ្ចឹម មិនរើសចំណី
- មានលទ្ធភាពបន្តពូជច្រើន (ផ្តល់កូនពី ១០ទៅ ១៥ក្បាលពេលពងម្តងៗ)
- ផ្តល់សាច់ និង ស៊ុតធ្វើជាអាហារដ៏ឆ្ងាញ់
- ផ្តល់លាមកសំរាប់ដាក់ដំណាំផ្សេងៗ
- ផ្តល់រោមសំរាប់ធ្វើអំបោស
- លក់បានកំរៃសំរាប់ដោះស្រាយជីវភាព ។



*កត្តាកំណត់ក្នុងការចិញ្ចឹមមាន់ :*

- ការជ្រើសរើសពូជ
- ការផ្តល់ចំណីអាហារ និងទឹក
- ការរៀបចំជំរក ឬទ្រុង
- ការថែទាំ និងការពារ ។

## ការជ្រើសរើសពូជ:

ពូជមាន់មានពីយ៉ាង គឺពូជមាន់មកពីបរទេស និង ពូជមាន់ក្នុងស្រុក

*ក. លក្ខណៈពូជមាន់មកពីបរទេស*

- មិនសូវធន់នឹងជំងឺផ្សេងៗ (ងាយទទួលជំងឺណាស់)
- មិនអាចចិញ្ចឹមលែង ឱ្យដើររកស៊ីចំណីដោយខ្លួនវាបានទេ
- ត្រូវការថែទាំទៅតាមបច្ចេកទេសជានិច្ច (ត្រូវមានទ្រុងនិងផ្តល់ចំណីផ្សំស្រេច និង ទឹក ឱ្យបានគ្រប់គ្រាន់ មានការលូតលាស់រហ័ស ចំពោះមាន់សាច់-ផ្តល់ពងច្រើនចំពោះមាន់ផ្តល់ពង)។

*ខ. លក្ខណៈសំគាល់ពូជមាន់ក្នុងស្រុក*

- ងាយស្រួលចិញ្ចឹមក្នុងលក្ខណៈគ្រួសារ
- ធន់នឹងជំងឺ
- ចេះក្រាបភ្ញាស់ពង បណ្តើរកូន ការពារសត្រូវបានមួយចំនួន
- លូតលាស់យឺត ផ្តល់ពងតិច

*លក្ខណ្ឌជ្រើសរើសមាន់ក្នុងស្រុកមកចិញ្ចឹម (ជ្រើសរើសមាន់ជំទង់ និង មេមាន់)*

- ត្រូវទិញមាន់ពីកន្លែងណាដែលគ្មានជំងឺមកចិញ្ចឹម



- មាន់មានសុខភាពល្អ រហ័សរហួន
- សីរពណ៌ក្រហម ភ្នែកភ្លឺថ្លា
- ជើង: ស្បែកជើងមិនជ្រីវជ្រួញ ភ្លឺរលោង
- គូថទូលាយ: ចន្លោះឆ្អឹងគូថ និងឆ្អឹងទ្រូងទូលាយ (ដាក់ម្រាមដៃ៣ ចុះ)
- ផ្ទុយទៅវិញមាន់នឹងពងតិច បើឆ្អឹងគូថចង្អៀត
- គប្បីជ្រើសរើស ឬទុកមេមាន់ណា ដែលមានពងច្រើន (លើសពី១០)
- ចេះភ្ញាស់ និងថៃកូនបានល្អ
- គប្បីបំបែកកូនមកចិញ្ចឹមដោយឡែក ធ្វើយ៉ាងនេះមេមាន់ និងឆាប់ពងសារជាថ្មី




## ការរៀបចំទ្រុង

ការសាងសង់ទ្រុងមានច្រើនរបៀប អាស្រ័យទៅតាមគោលបំណង និង ធនធានរបស់អ្នកចិញ្ចឹមគេអាចសាងសង់។ អំពីសម្ភារដែលមានស្រាប់នៅក្នុងមូលដ្ឋាន ដូចជា កូនឈើ ឫស្សី ស្បូវ ស្លឹកត្នោត....។ល។ សំភារៈទាំងនេះងាយស្រួលរក ហើយចំណាយប្រាក់អស់តិចតួច។

*ការសាងសង់ទ្រុងសមស្របតាមបច្ចេកទេស*

- ក្នុងទ្រុងត្រូវធ្វើទ្រនើសំរាប់ឱ្យ មាន់ដេក
- ក្នុងទ្រុងត្រូវធ្វើទ្រនើរសំបុកឱ្យ មាន់ពង នឹងឱ្យបានគ្រប់ចំនួនមាន់ ។ គេអាចធ្វើអំពីល្ហី កញ្ជើ បង្គី ឬឡាំងក្រដាសដែលមានទំហំ៣០-៤០ស.ម ហើយដាក់ចំបើង ស្លឹកចេកឬឧការុង។ ដើម្បីជៀងវាងមានស្រមើលគេដាក់ស្លឹកថ្នាំជក់ ឬកម្ទេចកម្ទីថ្នាំជក់ក្នុងសំបុកពងនីមួយៗ



ក្នុងទ្រុងត្រូវមានស្នូកទឹក ស្នូកចំណី ឯក្រៅទ្រុងក៏ត្រូវដាក់ផងដែរដើម្បីងាយស្រួលដល់មាន់រកទឹកផឹក និងចំណី
មុននឹងដាក់មាន់បញ្ចូលទៅក្នុងទ្រុង ត្រូវធ្វើការំងាប់មេរោគ ដោយបាចកំបោរសលើផ្ទៃទ្រុងទាំងមូលហើយទុកចោលពី១-២ អាទិត្យ
ឧស្សាហ៍បោសសំរាម លាមកចេញពីកម្រាលទ្រុង ស្អាត
ទំហំទ្រុងគឺ១ម៉ែត្រការ៉េសម្រាប់មាន់ ៣ក្បាល
កុំចិញ្ចឹមាន់ក្រោមផ្ទះ ព្រោះវាមានឥទ្ធិពលមិនល្អចំពោះសុខភាពមនុស្ស។

## *ការវាយតម្លៃ*

ការវាយតម្លៃសំណួរសរសេរ: **ការចិញ្ចឹមមាន់**

ឈ្មោះ....................................... ភេទ............ ថ្នាក់ទី.......... សាលា...................................

ស្រុក............................ ខេត្ត..................................

I.សំណួរចងចាំ:

១. តើកន្លែងចិញ្ចឹមមាន់មានស្ថានភាពដូចម្ដេច?

..........................................................................................................................................

..........................................................................................................................................

២. តើការសង់ទ្រុងមាន់មានសារប្រយោជន៍អ្វីខ្លះ?

..........................................................................................................................................

..........................................................................................................................................

៣. ហេតុអ្វីបានជាមិនឱ្យកូនមាន់ទើបនឹងញាស់ស៊ីចំណីក្នុងរយៈពេល ១២ ម៉ោង?

..........................................................................................................................................

.........................................................................................................................................

៤. តើគេត្រូវជ្រើសរើសមេមាន់មានលក្ខណៈដូចម្ដេច ដើម្បីយកវាធ្វើពូជបន្ត?

..........................................................................................................................................

..........................................................................................................................................

៥. ហេតុអ្វីបានជាចាំបាច់ ទម្លាក់ព្រូនមាន់?

..........................................................................................................................................

..........................................................................................................................................

II.សំណួរខុសត្រូវ:

| សំណួរ | | ខ្លឹមសារ | ខុស | ត្រូវ |
|---|---|---|---|---|
| ១ | ក | មេមាន់ ១០ ក្បាល ត្រូវការឈ្មោល ២ ក្បាល | | |
| | ខ | មេមាន់អាយុលើសពី ៣ ឆ្នាំទុកធ្វើពូជមិនបាន | | |
| ២ | ក | កូនមាន់ទើបនឹងញាស់យើងមិនចាំបាច់ចាក់វ៉ាក់សាំង | | |
| | ខ | មេមាន់ក្រាបពង ចំនួន ២៣ ថ្ងៃទើបញាស់ | | |
| ៣ | ក | កន្លែងមាន់ពង និងកន្លែងមាន់ដេក មិនដាក់នៅជាមួយគ្នា | | |
| | ខ | ចាំបាច់ធ្វើរណ្ដៅកំប៉ុស្ដឱ្យមាន់កាយ | | |

| | | | | |
|---|---|---|---|---|
| ៤ | ក | យកមាន់ដែលមានជំងឺមកបរិភោគបាន | | |
| | ខ | មាន់រាកពង ឬពងរៀច បណ្ដាលមកពីខ្វះជាតិកាល់ស្យូម | | |
| ៥ | ក | យកមាន់កូនដំបូងទុកធ្វើពូជ | | |
| | ខ | មាន់ដែលធ្លាប់កើតជំងឺទុកធ្វើពូជមិនបាន | | |

III.សំណួរវិភាគៈ

១. តើការលូតលាស់របស់មាន់មានប៉ុន្មានដំណាក់កាល ? អ្វីខ្លះ ?

...............................................................................................................................

...............................................................................................................................

...............................................................................................................................

២. តើស៊ុតមាន់អភិវឌ្ឍដូចម្ដេចខ្លះ ?

...............................................................................................................................

...............................................................................................................................

...............................................................................................................................

៣.តើគេកត់សម្គាល់ដូចម្ដេចដើម្បីឱ្យដឹងថាមាន់មានជំងឺ ?

.............................................................................................................................

...............................................................................................................................

...............................................................................................................................

៤.តើមានលក្ខណៈខុសគ្នាអ្វីខ្លះរវាងការចិញ្ចឹមមាន់ពូជក្នុងស្រុក និងពូជនាំចូល ?

...............................................................................................................................

...............................................................................................................................

...............................................................................................................................

៥. តើមានរុក្ខជាតិអ្វីខ្លះ ដែលអាចយកមកប្រើក្នុងការទម្លាក់ព្រូន ?

...............................................................................................................................

...............................................................................................................................

...............................................................................................................................

# សំណួរ និង ចម្លើយ

ការវាយតម្លៃសិស្ស មេរៀនៈ **ការចិញ្ចឹមមាន់**
មានសំណួរចំនួន ១៥ ខុសៗគ្នា ដែលទាក់ទងនឹងមេរៀន ការចិញ្ចឹមមាន់ៈ
I.សំណួរចងចាំ
១.តើកន្លែងចិញ្ចឹមមាន់មានស្ថានភាពដូចម្តេច?
- ទីកន្លែងចិញ្ចឹមមាន់មានស្ថានភាពដូចជាៈដីទួលស្រឡះ ធាតុអាកាសល្អ មានដើមឈើខ្លះៗ

២. តើការសង់ទ្រុងមាន់មានសារប្រយោជន៍អ្វីខ្លះ?
ការសង់ទ្រុងមាន់មានសារប្រយោជន៍ដូចជាៈ
- ក្រាប និងភ្ញាស់ពងទទួលផលបានល្អ
- ងាយស្រួលក្នុងការឱ្យចំណី
- ងាយស្រួលក្នុងការធ្វើអនាម័យ
- កាត់បន្ថយជំងឺផ្សេងៗ
- ងាយស្រួលក្នុងការប្រមូលលាមកសម្រាប់ធ្វើជី
- កាត់បន្ថយការបាត់បង់ដោយចោរលួច ឬសត្វស៊ី
- ងាយស្រួលក្នុងការចាប់ចាក់វ៉ាក់សាំង
- ងាយស្រួលក្នុងការតាមដានពេលកើតជំងឺ ព្យាបាល និងទម្លាក់ព្រូន
- ងាយស្រួលក្នុងការចាប់យកទៅលក់។

៣. ហេតុអ្វីបានជាមិនឱ្យកូនមាន់ទើបនឹងញាស់ស៊ីចំណីក្នុងរយៈពេល ១២ ម៉ោង?
កូនមាន់ទើបនឹងញាស់ មិនឱ្យស៊ីចំណីក្នុងរយៈពេល ១២ ម៉ោង ពីព្រោះកូនមាន់ដែលទើបនឹងញាស់ភ្លាមវានៅមានសារធាតុស៊ុតពណ៌លឿង(ស៊ុតលឿង)ដែលជាចំណីបម្រុងសម្រាប់ចិញ្ចឹមជីវិតនៅឡើយ។ ប្រសិនបើយើងរហ័សផ្តល់ចំណីឱ្យវាស៊ីពេក នោះបណ្តាលឱ្យវាអួលចំណីស្លាប់ ។

៤. តើគេត្រូវជ្រើសរើសមេមាន់មានលក្ខណៈដូចម្តេច ដើម្បីយកវាធ្វើពូជបន្ត?
ការជ្រើសរើសមេមាន់ទុកធ្វើពូជបន្ត មានលក្ខណៈដូចជាៈ
- មេមាន់ត្រូវមានរូបរាងធំធាត់ រឹងមាំ មិនដែលកើតជំងឺឆ្លង
- គួរមានទម្ងន់ ១.៥ គត្រ ឡើងទៅ
- មានអាយុចាប់ពី ៧ខែ ទៅ ៣ ឆ្នាំ
- ផ្តល់ពងយ៉ាងតិចពី ៤ ទៅ ៥ ដងក្នុង ១ ឆ្នាំ
- ផ្តល់ពង មួយដងបានពី ៨ ទៅ ១២ ពង
- ក្រាបពងម្តងៗកូនញាស់បានយ៉ាងតិច ៨ ក្បាល
- ពូកែចិញ្ចឹមកូន នៅសល់ពីងាប់យ៉ាងតិចពី ៦-៨ ក្បាល
- មិនកាច មិនចឹកកូនខ្លួនឯង ឬកូនរបស់មេដទៃទៀត

៥. ហេតុអ្វីបានជាចាំបាច់ ទម្លាក់ព្រូនមាន់?
ការទម្លាក់ព្រូនមាន់អាចជួយឱ្យមាន់មានសុខភាពរឹងមាំ ឆាប់ធំធាត់ ហើយមិនងាយកើតជំងឺផ្សេងៗទៀតផង។

II.សំណួរខុសត្រូវ:

| សំណួរ | | ខ្លឹមសារ | ខុស | ត្រូវ |
|---|---|---|---|---|
| ១ | ក | មេមាន់ ១០ ក្បាល ត្រូវការឈ្មោល ២ ក្បាល | | √ |
| | ខ | មេមាន់អាយុលើសពី ៣ ឆ្នាំទុកធ្វើពូជមិនបាន | √ | |
| ២ | ក | កូនមាន់ទើបនឹងញាស់យើងមិនចាំបាច់ចាក់វ៉ាក់សាំង | | √ |
| | ខ | មេមាន់ក្រាបពង ចំនួន ២៣ ថ្ងៃទើបញាស់ | √ | |
| ៣ | ក | កន្លែងមាន់ពង និងកន្លែងមាន់ដេក មិនដាក់នៅជាមួយគ្នា | | √ |
| | ខ | ចាំបាច់ធ្វើរណ្ដៅកំប៉ុស្ដឱ្យមាន់កាយ | | √ |
| ៤ | ក | យកមាន់ដែលមានជំងឺមកបរិភោគបាន | √ | |
| | ខ | មាន់រាកពង ឬពងវៀច បណ្ដាលមកពីខ្វះជាតិកាល់ស្យូម | √ | |
| ៥ | ក | យកមាន់កូនដំបូងទុកធ្វើពូជ | √ | |
| | ខ | មាន់ដែលធ្លាប់កើតជំងឺទុកធ្វើពូជមិនបាន | | √ |

III.សំណួរវិភាគ:
១. តើការលូតលាស់របស់មាន់មានប៉ុន្មានដំណាក់កាល? មានអ្វីខ្លះ?
ការលូតលាស់របស់មាន់ចែកចេញជា ៥ ដំណាក់កាលសំខាន់ៗ គឺ: ១.ដំណាក់កាលស៊ុត ២.ដំណាក់កាលកូនមាន់ ៣.ដំណាក់កាលមាន់ជំទង់ ៤.ដំណាក់កាលមេ និងបា ៥.ដំណាក់កាលមាន់ចាស់។

២. តើស៊ុតមាន់អភិវឌ្ឍដូចម្ដេចខ្លះ?
ស៊ុតមាន់អភិវឌ្ឍដូចតទៅ:
- ថ្ងៃទី ៤: មានគ្រាប់ខ្មៅមួយប៉ុនគ្រាប់សណ្ដែក អាចមើលឃើញ បើមិនឃើញគឺស៊ុតនោះខូច។
- ថ្ងៃទី ៧: សរសៃឈាមត្រូវបានគេឃើញចេញពីចំណុចខ្មៅ ហើយចង់ខ្យល់ស្លេកជាងផ្នែកផ្សេងៗ ទៀត។ ប្រសិនបើគ្រាប់ខ្មៅចេះចល័ត ស៊ុតនោះខូច។
- ថ្ងៃទី៩: ឃើញសរសៃឈាមច្រើន ចង់ខ្យល់ឃើញច្បាស់ ហើយចំណុចខ្មៅអាចចល័ត។
- ថ្ងៃទី១២: កូនមាន់មានទំហំប៉ុនប្រាក់កាក់ ពេលមានចលនា គេអាចឃើញសរសៃឈាមច្បាស់។
- ថ្ងៃទី១៧: ១ភាគ ៣នៃស៊ុតទទេ ជាផ្នែកនៅសល់ពេញដោយដុំខ្មៅ គេអាចឃើញចំពុះកូនមាន់។
- ថ្ងៃទី២០: កូនមាន់មានរូបរាងជិតពេញលេញ ហើយលែងត្រឡប់បាន។

- ថ្ងៃទី២១: ញាស់

៣.តើកត់សំគាល់ដូចម្តេចដើម្បីឱ្យដឹងថាមាន់មានជំងឺ?

កត់សំគាល់មាន់មានជំងឺដូចជា:

- មាន់សំកុក
- មិនស៊ីចំណី មិនផឹកទឹក
- មាន់ក្រិន ឬស្គម
- មាន់មានអាចម៍ជាប់គូថ ឬហៀរសំបោរ។

៤.តើមានលក្ខណៈខុសគ្នាអ្វីខ្លះរវាងការចិញ្ចឹមមាន់ពូជក្នុងស្រុក និងពូជនាំចូល?

លក្ខណៈខុសគ្នារវាងការចិញ្ចឹមមាន់ពូជក្នុងស្រុក និងពូជនាំចូល មានដូចខាងក្រោម:

| ពូជមាន់ក្នុងស្រុក | ពូជមាន់នាំចូល |
|---|---|
| រកចំណីក្នុងធម្មជាតិដោយខ្លួនឯង | មិនចេះរកចំណីក្នុងធម្មជាតិ |
| ក្រាបពងភ្ញាស់កូនបាន | ភ្ញាស់កូនដោយម៉ាស៊ីន |
| សាច់មានរសជាតិឆ្ងាញ់ | សាច់មិនសូវមានរសជាតិ |
| ផ្តល់ស៊ុតតិច និងទម្ងន់ទាប | ផ្តល់ស៊ុតច្រើន និងទម្ងន់ខ្ពស់ |
| ធន់ជំងឺ និងធាតុអាកាស | ត្រូវមានវ៉ាក់សាំងការពារ |

៥. តើមានរុក្ខជាតិអ្វីខ្លះ ដែលអាចយកមកប្រើក្នុងការទម្លាក់ព្រូន?

រុក្ខជាតិដែលអាចយកមកប្រើក្នុងការទម្លាក់ព្រូនមាន់បាន ដូចជា:

- គ្រាប់ ឬស្លឹកក្តម្ពទេស
- គ្រាប់សង្កែ យើងអាចលាយជាមួយចំណីរយៈពេល ៣ថ្ងៃម្តង ឬចាប់បញ្ចុក ក្នុងកម្រិត ៣ គ្រាប់ សម្រាប់មាន់ទម្ងន់ ១ គក្រ
- ផ្លែស្លា យើងអាចយកមកបញ្ចុក ឬបុកលាយចំណី ឬលាយនឹងទឹកក៏បានក្នុងកម្រិត ១/៤ នៃផ្លែស្លា សម្រាប់ទម្ងន់មាន់ ១ គក្រ
- កន្ទក់លាយជាមួយនឹងដូងទុំ កោសរួចច្របល់ចូលគ្នា( ដូងទុំ ១ ជាមួយនឹងកន្ទក់ ៣ គក្រ) ដោយដាក់ឱ្យស៊ីជារៀងរាល់ខែ ។

សំណួរទាំង ១៥ នេះ សិស្សឆ្លើយត្រូវទាំងអស់ បានទទួល ១៥ ពិន្ទុ បានន័យថា ១សំណួរ ទទួល បាន ១ ពិន្ទុ ។ ពិន្ទុសម្រាប់ការវាយតម្លៃនេះ បានភ្ជាប់ជាមួយតារាងខាងក្រោម:

| %នៃចម្លើយ | ពិន្ទុ | កំណត់សម្គាល់ |
|---|---|---|
| ពី ៦៦% ដល់ ១០០% | ចាប់ពី ១០ ឡើងទៅ | ល្អ |
| ពី ៥១% ដល់ ៦៥% | ពិន្ទុពី ៨ ទៅ៩ | មធ្យម |
| ទាបជាង ៥០% | ពិន្ទុតិចជាង ៧ | ខ្សោយ |

## ឧបសម្ព័ន្ធ ១.១ : គំរូប័ណ្ណវាយតម្លៃ (សម្រាប់គ្រូ)

# ប័ណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ......................... សាលា...................... . ខេត្ត............... ស្រុក.................. ថ្នាក់ទី ........ ប្រធានបទ................

| | | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| | **ចំណុចត្រូវដាក់ពិន្ទុ** | ពិន្ទុ (១-១៥) | និទ្ទេស |
| **កិច្ចការទី ១: តេស្តចំណេះដឹង (សំណួរសរសេរ)** | | | |
| សំណួរសរសេរមានពិន្ទុសរុប ១៥ ពិន្ទុ | បើពិន្ទុ 0 ដល់ ៧=ខ្សោយ/ បើ ៨ ដល់ ១០=មធ្យម / បើ ១១ ដល់ ១៥=ល្អ) | | |
| | **សង្កេតឥរិយាបថសិស្ស** | ពិន្ទុ (១-៥) | និទ្ទេស |
| ១ | **ការប្រាស្រ័យទាក់ទង និងការសហការ :** សកម្មភាពពិភាក្សាជាមួយសមាជិកទាំងអស់ក្នុងក្រុម និងធ្វើការបានប្រសើរ ជាមួយក្រុម ។ សិស្សស្តាប់គ្នាទៅវិញទៅមក និងផ្តល់យោបល់គ្នាទៅវិញទៅមក ។ | | |
| ២ | **ការវិភាគល្អិតល្អន់ និងការដោះស្រាយបញ្ហា :** ផ្តល់ចម្លើយដោយមានហេតុផល និងអំណះអំណាងច្បាស់លាស់ និងអាចកំណត់ដំណោះស្រាយចំពោះបញ្ហាងាយៗដែលជួបប្រទះ ។ | | |
| ៣ | **ការធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង :** មិនមានការបារម្ភច្រើន ក្នុងការធ្វើសេចក្តីសំរេចចិត្ត និងដឹងច្បាស់ថាខ្លួនគេកំពុងនិយាយឬធ្វើអ្វីមួយ ។ | | |
| ៤ | **ទំនុកចិត្តលើខ្លួនឯង :** កំឡុងពេលធ្វើបទបង្ហាញនិងពិភាក្សាក្រុម សិស្សមានទំនុកចិត្តក្នុងការនិយាយ និងចូលរួមក្នុងក្រុម | | |
| ៥ | **ការលើកទឹកចិត្ត និងការយល់ចិត្ត:** សិស្សចង់បន្តរៀនសូត្របន្ថែមពីប្រធានបទនេះ ហើយយល់ច្បាស់ខ្លឹមសារក្នុង ប្រធានបទ និងការអនុវត្តផ្ទាល់ ។ | | |
| ៦ | **ចរិត : សិស្ស**មានចិត្តអំណត់និងអារម្មណ៍ល្អនៅក្នុងការសិក្សា ។ | | |
| ៧ | **ការបង្កើតថ្មី :** សិស្សបង្ហាញនូវភាពច្នៃប្រឌិតក្នុងការរៀបចំការធ្វើបទបង្ហាញផលិតផល នៅកំឡុងពេលសិក្សា ដោយបង្ហាញចេញនូវគំនិតជាច្រើន ។ | | |
| | **សរុបសង្កេតឥរិយាបថសិស្ស** | | |
| សង្កេតឥរិយាបថសិស្សមានពិន្ទុសរុប ៣៥ ពិន្ទុ ( បើពិន្ទុ 0 ដល់ ១៧ =ខ្សោយ/ បើ ១៨ ដល់ ២៣=មធ្យម / បើ ២៤ ដល់ ៣៥=ល្អ) | | | |
| ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស ( បើពិន្ទុ 0 ដល់ ២៤=ខ្សោយ/ បើ ២៥ ដល់ ៣៣=មធ្យម / បើ ៣៤ ដល់ ៥០=ល្អ) | | | |

ថ្ងៃទី .......... ខែ ........... ឆ្នាំ ..........

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរបាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត ........................... ស្រុក ........................សាលា ............................... ថ្នាក់ទី ........... ប្រធានបទ ...................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព　　　　　　　　　　ថ្ងៃទី ........... ខែ ............. ឆ្នាំ ...........

នាយកសាលា　　　　　　　　　　ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| **ការអង្កេតថ្នាក់រៀន** | | | | | **ការវាយតម្លៃគ្រូបំណិនជីវិត** |
|---|---|---|---|---|---|
| សាលារៀន | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយ ត្រៀមសម្ភារៈរួចជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេដែរឬទេ? | 1-2-3-4-5 | |
| ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀនដោយមានតួនាទីក្រុមច្បាស់លាស់ | 1-2-3-4-5 | |
| រីករាយជាមួយមេរៀនដែលគ្រូបង្រៀន | 1-2-3-4-5 | |
| បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| អនុវត្តតាមកិច្ចតែងការបង្រៀនដែលមានឬទេ? | 1-2-3-4-5 | *សូមបញ្ជាក់ធាតុណាមួយដែលត្រូវបានប្រើ* |
| ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង? | 1-2-3-4-5 | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម/សកម្ម ឧ.ផែនទីគំនិត, ករណីសិក្សា, ការសម្តែងតួ, ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬឯកសារបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេលវេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តដល់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សជាលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ។ **សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន** ហើយស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ។ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំង។ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ។ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្អាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខា និងឈ្មោះរបស់អ្នកវាយតម្លៃ .......................

ហត្ថលេខា និងឈ្មោះរបស់គ្រូ .....................................

# ការចិញ្ចឹមមាន់



## ហេតុអ្វីត្រូវសាងសង់ទ្រុងមាន់?

- ងាយស្រួលធ្វើអនាម័យ
- កាត់បន្ថយការជល់គ្នា ជំងឺ និងចោរលួច
- ងាយស្រួលចាប់មាន់ និងប្រមូលស៊ុត

## តើយើងសាងសង់ទ្រុងដូចម្តេច?

- យ៉ាងហោចណាស់កម្ពស់១២០សម
- កន្លែងដេកនិងពងដាច់ពីគ្នា
- សាងសង់តាមបណ្តោយថ្ងៃ
- កន្លែងដេកគួរខ្ពស់ពីដី២ទៅ៣សម

## ការឱ្យចំណីមាន់

-យ៉ាងហោចណាស់១ក្រាមក្នុងមួយថ្ងៃសម្រាប់មាន់មួយ
-ឱ្យចំណីកូនមាន់អាយុក្រោម១៥ថ្ងៃពី៤ទៅ៥ដង ក្នុងមួយថ្ងៃ បន្ទាប់ពីនោះឱ្យចំណី២ទៅ៣ដង ក្នុងមួយថ្ងៃ លាយចំណីជាមួយបន្លែបៃតង និងអំបិល
- ដាក់ចំណីនៅក្នុងស្នូក ដើម្បីជៀសវាងជំងឺ សំអាតទឹក និងចំណីនៅក្នុងស្នូកនៅពេលមាន់ដេក។





ការចាក់ថ្នាំបង្ការជំងឺដល់មាន់



## ការធ្វើកំប៉ុស្តមាន់

ទ្រុងមាន់ត្រូវតែស្អាត ប៉ុន្តែជាមួយអាចម៍សត្វយើងអាចបង្កើតកំប៉ុស្តសម្រាប់មាន់ស្វែងរកចំណីដោយខ្លួនឯង។ កំប៉ុស្តនេះនឹងទាក់ទាញសត្វល្អិតផ្សេងៗ ដែលមាន់អាចស៊ីបានសម្រាប់បំពេញបន្ថែមអាហាររបស់វា។ យើងអាចប្រើកំប៉ុស្តសម្រាប់ធ្វើជីដំណាំផងដែរ។

សូមសំអាតទ្រុងមាន់ឱ្យបានរាល់ថ្ងៃ និងភក់នៅជុំវិញទ្រុងមាន់។



## ការជ្រើសរើសពូជមាន់

នៅពេលជ្រើសរើសពូជ យើងគួរជ្រើសរើសមាន់ប៉ុនៗគ្នា នៅពេលទិញមាន់ធំត្រូវពិនិត្យមើលទៅលើរោមនិងភ្នែកភ្លឺថ្លាគួរយល់ដឹងពីរូបរាងខុសៗគ្នា តាមដំណាក់កាលនៃពូជនីមួយៗ។





## ជំងឺមាន់

ជំងឺទូទៅរបស់មាន់ដូចជា New Castle Disease, VariuolaOvium,Fowl cholera, Salmonellosisand CoccidiosisAvium ជំងឺទាំងនេះយើងគួរដឹងពីរបៀបទប់ស្កាត់រោគសញ្ញានិងការព្យាបាល។